

## ត្រីស្តុបរិស័ទព្រះសហាគមន៍នានាប្រារព្ធពិធីបុណ្យភ្ជុំ រួមជាមួយប្រពៃណីខ្មែរតាមបែបកាតូលិក

<ទំព័រ-១៧-១៩និង២០




កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ កញ្ញា | ឆ្នាំ ២០២០ | លេខទី ១៣១

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

AUGUST, 2020 | #130


## មេដឹកនាំកម្ពុជាផ្តល់ទស្សនៈទានសំខាន់ៗទៅកាន់កិច្ចប្រជុំកំពូលឆ្នាំ២០២០នៃវេទិកាសេដ្ឋកិច្ចពិភពលោក

ទំព័រ-៩

## ទំនាក់ទំនងអន្តរសាសនាដើម្បីលើកកំពស់សន្តិភាព និង សុខដុមសាសនា

ទំព័រ-១៨



## ការប្រារព្ធខួប៥៥ឆ្នាំនៃព្រះវិហារសន្តមីកាអែលក្នុងខេត្តព្រះសីហនុ

ទំព័រ-១៩



# ជំនន់ទឹកភ្លៀង

*ជំនន់ទឹកភ្លៀងនេះបានប៉ះពាល់ដល់ផ្ទះប្រជាពលរដ្ឋសរុបជាង៣៥០០ខ្នង ប៉ះពាល់ប្រជាជនចំនួន៦៥៥គ្រួសារដែលត្រូវបានជម្លៀសទៅកាន់ទីទួលសុវត្ថិភាព ស្លាប់១០នាក់ បាត់ខ្លួនម្នាក់ ព្រមទាំងខូចខាតផ្លូវនិងស្ពានមួយចំនួនទៀត។* ***រូបភាព៖ រដ្ឋបាលខេត្តពោធិ៍សាត់***

ទស្សនាវីដេអូទីនេះ

## «ឌុច» មេគុកទួលស្លែងដែលធ្វើទារុណកម្មនិងសម្លាប់មនុស្សជាង១២០០០នាក់បានស្លាប់ដោយសារជំងឺក្នុងអាយុ៧៨ឆ្នាំ

ទំព័រ-៤



# ហិង្សាកើតឡើងជាបន្តបន្ទាប់ ដែលគួរឲ្យភ័យខ្លាច និងព្រួយបារម្ភ



*ដោយៈ លី សុវណ្ណា*

ស្របពេលប្រទេសកម្ពុជា កំពុងព្រួយបារម្ភ ព្រមទាំងកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូវីដ១៩ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលទៅក្នុងសហគមន៍ និងក៏កំពុងខិតខំដោះស្រាយបញ្ហាជាច្រើន សម្រាប់ពលរដ្ឋក្រីក្រ កម្មករកម្មការិនីឱ្យមានលំនឹងក្នុងជីវភាពប្រចាំថ្ងៃ នៅគ្រាដែលការងារជាច្រើនត្រូវបានផ្អាកដំណើរការនោះ ព្រឹត្តិការណ៍សង្គមនានាបានកើតឡើងជាបន្តបន្ទាប់មិនចេះចប់។

អ្វីដែលចាប់អារម្មណ៍និងភ័យខ្លាចនោះ គឺឃាតកម្ម និងអំពើហិង្សា ព្រោះតែហេតុផលនៃសេចក្តីស្នេហាស៊ីជម្រៅឬការបាត់ទំនុកចិត្តនៅក្នុងរឿងស្នេហានេះ។

ករណីនីមួយៗមានហេតុផលច្បាស់លាស់។ អ្នកប្រព្រឹត្តអំពើឃាតកម្មទាំងឡាយសុទ្ធតែបានព្យាយាមសម្លាប់ខ្លួនឯងតាមក្រោយ។ ខ្លះបានសម្រេចនិងខ្លះមិនបានសម្រេច បានត្រឹមរងរបួស។ ភាពសោកសៅទាំងអម្បាលមាណ បានធ្វើឱ្យគ្រួសារមួយបែកបាក់ព្រាត់និរាស ឪពុកម្តាយ ប្តី ប្រពន្ធ កូនជាដើម។

ការបាក់ទឹកចិត្ត ភាពអស់សង្ឃឹម និងអាត្មានិយម ហួងហែង បានជំរុញឱ្យមនុស្សបាត់នូវសតិពិចារណាខុសត្រូវ ធ្លាក់ក្នុងភាពខ្មៅងងឹតងើបមិនរួច។ តើនេះឬជាមូលហេតុនៃសេចក្តីស្រឡាញ់ស្មោះឬក៏ជាការហួងហែងអាត្មានិយម?

បងប្អូនពិតជានឹងឆ្លើយភ្លាមថា អាត្មានិយមឬចិត្តគំនិតតិរច្ឆាន...។ មានចម្លើយច្រើនដែលបងប្អូននឹងរកឃើញ។ តើហេតុអ្វីបានជាគ្មានវិធីដោះស្រាយដោយសន្តិវិធីឬអហិង្សា នៅពេលមានទំនាស់ពាក្យសម្តី? ឬហេតុអ្វីបានជាគ្មានវិធីទប់ស្កាត់នូវចិត្តគុំគួន?

នៅក្នុងជីវិតជាគូ មិនថាគ្រួសារឬដៃគូជីវិតស្នេហា ទំនាស់និងការឈ្លោះប្រកែក ព្រមទាំងខ្វែងគំនិតគ្នា គឺជារឿងដែលជៀសមិនរួច ហើយឪពុកម្តាយ ឬអាណាព្យាបាលស្តីប្រដៅនិងវាយកូន ខ្លះៗក៏ប្រហែលជារឿងដែលតែងតែកើតមានជាទូទៅនៅក្នុងសង្គមគ្រួសារភាគច្រើន។ ប៉ុន្តែអ្វីដែលសំខាន់គឺការអត់ធ្មត់ និងចេះទប់កំហឹងរបស់ខ្លួនរៀងៗខ្លួន។ មនុស្សម្នាក់ៗនៅពេលខឹងប្រាកដណាស់មិនអាចគ្រប់គ្រងខ្លួនឯងបានឡើយ ចិត្តមានៈ និងចង់ឈ្នះតែងកើតមានឡើងជារឿយៗ ដែលនាំឱ្យខ្លួនពិបាកប្រឈមមុខ និងអាចដោះស្រាយបញ្ហាបានដោយសន្តិវិធី។

ភាពជាមនុស្ស មិនត្រឹមតែមានចំណុចខ្លាំង តែក៏មានភាពទន់ខ្សោយរបស់ខ្លួនរៀងៗខ្លួន ដូច្នេះម្នាក់ៗត្រូវតែរៀនអត់ទោសឱ្យគ្នាទៅវិញទៅមក។

ក្នុងព្រះគម្ពីរគ្រីស្តបរិស័ទតែងលឺថា ត្រូវអត់ទោសឱ្យគ្នាមិនមែនតែ៧ដង ៧០ដង។ តាមជនជាតិយូដា ៧ដង ៧០ដង គឺមានន័យថាត្រូវអត់ទោសឱ្យគេរហូត។

ហេតុនេះ ការរស់នៅជាក្រុមគ្រួសារ មិនថាគ្រួសារប្រភេទណា វណ្ណៈ ឬកម្រិតណា ត្រូវតែចេះយោគយល់គ្នា និងអត់ទោសឱ្យគ្នា ដើម្បីឱ្យគ្រួសារនោះ អាចទៅមុខដោយសុភមង្គល។

ជាការពិត ទំនាស់វាមិនដែលកើតមានដោយសារតែភាគីម្ខាងនោះទេ ដូច្នេះនៅពេលដែលមានទំនាស់ឬក៏ការខ្វែងគំនិតគ្នា ចែកផលប្រយោជន៍គ្នាមិនយុត្តិធម៌ នោះគួរតែមានវិធីសាស្ត្រកាត់បន្ថយ ដោយម្យ៉ាងនៅពេលដែលឃើញភាគីម្ខាងទៀតខឹងហើយនោះ គួរតែអត់ធ្មត់ទប់អារម្មណ៍កុំអាលឆ្លើយឆ្លង។

អំពើហិង្សាភាគច្រើនតាមការសង្កេតកន្លងមក វាច្រើនតែកើតចេញពីការឌឺដងដាក់គ្នាផងដែរ ដោយនៅពេលដែលភាគីម្ខាងកំពុងតែខឹង ហើយនោះ ភាគីម្ខាងទៀតឌឺ។ សកម្មភាពឌឺដាក់គ្នាចុះឡើងនោះហើយ ដែលនាំឱ្យកើតមានជាអំពើហិង្សាកើតឡើង។

សម័យកាលនេះហើយ យើងទាំងអស់គ្នាគួរតែកុំប្រើអំពើហិង្សាមកដោះស្រាយបញ្ហាទៀតទៅ។ ខុសត្រូវឬខ្វែងគំនិតគ្នាយ៉ាងណា ពេលដែលអារម្មណ៍ក្តៅក្រហាយទប់លែងបានគួរតែដើរចេញ ហើយពិចារណារកកំហុសរៀងៗខ្លួន។

បងប្អូនគួរចេះបញ្ចេញប្រាប់អ្នកដទៃដែលខ្លួនទុកចិត្ត និយាយរៀបរាប់នូវកំរិតទុក្ខលំបាកផ្លូវចិត្តរបស់ខ្លួនផងដែរ ដើម្បីកុំឱ្យគំនុំ និងភ្លើងកំហឹងឆេះធំក្នុងចិត្តបណ្តាលឱ្យឈឺទប់មិនបានឬការធ្លាក់ទឹកចិត្តដែលមិនអាចស្រោចស្រង់បាន ហើយសម្រេចចិត្តខុស។ ឬមួយម្នាក់ៗគួររៀនធ្វើសមាធិ តាមលទ្ធភាពរបស់ខ្លួនក្នុងជំនឿរៀងៗខ្លួនដែរ។ មនុស្សជារូបតំណាងរបស់ព្រះជាម្ចាស់។ បងប្អូនមានតម្លៃហួសពីការស្មាន ព្រោះម្នាក់ៗជាបុត្រធីតារបស់ព្រះជាម្ចាស់។

សរុបសេចក្តីមក អំពើហិង្សាគ្រប់ទម្រង់គួរតែបញ្ចប់ ហើយជាពិសេស បើអាចបាន គួររួមគ្នាស្វែងរដំណោះស្រាយបញ្ចប់ឱ្យបាននូវអំពីហិង្សានៅក្នុងគ្រួសារឬរវាងដៃគូជីវិត។ អំពើហិង្សាគឺជាអំពើឧក្រិដ្ឋមួយដែលអាចនឹងមានទោសទណ្ឌរហូតដល់កម្រិតព្រហ្មទណ្ឌ៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខៈ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# អគារសាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍នឹងប្តូរទីតាំងទៅក្នុងតំបន់អភិវឌ្ឍន៍OCIC

*អត្ថបទៈ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាលបានយល់ព្រមតាមការស្នើសុំអនុញ្ញាតសាងសង់អគារសាលាយុត្តិធម៌ថ្មីមួយខ្នងសម្រាប់ប្រើប្រាស់ធ្វើជាអគារសាលាដំបូងរាជធានីភ្នំពេញ និងអគារសាលាឧទ្ធរណ៍ភ្នំពេញដោយឱ្យក្រុមហ៊ុន លី ឈួង សំណង់និងអាហារ័ណនីហរ័ណ អនុវត្តគម្រោងសាងសង់។

យោងតាមលិខិតដែលចុះហត្ថលេខាដោយលោក សុក ផេង រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី បានឱ្យដឹងថា រាជរដ្ឋាភិបាលបានយល់ព្រមជាគោលការណ៍ដោយសាងសង់អគារសាលាយុត្តិធម៌ថ្មីមួយខ្នងកម្ពស់៧ជាន់ ដែលមានផ្ទៃក្រឡាសរុបចំនួន១៩៩៥៩ម៉ែត្រក្រឡា សម្រាប់ប្រើប្រាស់ធ្វើជាអគារសាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងអគារសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

លោក សុក ផេង បានលើកឡើងបន្ថែមតាមរយៈលិខិតដដែលនេះថា ដោះដូរទីតាំងរបស់សាលាដំបូងរាជធានីភ្នំពេញនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដែលមានផ្ទៃដីទំហំ ១៧៥៦ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ២១៧ កែងផ្លូវលេខ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាថ្នូរនឹងការសាងសង់អគារសាលាយុត្តិធម៌ថ្មីនៅលើដីដែលទទួលបានពីរាជរដ្ឋាភិបាលទំហំ៩៤៥៦ម៉ែត្រក្រឡា ស្ថិតក្នុងតំបន់អភិវឌ្ឍន៍OCIC សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដោយអនុវត្តស្របតាមគោលការណ៍ឯកជនភាវូបនីយកម្ម។

លោកបានសង្កត់ធ្ងន់ដូចនេះថាៈ «ដើម្បីធានាដំណើរការនៃការសាងសង់អគារសាលាយុត្តិធម៌ថ្មីនេះ អនុញ្ញាតឱ្យផ្ទេរសិទ្ធិទីតាំងដីសាលាដំបូងរាជធានីភ្នំពេញជូនក្រុមហ៊ុនមុនការសាងសង់ដោយ



*អគារសាលាដំបូងរាជធានីភ្នំពេញ ដែលស្ថិតនៅក្នុង ខណ្ឌ៧មករា រាជធានីភ្នំពេញ។ រូបភាពៈ លី សុវណ្ណា*

ពន្ធប្រថាប់ត្រាជាបន្ទុករបស់រដ្ឋ។ រដ្ឋាភិបាលផ្តល់ថវិកាបន្ថែមពីរដ្ឋចំនួន៣លានដុល្លារអាមេរិក សម្រាប់ចំណាយលើការបំពាក់សម្ភារៈបរិក្ខារនិងគ្រឿងសង្ហារឹម»។

លោក សុក ផេងបញ្ជាក់បន្ថែមទៀតថា ចំពោះថវិកាបន្ថែមនេះរដ្ឋនឹងធ្វើការទូទាត់ជូនក្រុមហ៊ុន លី ឈួង សំណង់និងអាហារ័ណនីហរ័ណនៅពេលសំណង់អគារសាលាយុត្តិធម៌និងការបំពាក់សម្ភារបរិក្ខារ និងគ្រឿងសង្ហារឹមបានបញ្ចប់ជាស្ថាពរ។

នៅពេលសាលាឧទ្ធរណ៍ភ្នំពេញនិងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ផ្ទេរទៅទីតាំងថ្មីរួចរាល់ អនុញ្ញាតឱ្យក្រសួងយុត្តិធម៌យកទីតាំងសាលាឧទ្ធរណ៍បច្ចុប្បន្នវិញដើម្បីប្រើប្រាស់។ តម្លៃនៃការដោះដូរត្រូវមានការយល់ព្រមពីគណៈកម្មាធិការឯកជនភាវូបនីយកម្ម ដោយភ្ជាប់ជាមួយថវិការដ្ឋចំនួន៣លានដុល្លារអាមេរិកផង។

លោក ជិន ម៉ាលីន អ្នកនាំពាក្យនៃក្រសួងយុត្តិធម៌បានប្រាប់ឱ្យដឹងថា ប្រសិនបើក្រសួងយុត្តិធម៌ផ្លាស់ប្តូរទីតាំងថ្មី នោះអគារសព្វថ្ងៃនេះនឹងក្លាយជាអគាររដ្ឋបាលរបស់ក្រសួងយុត្តិធម៌ និងមានការងាយស្រួលក្នុងការធ្វើការល្អជាងមុន ទីតាំងទូលាយ និងធ្វើឱ្យប្រសិទ្ធភាពការងារកាន់តែល្អ។

ចំណែក លោក ប៉ា ចន្ទរឿន ប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា បានលើកឡើងផងដែរថា ការដោះដូរទីតាំងអគាររដ្ឋ ភាគច្រើនប្រជាពលរដ្ឋហាក់មិនសូវទទួលបានព័ត៌មានលំអិតទេ ជាពិសេសពីតម្លាភាពនៃការដោះដូរនេះ។

លោកបានថ្លែងថា ៖ «នៅពេលដែលមានការដោះដូរគឺធ្វើឱ្យបាត់បង់នូវរូបភាពប្រវត្តិសាស្ត្រ និងមួយទៀតការដោះដូរទីតាំងច្រើនវាធ្វើឱ្យការិយាល័យរដ្ឋបាលរបស់យើងបែកខ្ញែកគ្រប់ទិសនៅក្នុងក្រុង ដែលធ្វើឱ្យប្រសិទ្ធភាពនិងភាពងាយស្រួលនៅក្នុងការងាររដ្ឋបាលមានការពិបាកក្នុងការធ្វើកិច្ចការងារដែរ។ ខ្ញុំចង់ឃើញការដោះដូរនេះមានតម្លាភាព»៕

# ថវិកាជិត៧៩ពាន់លានរៀលត្រូវបានផ្តល់ជូនស្ត្រីជាកម្មករនិយោជិតសម្រាលកូនក្នុងរយៈពេលជាង២ឆ្នាំកន្លងមកនេះ

*អត្ថបទៈ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ថវិកាដល់ស្ត្រីសម្រាលកូនជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ប្រមាណជាង ៧៨.៧ពាន់រៀល ក្នុងរយៈពេលជាង២ឆ្នាំកន្លងមកនេះ។

យោងតាមរបាយការណ៍របស់ការិយាល័យតាវកាលិកនៃបេឡាជាតិសន្តិសុខសង្គមដែលបានចេញកាលពីខែកញ្ញា នេះបានឱ្យដឹងថា គិតចាប់ពីថ្ងៃដែលបានដាក់ឱ្យដំណើរការនៃការផ្តល់ជូនគោលរបបប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ កន្លងទៅនេះ ថវិការបស់រាជរដ្ឋាភិបាលសរុបប្រមាណជាង ៧៨.៧ ពាន់លានរៀលហើយ។

បេឡាជាតិរបបសន្តិសុខសង្គមបានបើកផ្តល់ជូនស្ត្រីសម្រាលកូនចំនួន១៩៥,៥៣០នាក់ ដែលមានចំនួនកូនសរុប១៩៦,៨៦៦នាក់។

របាយការណ៍ដដែលនេះបានបញ្ជាក់ទៀតថា គ្រាន់តែក្នុងខែសីហា ឆ្នាំ២០២០ កន្លងទៅនេះ ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសរុបប្រមាណជាង ២.២ ពាន់លានរៀល ដែលប.ស.ស. បានបើកផ្តល់ជូនបងប្អូនសមាជិក ប.ស.ស. ជាស្ត្រីសម្រាលកូនសរុបចំនួន៥,៦៦២នាក់ ដែលមានចំនួនកូនសរុបចំនួន៥,៦៩៩នាក់។

ទាំងនេះគឺជាការយកចិត្តទុកដាក់យ៉ាងខ្ពស់បំផុតពីប្រមុខរាជរដ្ឋាភិបាលតែងតែគិតគូរពីសុខុមាលភាពនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត។

រហូតមកទល់ពេលនេះ បើទោះបីជាមានការវាយតម្លៃខ្ពស់និងទទួលបានការកោតសរសើរពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ព្រមទាំងមានការគាំទ្រពីសំណាក់បងប្អូនកម្មករនិយោជិតជាសមាជិកយ៉ាងណាក៏ដោយ ស្ថិតនៅក្នុងស្មារតីទំនួលខុសត្រូវខ្ពស់ ដែលរាជរដ្ឋាភិបាលប្រគល់ជូន បេឡាជាតិសន្តិសុខសង្គម ដោយធ្វើយ៉ាងណាឱ្យការផ្តល់សេវាគាំពារសង្គមមួយនេះ កាន់តែមានភាពល្អប្រសើរ និងទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាពខ្ពស់ជូនបងប្អូនកម្មករនិយោជិតជាសមាជិករបស់ខ្លួន។

គួររំលឹកផងដែរថា ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល សមាជិក ប.ស.ស. ជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ពេលសម្រាលត្រូវអនុវត្តតាមការណែនាំដូចជា កម្មករនិយោជិតជាស្ត្រី ត្រូវអញ្ជើញមកបំពេញបែបបទនៅទីស្នាក់ការ ប.ស.ស. ក្នុងរាជធានី ខេត្ត ក្នុងអំឡុងពេលយ៉ាងយូរ ៣ខែមុនសម្រាលកូន។

សាមុីខ្លួនត្រូវភ្ជាប់មកជាមួយនូវលិខិតពិនិត្យផ្ទៃពោះ ដែលបានបញ្ជាក់កាលបរិច្ឆេទត្រូវសម្រាល (អេកូ) ប័ណ្ណសមាជិក ប.ស.ស. ឬប័ណ្ណមូលនិធិសមធម៌សុខាភិបាល អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទច្បាស់លាស់របស់សាមុីខ្លួនដែលអាចទំនាក់ទំនងបាន។

ក្នុងករណីសាមុីខ្លួនមិនបានមកបំពេញបែបបទនៅ ប.ស.ស. ក្នុងអំឡុងពេលខាងលើ សាមុីជនឬអ្នកតំណាង ត្រូវជូនដំណឹងជាបន្ទាន់មកកាន់ ប.ស.ស. យ៉ាងយូរបំផុតមួយខែ ក្រោយថ្ងៃសម្រាលកូន។

សាមុីខ្លួនឬសាច់ញាតិត្រូវជូនដំណឹងមក ប.ស.ស. តាមលេខទូរស័ព្ទទំនាក់ទំនង១២៨៦ ពេលដែលសម្រាកក្នុងមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យ) ដែលគ្មានភ្នាក់ងារ ប.ស.ស.៕

# អង្គការពីររួមគ្នាជួយផ្តល់ជំនួយសុខភាពដល់ជនចំណាកស្រុកមកពីប្រទេសថៃ

*អត្ថបទៈ អមរិន្ទ ដានុត*

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA-កយកា) បានចុះអនុស្សារណៈយោគយល់គ្នា (MoU) ជាមួយនឹងអង្គការអន្តរជាតិទេសសន្តរប្រវេសន៍ (IOM) កាលពី ខែកញ្ញានេះ ដើម្បីផ្តល់ជំនួយសុខភាពជាបន្ទាន់ដល់ជនចំណាកស្រុកពីប្រទេសថៃ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ស្តីពីភាពជាដៃគូយុទ្ធសាស្ត្រ ថ្មី ដើម្បីជួយដល់ជនចំណាកស្រុក កម្ពុជាដែលវិលត្រឡប់មកពីប្រទេសថៃវិញ។

លោកស្រី Kristin Parco ប្រធានបេសកម្មនៃអង្គការអន្តរជាតិទេសសន្តរប្រវេសន៍ (IOM) និងលោក Hyunjun Rho ជានាយកប្រចាំប្រទេសនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានចុះកិច្ចព្រមព្រៀងភាពជាដៃគូ/អនុស្សរណៈនៃការយោគយល់គ្នា (MoU) ដើម្បីផ្តល់ជំនួយសុខភាពជាបន្ទាន់ដល់ជនចំណាកស្រុកពីប្រទេសថៃ។

សេចក្តីប្រកាសព័ត៌មានបានបន្តថា ភាពជាដៃគូថ្មីនេះមានគោលបំណងពិសេសដើម្បីការពារជនចំណាកស្រុកដែលវិលត្រឡប់មកស្រុកកំណើតវិញ។

ជនចំណាកស្រុកជាង១១ម៉ឺននាក់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញចាប់តាំងពីខែមីនាឆ្នាំ ២០២០ បន្ទាប់ពីការបិទអាជីវកម្ម និងការបាត់បង់ការងារនៅក្នុងប្រទេសថៃនិងប្រទេសជិតខាង។ អង្គការអន្តរជាតិទេសសន្តរប្រវេសន៍ (IOM) កម្ពុជាបាននិងកំពុងជួយដល់ជនចំណាកស្រុកដែល វិលត្រឡប់មកវិញនៅតាមច្រកព្រំដែនក្នុងមណ្ឌលដាច់ដោយឡែក និងនៅតាមខេត្តរបស់ពួកគេ។

ដោយមានការគាំទ្រ KOICA អង្គការអន្តរជាតិទេសសន្តរប្រវេសន៍នឹងបន្តផ្តល់ព័ត៌មាន អំពីការការពារជំងឺកូវីដ១៩ ដល់ជនចំណាកស្រុក និងសហគមន៍ ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃ ការប្រមូលសំណាកគំរូរបស់ជំងឺកូវីដ១៩ នៅតាមខេត្តនិងផ្តល់នូវកញ្ចប់ស្បៀងអាហារនិង អនាម័យចាំបាច់ដល់ជនចំណាកស្រុកដែលនៅដាច់ដោយឡែកពីគ្នា។

លោកស្រី Kristin Parco បានមានប្រសាសន៍ថាៈ «ការគាំទ្រពី KOICA នឹងជួយដោះស្រាយនូវ សេចក្តីត្រូវការជាបន្ទាន់របស់ជនចំណាកស្រុកនិងសហគមន៍ដែលវិលត្រឡប់ពីចំណុចចូលទៅកាន់មណ្ឌលដាច់ស្រយាលនិងតំបន់ដែលវិលត្រឡប់មកវិញ។ កិច្ចខិតខំប្រឹងប្រែងនិង កិច្ចសហប្រតិបត្តិការរួមគ្នាដូចជា KOICA និងរដ្ឋាភិបាលកម្ពុជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសមត្ថភាពជាតិនិងការត្រៀមលក្ខណៈក្នុងតំបន់និងវិបត្តិនៅក្នុងវិបត្តិរាតត្បាតនេះ»៕

# «ឌុច» មេគុកទួលស្លែងដែលធ្វើទារុណកម្មនិងសម្លាប់មនុស្ស ជាង១២០០០នាក់បានស្លាប់ដោយសារជំងឺក្នុងអាយុ៧៨ឆ្នាំ

*អត្ថបទ៖ អមរិន្ទ្រដានុត*

ទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅឌុច ដែលជាអតីតមេគុកទួលស្លែងក្នុងរបបខ្មែរក្រហមនិងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតក្នុងពន្ធនាគារខេត្តកណ្តាល បានទទួលមរណភាពក្នុងវ័យ៧៨ឆ្នាំ ក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ដោយរោគាពាធ។

ទណ្ឌិតរូបនេះបានធ្លាក់ខ្លួនឈឺធ្ងន់និងបានបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កាលពីយប់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២០។

សាកសពរបស់ឌុចត្រូវបានធ្វើការបូជាភ្លាមៗ ប៉ុន្មានម៉ោងក្រោយពីទទួលមរណៈភាព ដោយមិនមានសាច់ញាតិណាមួយចេញមុខរៀបចំពិធីបុណ្យសពឡើយ។ សពរបស់លោកត្រូវបានបូជានៅវត្តចាក់អង្រែក្រោមក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ ក្រោមវត្តមានសាច់ញាតិរបស់លោកប្រហែលប្រាំនាក់រួមទាំងសមត្ថកិច្ចនិងអាជ្ញាធរជួយរៀបចំឱ្យតែប៉ុណ្ណោះ។

នៅក្នុងចំណោមអតីតមេដឹកនាំខ្មែរក្រហមដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញធ្វើការចោទប្រកាន់ និងឃុំខ្លួន ឌុចជាមនុស្សទីមួយដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទឧក្រិដ្ឋក្នុងសម័យខ្មែរក្រហម។ ថ្វីដ្បិតតែ ឌុចមិនមែនជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែ ឌុច ជាមេគុកទួលស្លែង ជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មនិងសម្លាប់មនុស្សជាង១២០០០នាក់។

យោងតាមឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានឱ្យដឹងថា ឌុច មានឈ្មោះដើមថា កាំង ហ្គេកអ៊ាវ កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ កាំង ហ្គេកអ៊ាវ ជាកូនកាត់ចិន មានបងប្អូនបង្កើត ៥នាក់ នៅក្នុងត្រកូលជាកសិករក្រីក្រ។ កាំង ហ្គេកអ៊ាវ បានមករៀននៅវិទ្យាល័យដ៏ល្បីល្បាញមួយក្នុងក្រុងភ្នំពេញ គឺវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយបានស្នាក់នៅវត្តឧណ្ណាឡោម។

នៅឆ្នាំ១៩៦៤ កាំង ហ្គេកអ៊ាវ បានប្រឡងជាប់បាក់ឌុប ដោយជាប់ជាសិស្សឆ្នើមទូទាំងប្រទេស ផ្នែកគណិតវិទ្យា។ បន្ទាប់មក កាំង ហ្គេកអ៊ាវ បានទៅចូលរៀននៅវិទ្យាស្ថានគរុកោសល្យ នៅជិតវិមានឯករាជ្យ។ នៅឆ្នាំ១៩៦៥ កាំង ហ្គេកអ៊ាវ បានចេញទៅធ្វើគ្រូបង្រៀនផ្នែកគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា នៅវិទ្យាល័យស្គន់ ខេត្តកំពង់ធំ។ អ្នកដែលធ្លាប់រៀនជាមួយ កាំង ហ្គេកអ៊ាវ បានឱ្យដឹងថា កាំង ហ្គេកអ៊ាវ គឺជាគ្រូម្នាក់ដែលមានចរិតស្លូតបូត រាក់ទាក់ មិនចេះវាយប្ញក និងស្និទ្ធស្នាលជាមួយសិស្ស ដែលជាហេតុធ្វើឱ្យសិស្សស្រលាញ់ ចូលចិត្តគ្រប់ៗគ្នា។



លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច។ រូបភាព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា





លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច នៅក្នុងសាលាក្តីខ្មែរក្រហម និងរូបភាពស្រមាកនៅមន្ទីរពេទ្យ។ **រូបភាព៖ សហការី**

## ការចូលបក្សកុម្មុយនិស្ត

នៅឆ្នាំ១៩៦៧ នៅពេលធ្វើជាគ្រូបង្រៀននៅកំពង់ធំ កាំង ហ្គេកអ៊ាវ ក៏បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា ហើយបានស្គាល់ ទង់ សេងហឿន ដែលក្រោយមកបានក្លាយទៅជាជំនួយការរបស់ ឌុច នៅគុកទួលស្លែង។ នៅឆ្នាំដដែលនោះ កាំង ហ្គេកអ៊ាវ ត្រូវបាននគរបាលនៃរដ្ឋាភិបាលសង្គមរាស្ត្រនិយមចាប់ខ្លួន យកទៅដាក់គុកព្រៃស នៅភ្នំពេញ។ នៅក្នុងគុក កាំង ហ្គេកអ៊ាវ បានជួបជាមួយ ម៉ម ណៃ ហៅ ចាន់ ដែលក្រោយមកបានក្លាយទៅជាអនុប្រធានរបស់ ឌុច នៅគុកទួលស្លែង។

នៅឆ្នាំ១៩៧០ ក្រោយពីត្រូវបានគេដោះលែងពីពន្ធនាគារ កាំង ហ្គេកអ៊ាវ បានរត់ទៅចូលរួមតស៊ូជាមួយខ្មែរក្រហម នៅក្នុងព្រៃស្ថិតនៅតាមបណ្តោយជួរភ្នំក្រវ៉ាញ។ កាំង ហ្គេកអ៊ាវ បានចាប់ផ្តើមប្រើឈ្មោះបដិវត្តន៍ថា ឌុច ហើយត្រូវបាន វ៉ន វ៉េត តែងតាំងឱ្យធ្វើជាមេគុក ដែលមានលេខសម្ងាត់ថា ម១៣ ស្ថិតនៅឃុំអមលាំង ខេត្តកំពង់ស្ពឺ។ ក្រោយមក ឌុច បានបង្កើតគុកមួយទៀត ដែលមានលេខសម្ងាត់ថា ម៩៩ ស្ថិតនៅជើងភ្នំឱរ៉ាល់។ មានអ្នកទោសរាប់ម៉ឺននាក់បានជាប់នៅគុកទាំងពីរខាងលើនេះ។ ចាប់ពីពេលនោះហើយដែល ឌុច បានចាប់ផ្តើមដកពិសោធន៍របៀបធ្វើទារុណកម្មសួរចម្លើយអ្នកទោស។

## នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឌុច ត្រូវបានតែងតាំងឱ្យធ្វើជាប្រធានមន្ទីរសន្តិសុខ ស២១ ហៅ គុកទួលស្លែង នៅក្រុងភ្នំពេញ។

នៅចន្លោះឆ្នាំ១៩៧៨ ដល់ដើមឆ្នាំ១៩៧៩ គឺជារយៈពេលដែលខ្មែរក្រហមបង្កើនប្រតិបត្តិការបោសសំអាតផ្ទៃក្នុងបក្សខ្លាំងក្លាជាងគេ។ ក្នុងពេលនោះ មន្ត្រីកម្មាភិបាលខ្មែរក្រហមយ៉ាងច្រើនត្រូវបានចាប់បញ្ជូនទៅឱ្យ ឌុច ធ្វើទារុណកម្មសួរចម្លើយនៅគុកទួលស្លែង។ ឌុច បានរៀបចំចងក្រងឯកសារជាច្រើនស្តីពីប្រវត្តិរូប និងចម្លើយសារភាពរបស់អ្នកទោស។ គឺឯកសារទាំងនេះហើយ ដែលបានក្លាយទៅជាភស្តុតាងយ៉ាងសំខាន់ ក្នុងការស៊ើបអង្កេតរបស់តុលាការ ខ្មែរក្រហម។

## ក្រោយការដួលរលំនៃរបបខ្មែរក្រហម

នៅព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ឌុច ស្ថិតក្នុងចំណោមមន្ត្រីកម្មាភិបាលខ្មែរក្រហមចុងក្រោយគេបង្អស់ ដែលបានរត់ចេញពីភ្នំពេញ។ ឌុច បានទៅដល់ប្រទេសថៃនៅអំឡុងខែឧសភា ឆ្នាំ១៩៧៩។ ឌុច ត្រូវបានបងធំទីពីរ នួន ជា ដកតំណែងក្នុងហេតុផលថា ឌុច មិនបានកម្ទេចឯកសារនៅគុកទួលស្លែងឱ្យអស់មុននឹងរត់ចេញពីភ្នំពេញ។ ក្រោយមក ឌុច បានទៅធ្វើជាគ្រូបង្រៀនភាសាអង់គ្លេសនិងគណិតវិទ្យា នៅសាលារៀនមួយ ក្នុងជំរំជនភៀសខ្លួនស្ថិតក្នុងទឹកដីថៃ។

នៅឆ្នាំ១៩៨៦ ឌុច ត្រូវបានមេដឹកនាំខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើជាគ្រូបង្រៀនភាសាខ្មែរ នៅវិទ្យាស្ថានភាសាបរទេសក្រុងប៉េកាំង ប្រទេសចិន។ មួយឆ្នាំក្រោយមក ឌុច បានវិលត្រឡប់មកប្រទេសថៃវិញ ហើយបានដូរឈ្មោះទៅជា ហង្ស ពិន វិញ។ ឌុច បានទៅបម្រើការនៅការិយាល័យរបស់ ប៉ុល ពត ដែលស្ថិតនៅក្នុងជំរំ៥០៥។

ក្រោយកិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ២៣ តុលា ១៩៩១ ឌុច បាននាំគ្រួសារទៅរស់នៅភូមិផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ ឌុច បានវិលត្រឡប់ទៅប្រកបរបរជាគ្រូបង្រៀនវិញ។ នៅឆ្នាំ១៩៩៥ ក្រោយពី រ៉ុម ជាប្រពន្ធបានស្លាប់ដោយសង្គ្រាម ឌុច បានសុំផ្លាស់ទៅបង្រៀននៅអនុវិទ្យាល័យស្វាយចេកវិញ។ គឺនៅពេលនោះហើយ ដែល ឌុច បានថ្វាយខ្លួនជឿព្រះយេស៊ូ ហើយទទួលពិធីជ្រមុជទឹក។ បន្ទាប់មក ឌុច បានក្លាយទៅជាគ្រូគង្វាលជំនួយនៅក្នុងព្រះវិហារមួយឈ្មោះ Golden Western Cambodian Christian Church។

## ការចាប់ខ្លួន

នៅឆ្នាំ១៩៩៩ អ្នកកាសែតបរទេសពីររូប គឺ Nate Thayer និង Nic Dunlop បានទៅជួបសម្ភាសជាមួយ ឌុច។ ក្រោយពីបទសម្ភាសន៍នេះត្រូវបានចុះផ្សាយនៅក្នុងទស្សនាវដ្តី សេដ្ឋកិច្ចចុងបូព៌ា (ឬតាមភាសាអង់គ្លេសថា Far Eastern Economic Review) ឌុច ក៏បានចូលសារភាពប្រគល់ខ្លួនឱ្យអាជ្ញាធររដ្ឋាភិបាលកម្ពុជា។ ចាប់ពីពេលនោះមក ឌុច ត្រូវបានគេចាប់ឃុំខ្លួននៅក្នុងមន្ទីរឃុំខ្លួននៃតុលាការយោធា ក្នុងក្រុងភ្នំពេញ។

នៅថ្ងៃទី៣១ កក្កដា ឆ្នាំ២០០៧ ឌុច ត្រូវបានផ្ទេរពីមន្ទីរឃុំឃាំងនៃតុលាការយោធា ទៅឱ្យអង្គជំនុំជម្រះវិសាមញ្ញ ទទួលបន្ទុកជំនុំជម្រះអតីតមេដឹកនាំខ្មែរក្រហមវិញ។ ឌុច ត្រូវបានតុលាការពិសេសធ្វើការចោទប្រកាន់ជាផ្លូវការពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ថ្វីដ្បិតតែឌុចមិនមែនជាអតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ ក្នុងឋានៈជាប្រធានគុកទួលស្លែងដែល ជាកន្លែងធ្វើទារុណកម្មនិងសម្លាប់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់នោះ ឌុច ត្រូវបានចាត់បញ្ចូលក្នុងចំណោម អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម នៅក្នុងរបបខ្មែរក្រហម។

ឌុច សារភាពកំហុស តុលាការសម្រាលទោសត្រឹមជាប់គុក ៣៥ឆ្នាំ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះវិសាមញ្ញ ទទួលបន្ទុកជំនុំជម្រះមេដឹកនាំខ្មែរក្រហមបានប្រកាសសាលក្រមសម្រេចឱ្យកាំង ហ្គេកអាវ ហៅ ឌុច ជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ក៏ប៉ុន្តែ ដោយសារឌុចបានសារភាពកំហុស និងបានសហការជាមួយតុលាការ ចៅក្រមបានសម្រេចផ្តន្ទាទោស ឌុច ឱ្យជាប់ពន្ធនាគារតែ ៣៥ឆ្នាំប៉ុណ្ណោះ។

ពីរយៈពេល ៣៥ឆ្នាំនេះ ត្រូវកាត់បន្ថយ ៥ ឆ្នាំ បន្ថែមទៀត ដោយតុលាការយល់ឃើញថា ការឃុំខ្លួនឌុច នៅក្នុងតុលាការយោធាកម្ពុជា ពីឆ្នាំ១៩៩៩ គឺជាការឃុំខ្លួនខុសនីតិវិធី។ ទីបញ្ចប់ទោសរបស់ ឌុច នៅសល់តែ ៣០ឆ្នាំប៉ុណ្ណោះ ដោយគិតចាប់ពីថ្ងៃចាប់ខ្លួន ពោលគឺពីឆ្នាំ១៩៩៩មក។

បើរាប់ពីថ្ងៃប្រកាសសាលក្រម ឌុច នឹងត្រូវជាប់ពន្ធនាគាររយៈពេលតែជាង ១៨ឆ្នាំទៀតប៉ុណ្ណោះ។ ដល់ពេលផុតទោស ឌុច នឹងមានអាយុ ៨៦ឆ្នាំ។ ប្រសិនបើ ឌុច អាចនៅរស់លើសពី ៨៦ឆ្នាំ ឌុច នឹងអាចដើរចេញពីគុក ហើយអាចរស់នៅដោយមានសេរីភាពវិញបាន៕





# លោក អ៊ុក កុសល ស្នងការខេត្តកំពង់ធំត្រូវបានបញ្ចប់ជាស្ថាពរ និងបានទម្លាក់មកសក្តិ៥

*អត្ថបទ៖ អមរិន្ទ ដានុត*

លោក អ៊ុក កុសល អតីតស្នងការខេត្តកំពង់ធំ ដែលត្រូវបានព្យួរការងារកាលពីខែសីហាកន្លងមកត្រូវបានក្រសួងមហាផ្ទៃសម្រេចបញ្ចប់តំណែងជាស្នងការខេត្តនេះជាផ្លូវការ។ នេះបើតាមការបញ្ជាក់របស់លោក ខៀវ សុភ័គ អ្នកនាំពាក្យនៃក្រសួងមហាផ្ទៃ។

លោក ខៀវ សុភ័គ បានលើកឡើងថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្តេចក្រឡាហោម ស ខេង បានចេញប្រកាសសម្រេចបញ្ចប់មុខតំណែងលោក អ៊ុក កុសល ជាផ្លូវការហើយកាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ និងបានស្នើសុំរាជរដ្ឋាភិបាលបន្ថយឋានន្តរស័កពីឧត្តមសេនីយ៍ទោ (ផ្កាយ២)មកត្រឹមវរសេនីយឯង (ស័ក្តិ៥) ផងដែរ។



លោក អ៊ុក កុសល អតីតស្នងការខេត្តកំពង់ធំ។ **រូបភាព៖ នគរបាលជាតិ**

លោកបានថ្លែងថា៖ «ករណីនេះមិនមានអ្វីទាក់ទងនឹងកំហុសព្រហ្មទណ្ឌនោះទេដោយសារជនរងគ្រោះមិនប្តឹងទៅតុលាការ គឺជនរងគ្រោះប្តឹងត្រឹមក្នុងការងាររដ្ឋបាលតែប៉ុណ្ណោះ ហើយពេលនេះយើងបានរកឃើញនូវកំហុសរបស់បុគ្គលរូបនេះថាពិតជាបានប្រព្រឹត្តដូចការប្តឹងរបស់ជនរងគ្រោះទាំងនោះមែន។ ដូចនេះខាងក្រសួងសម្រេចធ្វើការដកហូតតំណែងនិងបញ្ចុះឋានន្តរស័ករបស់គាត់ ដែលទាំងនេះខ្ញុំគិតថាជាការដាក់ទោសធ្ងន់ធ្ងរណាស់ទៅហើយ»។

លោកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជាបានលើកឡើងផងដែរថា ការផ្តល់ព័ត៌មានពីលទ្ធផលនៃការស៊ើបអង្កេតរបស់ក្រសួងមហាផ្ទៃបានបង្ហាញនូវតម្លាភាពមួយនិងថាក្រសួងបានយកចិត្តទុកដាក់មួយកម្រិតលើករណីបៀតបៀនផ្លូវភេទលើមន្ត្រីក្រោមបន្ទុក។

លោកស្រីបន្ថែមថា៖ «ការបញ្ចប់រឿងនេះត្រឹមតែការបញ្ចប់តំណែងនិងបន្ថយឋានៈហើយមិនមានចំណាត់ការតាមផ្លូវច្បាប់នេះមិនមែនដំណោះស្រាយប្រកបដោយគតិយុត្តិនោះទេ ហើយជាការផ្តល់សារដល់ជនល្មើសថា ខ្លួននឹងរួចពីសំណាញ់ច្បាប់នូវទង្វើបំពានរបស់ខ្លួន»។

នាយិការូបនេះបានបន្តថា ហេតុផលនៃសេចក្តីថ្លៃថ្នូរ កិត្តិយសដល់ជនរងគ្រោះអាចការពារតាមនីតិវិធីរបស់តុលាការដែលមានជាធរមាន បើមិនដូច្នោះបានន័យថា គ្រប់ករណីបៀតបៀនបែបនេះនឹងមិនត្រូវបញ្ជូនទៅតុលាការនិងបានយុត្តិធម៌ទេព្រោះមិនមានយន្តការការពារជនរងគ្រោះផងនោះ។

លោកស្រី ចក់ សុភាពបានថ្លែងថា៖ «ការលើកឡើងថា ចំណាត់ត្រឹមកម្រិតថ្នាក់រដ្ឋបាលប៉ុណ្ណោះគឺគ្រប់គ្រាន់ ចឹងយើងចោទសួរវិញថា ប្រសិនបើចំណាត់ការត្រឹមនីតិវិធីរដ្ឋបាលគ្រប់គ្រាន់ តើយើងមានច្បាប់ក្រមព្រហ្មទណ្ឌធ្វើអី ហើយករណីដែលក្រសួងធ្វើការស៊ើបអង្កេតនេះវាបង្ហាញនូវការយកចិត្តទុកដាក់មួយកម្រិត ប៉ុន្តែនៅពេលដែលក្រសួងមិនបន្តនីតិវិធីទៅមុខទៀតនោះ ខ្ញុំមើលទៅហាក់ដូចជាធ្វើសារមួយដែលខុសឆ្គងមែនទែន ដោយបង្ហាញថាករណីបែបនេះត្រូវបានបញ្ចប់ត្រឹមការដាក់ពិន័យរដ្ឋបាលគ្រប់គ្រាន់»។

គួររំលឹកផងដែរថា សម្តេចក្រឡាហោម ស ខេង បានសម្រេចធ្វើការផ្អាកការងារជាបណ្តោះអាសន្នកាលពីខែសីហាកន្លងមកចំពោះលោក អ៊ុក កុសល ពីស្នងការនគរបាលខេត្តកំពង់ធំបន្ទាប់ពីក្រុមនគរបាលនារីនៃស្នងការដ្ឋានខេត្តនេះធ្វើការស្នើសុំទាមទាររកយុត្តិធម៌លើការបៀតបៀនកេរខ្មាស់។

អ្នកនាំសារមិនអាចទាក់ទងសុំការអធិប្បាយបន្ថែមពីលោក អ៊ុក កុសលបានទេ ប៉ុន្តែលោកធ្លាប់បានធ្វើសន្និសីទកាសែតបដិសេធការចោទប្រកាន់មកលើរូបលោកផងដែរ។

បើតាមការបញ្ជាក់ពីលោកខៀវ សុភ័គ ស្នងការខេត្តកំពង់ធំថ្មីត្រូវជំនួសដោយលោក ម៉ែន លី អតីតស្នងការនគរបាលខេត្តឧត្តរមានជ័យដែលត្រូវបានផ្លាស់ប្តូរនាពេលថ្មីៗនេះ៕

# បណ្ណាល័យសម្តេចម៉ែត្រូវបានបើកពិធីសម្ពោធជាផ្លូវការក្រោមអធិបតីភាព សម្តេចព្រះមហាក្សត្រី មុនិនាថ សីហនុ

*អត្ថបទ៖ អមរិន្ទ ដានុត*

បណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ពោធជាផ្លូវការហើយកាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដោយសម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។

យោងតាមវិទ្យាស្ថានស្លឹករឹតបានឱ្យដឹងថា បណ្ណាល័យសម្តេចម៉ែ បានបង្កើតឡើងជាផ្លូវការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីថ្វាយព្រះរាជកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជូនសម្តេចព្រះមហាក្សត្រី ដែលបានខិតខំប្រឹងប្រែងដើម្បីសម្តេចព្រះបរមរតនកោដ្ឋ។

នៅក្នុងពិធីសម្ពោធដ៏ឧត្តុងឧត្តមនេះ មានការដាក់តាំងពិព័រណ៍ពិសេសចំនួនពីរ គឺ ព្រះឆាយាលក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយស្ថាបត្យករលំដាប់ពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ។

វិទ្យាស្ថានស្លឹករឹតបានលើកឡើងទៀតថា បណ្ណាល័យសម្តេចម៉ែ មានតម្កល់ទុកសមុច្ច័យជាសៀវភៅប្រមាណជាង៣០០០ក្បាល និងឯកសារចំនួន ២៨០០ប្រអប់ ដែលបានប្រមូលដោយលោកឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ. ដែលជ្រេស ក្នុងអំឡុងរយៈពេលជាច្រើនឆ្នាំនៃការងារចងក្រងកត់ត្រាឯកសាររបស់លោកស្តីពីរាជវង្សានុវង្ស និងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

លោកឯកអគ្គរាជទូតបណ្ឌិត ដែលជ្រេស បានបរិច្ចាគដោយសប្បុរសនូវសមុច្ច័យដ៏ធំធេងនេះដល់មជ្ឈមណ្ឌលឯកសារកម្ពុជានាចុងឆ្នាំ២០១៩។ ឯកសារដែលតម្កល់នៅក្នុងបណ្ណាល័យសម្តេចម៉ែ រួមមានសៀវភៅជាច្រើនទៀតស្តីពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងឯកសារស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) យ៉ាងហោចណាស់១លាន៧សែនទំព័រ ដែលស្រាវជ្រាវដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលប្រមាណជាង ២០ឆ្នាំកន្លងមក។

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យប្រោសប្រទានអំណោយដែលមិនអាចកាត់ថ្លៃបាន រួមមាន សៀវភៅ មេដាយ លិខិតសរសើរ គ្រឿងឥស្សរិយយស និងសម្បត្តិផ្ទាល់ព្រះកាយដ៏មានតម្លៃរបស់ទ្រង់ដល់បណ្ណាល័យ ដើម្បីឱ្យសាធារណជនបានទស្សនា សិក្សា និងយល់ដឹងអំពីតម្លៃ។

ស្របពេលដែលពិភពលោកកំពុងប្រឈមនឹងវិបត្តិនៃជំងឺរាតត្បាត កូវីដ១៩ ឯសកម្មភាពអប់រំ សកម្មភាពវប្បធម៌ និងព្រឹត្តិការណ៍ជាតិផ្សេងៗនៅតែបន្តមជ្ឈមណ្ឌលឯកសារកម្ពុជា ជឿជាក់ថា សកម្មភាពទាំងអស់នេះត្រូវតែប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងបានគិតគូរទុកជាមុនអំពីសុខភាពនិងសុខមាលភាពរបស់មនុស្សគ្រប់រូប។ អាស្រ័យហេតុនេះហើយ នាខណៈពេលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា សូមរក្សាសិទ្ធិអនុញ្ញាតឱ្យសាធារណជនចូលប្រើប្រាស់ បណ្ណាល័យសម្តេចម៉ែ តាមប្រព័ន្ធអនឡាញ។

នៅឆ្នាំ២០១៤ លោកស្រី ហ្សាហា ហាឌីដ នាយកស្ថាបត្យកម្ម ហ្សាហា ហាឌីដ និងលោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើសេចក្តីប្រកាសរួមអំពីកិច្ចសហប្រតិបត្តិការជាមួយស្ថាបត្យកម្មរបស់លោកស្រី ហាឌីដ ក្នុងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត ដែលជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំឭកនិងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ២លាននាក់ នាអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

អ្នកទស្សនានឹងបានយល់ដឹងថាតើតម្លៃទាក់ទងទៅនឹងចំណេះដឹង ការអត់ឱន ការផ្សះផ្សា និងការយោគយល់អធ្យាស្រ័យនឹងផ្តល់ឱ្យមនុស្សនូវមធ្យោបាយឆ្ពោះទៅកាន់អនាគតមួយ ដែលពោរពេញទៅដោយភោគផលនិងភាពវិជ្ជមានបានយ៉ាងដូចម្តេច។ ទន្ទឹមនឹងនេះ អ្នកទស្សនាអាចយល់ដឹងបន្ថែមទៀតពីរបៀបដាក់បញ្ចូលព្រឹត្តិការណ៍ដែលនាំឱ្យឈានដល់របបខ្មែរក្រហម ទៅក្នុងបរិបទនៃប្រវត្តិសាស្ត្រយូរលង់របស់ប្រទេសកម្ពុជា និងអាចយល់ដឹងថា ហេតុអ្វីបានជាបរិបទនោះគួរតែលើកយកមករំឭកឡើងវិញជាសាធារណៈ។

ស្ថាបត្យកម្មរបស់លោកស្រី ហាឌីដ និងលោក ឆាំង យុ បានរួមគ្នាបង្កើតជាអគារមួយនេះឡើង ដែលដើរតួនាទីពង្រីក និងពង្រឹងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបង្កើនការទទួលជ្រាបនិងការយល់ដឹងជាសាធារណៈអំពីសោកនាដកម្មដែលបានកើតឡើង និងស្វះស្វែងរកផលប្រយោជន៍សង្គមចេញពីការផ្សះផ្សាតាមរយៈការអប់រំ ការបញ្ជ្រាបចំណេះដឹង និងការធ្វើឱ្យធូរស្បើយអារម្មណ៍ ដោយផ្អែកលើការចងចាំនិងការប្តេជ្ញាចិត្ត។ ការរចនាបូជនីយដ្ឋានរបស់លោកស្រី ហាឌីដ គឺជាស្នាដៃមួយ ប្រកបដោយសម្រស់ល្អឯក និងជានិមិត្តរូបដ៏កម្រក្នុងសតវត្សរ៍ ទី២១៕





សម្តេចព្រះមហាក្សត្រី មុនិនាថ សីហនុ យាងសម្ពោធបណ្ណាល័យសម្តេចម៉ែ។ **វិទ្យាស្ថានស្លឹករឹត**

# ប្រាក់ឈ្នួលកម្មករផ្នែកវាយនភណ្ឌកាត់ដេរនិងស្បែកជើងទទួលបាន១៩២ដុល្លារអាមេរិកក្នុងឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសម្រេចតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងក្នុងឆ្នាំ២០២១ចំនួន ២ដុល្លារបន្ថែមលើប្រាក់ឈ្នួលបច្ចុប្បន្ននេះ ដែលធ្វើឱ្យប្រាក់ឈ្នួលសម្រាប់ឆ្នាំក្រោយមានចំនួន១៩២ ដុល្លារអាមេរិកក្នុងមួយខែ។

ប្រាក់ឈ្នួលអប្បបរមាថ្មីនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១តទៅ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងជាប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានថ្លែងក្នុងថ្ងៃចុងក្រោយនៃការចរចាប្រាក់ឈ្នួលនេះថា ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលបានបញ្ចប់ដោយជោគជ័យសម្រាប់ឆ្នាំ២០២០ក្នុងការកំណត់សម្រេចទៅលើប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ ២០២១ស្របទៅតាមច្បាប់ប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់។




លោកបានលើកឡើងទៀតថា ពិនិត្យទៅលើទិដ្ឋភាពច្បាប់សមាជិករបស់ក្រុមប្រឹក្សាជាតិបានអនុវត្តន៍ទៅតាមច្បាប់ហើយការសម្រេចបាននេះគឺបង្ហាញពីលទ្ធផលនៃការសហការយ៉ាងជិតស្និទ្ធិ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានឱ្យដឹងថា ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាដែលជាយន្តការត្រីភាគីនិងមានសមាជិកជាតំណាងភាគីកម្មករនិយោជិកចំនួន១៧រូប តំណាងភាគីនិយោជកចំនួន១៧រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន១៧រូប បានឯកភាពគ្នាជាឯកច្ឆន្ទគាំទ្រតួលេខ១៩០ដុល្លារអាមេរិក ជាតួលេខប្រាក់ឈ្នួលអប្បបរមាក្នុងមួយខែសម្រាប់២០២១។

ក្រុមប្រឹក្សាជាតិបានស្នើតួលេខនេះជូន លោក អ៊ិត សំហេង ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករកាត់ដេរនិងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២១។

លោក អ៊ិត សំហេង បានមានប្រសាសន៍ថា៖ «ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលបានសម្រេចជាឯកច្ឆន្ទលើតួលេខ១៩០ដុល្លារសម្រាប់ឆ្នាំ២០២១ដែលជាតួលេខចាស់ឆ្នាំ២០២០។ យើងមិនបានធ្វើការបោះឆ្នោតជ្រើសរើសតួលេខទេសម្រាប់ឆ្នាំនេះដោយសារភាគីទាំងបីបានព្រមព្រៀងគ្នាយកតួលេខមួយនេះ។ ខ្ញុំបានរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី លោកក៏បានសម្រេចធ្វើការបន្ថែម២ដុល្លារទៅលើប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយក្រុមប្រឹក្សាជាតិ។ ដូចនេះប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនៅឆ្នាំ២០២១គឺមានចំនួន១៩២ដុល្លារក្នុង១ខែ»។

លោករដ្ឋមន្ត្រីសង្ឃឹមថា ប្រាក់ឈ្នួលអប្បបរមាថ្មីនេះនឹងជួយជីវភាពរបស់កម្មករនិយោជិត និងសម្រួលដល់ការបង្កើននូវផលិតភាពការងាររបស់កម្មករដើម្បីធ្វើយ៉ាងណាឱ្យរោងចក្រ សហគ្រាសកាន់តែមានភាពប្រកួតប្រជែងជាមួយនឹងប្រទេសដែលផលិតទំនិញនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

លោករដ្ឋមន្ត្រីបានបញ្ជាក់ថា EBA មិនមែនជាបញ្ហានៃការរារាំងការតម្លើងប្រាក់ឈ្នួលនេះទេ ដោយសារបញ្ហាកូវីដ១៩នេះបានគ្របដណ្តប់ទាំងអស់ហើយ ហើយមកដល់ពេលនេះរោងចក្រចន្លោះពី១០០ទៅ១៥០បានព្យួរនិងធ្វើឱ្យកម្មករប្រមាណជា៤០,០០០ ទៅ៥០,០០០នាក់បាត់បង់ការងារធ្វើ។

លោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជា បាននិយាយក្រោយបញ្ចប់ការចរចាសម្រេចប្រាក់ឈ្នួលនេះថា ការចរចាប្រាក់ឈ្នួលអប្បបរមានៅឆ្នាំនេះជាការចរចាមួយដែលមានលក្ខណៈលំបាកជាងឆ្នាំមុនៗ ដោយសារបញ្ហាកូវីដ EBA និងការវិវត្តនៃសេដ្ឋកិច្ចទូទៅ។

លោក អាត់ ធន់ បានបញ្ជាក់ថា៖ «ការតម្លើងប្រាក់ឈ្នួលនៅឆ្នាំនេះជាចំនួនមួយដែលយើងមិនពេញចិត្តទេ ដោយសារវាតិចពេក ប៉ុន្តែយោងទៅលើស្ថានភាពនេះយើងក៏ពិបាកក្នុងការទាមទារដែរ ហើយបើសិនជាយើងចង់បានតាមការទាមទាររបស់យើងគឺអាចចំណាយពេលយូរជាងនេះទៅទៀត»។

លោក អាត់ ធន់ នឹងធ្វើការពន្យល់កម្មករពីការលំបាកនៃការតម្លើងប្រាក់ឈ្នួលនេះ ហើយប្រសិនបើគាត់មិនពេញទៀតនោះជានីតិវិធីនិងជាសិទ្ធិរបស់គាត់ ប៉ុន្តែលោកមិនគិតថា ការធ្វើកូដកម្មឬបាតុកម្មទាមទារបន្ថែមប្រាក់ឈ្នួលនេះគឺប្រាកដជាមិនអាចកើតឡើងបានទេក្នុងតំណាក់កាលនេះដោយសារ បញ្ហានយោបាយ កូវីដ និងការរឹតបន្តឹងលើច្បាប់សហជីព។

ជាមួយគ្នានេះដែរ អនុប្រធានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាដែលតំណាងឱ្យនិយោជក លោក ណាង សុធី បានមានប្រសាសន៍ថា ជាការលំបាកសម្រាប់និយោជកក្នុងការតម្លើងប្រាក់ឈ្នួលចំនួន ២ដុល្លារអាមេរិកក្នុងស្ថានភាពនេះ ប៉ុន្តែលោកថាក្នុងស្មារតីភាតរៈ ការសាមគ្គីភាពគ្នារវាងរដ្ឋាភិបាលទោះបីជាបញ្ហាកូវីដមានការលំបាកយ៉ាងណាក៏ភាគីរដ្ឋាភិបាល និយោជក និងនិយោជិក នៅរក្សាចង្កោមតែមួយរួមគ្នា។

លោក ណាង សុធី បានមានប្រសាសន៍ថា៖ «ការតម្លើងអាចជាការពិបាកសម្រាប់ការទាក់ទាញអ្នកវិនិយោគទុនក្នុងតំណាក់កាលកូវីដនេះ»។

ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាមានសមាជិកជាតំណាងភាគីកម្មករនិយោជិតចំនួន ១៧ រូប តំណាងភាគីនិយោជកចំនួន១៧រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន១៧រូបស្មើគ្នា។

ក្រៅពីប្រាក់ឈ្នួលអប្បបរមា កម្មករនិយោជិកប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករធ្លាប់ទទួលបានកន្លងមកត្រូវបានរក្សាទុកនៅដដែល ដូចជា ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅចំនួន ៧ដុល្លារក្នុង១ខែ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារក្នុង១ខែ ប្រាក់ថ្លៃបាយសម្រាប់ធ្វើការងារបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន២០០០រៀលក្នុង ១ថ្ងៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួន២ដុល្លារ ដល់១១ដុល្លារក្នុង១ខែសម្រាប់កម្មករដែលបានធ្វើការចាប់ពីឆ្នាំទី២ដល់ឆ្នាំទី១១។ ដូចនេះ ជាមធ្យមកម្មករម្នាក់ៗនឹងទទួលបានប្រាក់បៀវត្សយ៉ាងតិចចំនួនពី២០៩ដុល្លារដល់២២០ដុល្លារក្នុងមួយខែ៕

## ហ្វេសប៊ុកសហការណ៍ជាមួយអង្គការអន្តរតំបន់លើកកម្ពស់ការយល់ដឹងពីគ្រោះធម្មជាតិ

*អត្ថបទ៖ អរិយបុត្រ*

បណ្តាញសង្គមហ្វេសប៊ុក (Facebook) និងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ បានប្រកាសដាក់ឱ្យដំណើរការនូវគំនិតផ្តួចផ្តើមរួមគ្នាមួយ ដើម្បីផ្តល់ការជូនដំណឹងជាមុនស្តីពីគ្រោះទឹកជំនន់ និងព័ត៌មានតាមដានពីគ្រោះរាំងស្ងួត ដល់សហគមន៍ និងប្រទេសក្នុងតំបន់ទន្លេមេគង្គក្រោម។

នេះជាកិច្ចសហប្រតិបត្តិការដែលមិនធ្លាប់មានពីមុនមក ដោយគំនិតផ្តួចផ្តើមរួមគ្នានេះមានគោលដៅលើកកម្ពស់ការយល់ដឹងរបស់សាធារណៈជនជាទូទៅ នៅក្នុងប្រទេសជាសមាជិកទាំងបួនរួមមាន ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម អំពីប្រព័ន្ធព័ត៌មានទឹកជំនន់ និងគ្រោះរាំងស្ងួតរបស់តំបន់ និងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពាក់ព័ន្ធអំពីការប្រើប្រាស់ប្រព័ន្ធឌីជីថលតាមអ៊ីនធឺណេត ហើយកិច្ចសហប្រតិបត្តិការនេះមានរយៈពេលមួយឆ្នាំ គឺពីឆ្នាំ២០២០ដល់២០២១។

លោកស្រី សានទិ អាឡិចហ្សានឌឺរ (Shanti Alexander) អ្នកគ្រប់គ្រងកិច្ចការសហគមន៍របស់ហ្វេសបុក ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានថ្លែងថា៖ «យើងតែងតែស្វែងរកមធ្យោបាយថ្មីៗ ដើម្បីផ្តល់ការគាំទ្រដល់កិច្ចការអភិវឌ្ឍន៍នៅក្នុងតំបន់នេះ។ ជាមួយនឹងឧបករណ៍សម្បូរបែបជាច្រើនដែលជួយដល់សហគមន៍ឱ្យចេះត្រៀមខ្លួន ឆ្លើយតបនិងស្តារឡើងវិញនូវសមត្ថភាព និងដើម្បីបង្កើតភាពធន់នឹងគ្រោះមហន្តរាយ យើងសប្បាយចិត្តដែលបានរួមគ្នាជាមួយគណៈកម្មការទន្លេមេគង្គ ដើម្បីផ្តល់ព័ត៌មានពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតដែលអាចកើតមានជូនប្រជាពលរដ្ឋរាប់លាននាក់នៅក្នុងតំបន់នេះ ដើម្បីឱ្យពួកគេត្រៀមឱ្យបានកាន់តែប្រសើរសម្រាប់ប្រឈមនឹងវិបត្តិនេះ»។

យោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិស្តីពីការបាត់បង់ផ្នែកសេដ្ឋកិច្ច ភាពក្រីក្រ និងគ្រោះមហន្តរាយ នៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ គេសង្កេតឃើញថា ការបាត់បង់ផ្នែកសេដ្ឋកិច្ចដោយផ្ទាល់ពីគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ បានកើនឡើងរហូតដល់ទៅ ២៥០%។ នៅក្នុងតំបន់មេគង្គក្រោម ចន្លោះពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០១៧ ប្រទេសថៃបានរងការវាយប្រហារអាក្រក់បំផុត ដែលធ្វើឱ្យមានការខូចខាតជាទឹកប្រាក់ប្រមាណជា ៥២.៤ ពាន់លានដុល្លារអាមេរិក។

ដោយឡែក គណៈកម្មការទន្លេមេគង្គ បានឱ្យដឹងថា ខណៈដែលទឹកជំនន់ប្រចាំរដូវ បាននាំមកនូវអត្ថប្រយោជន៍ផ្សេងៗគ្នាដល់តំបន់ ការខាតបង់ប្រចាំឆ្នាំជាមធ្យមកើតចេញពីទឹកជំនន់នៅក្នុងអាងទន្លេមេគង្គក្រោម មានតម្លៃប្រមាណពី ៦០ ទៅ ៧០ លានដុល្លារអាមេរិក នេះបើគិតជារួម។ ប្រទេសកម្ពុជា និងវៀតណាម បានបាត់បង់ប្រមាណពីរភាគបី នៃការខូតខាតដោយទឹកជំនន់ប្រចាំឆ្នាំសរុបនៅក្នុងតំបន់ទន្លេមេគង្គ នេះបើគិតដោយឡែក។ ការសិក្សាជាច្រើនរបស់លេខាធិការដ្ឋានស្ថាប័ននេះនាពេលថ្មីៗកន្លងទៅ ក៏បានបង្ហាញផងដែរថា ព្រឹត្តិការណ៍ទឹកជំនន់ក្នុងតំបន់អាងទន្លេមេគង្គក្រោមបានកើនឡើង ជាញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ នៅក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ហើយនិន្នាការនេះនឹងបន្តទៅមុខទៀត។ អាងទន្លេនេះ ក៏ងាយនឹងរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុបន្ថែមទៀតផងដែរ ដែលរួមបញ្ចូលទាំងកំណើនសីតុណ្ហភាពនៃមេឃ្យានដែលបានព្យាករទុកប្រមាណ ០.៨ ដឺក្រេ នៅឆ្នាំ២០៣០។

លោកបណ្ឌិត អានុល័ក គិតិឃូន (Anoulak Kittikhoun) ប្រធានមន្ត្រីផ្នែកយុទ្ធសាស្ត្រ និងភាពជាដៃគូរបស់ លេខាធិការដ្ឋាននៃគណកម្មការទន្លេមេគង្គបានឱ្យដឹងថា "យើងឃើញពីសារៈសំខាន់ខ្លាំងបំផុតនៃការផ្តល់នូវព័ត៌មានដែលគួរឱ្យទុកចិត្ត និងទាន់ពេលវេលា ស្តីពីកម្ពស់ទឹក ដល់ប្រទេសនិងបណ្តាលសហគមន៍នានាតាមដងទន្លេមេគង្គ ដែលប្រឈមនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងការប្រែប្រួលអាកាសធាតុ ដើម្បីឱ្យពួកគាត់អាចចាត់វិធានការទាន់ពេលវេលា ក្នុងការជៀសវៀង ឬកាត់បន្ថយហានិភ័យ និងរៀបចំឆ្លើយតបប្រកបដោយប្រសិទ្ធិភាព»៕








*បុគ្គលិកបម្រើការងារក្នុងហាងកាបូប Dior ក្នុងទីក្រុងបាងកក។ **រូបភាព៖ ស៊ីអេសស៊ី***

# យុវជនអាស៊ានប្រឈមនឹងអត់ការងារធ្វើខ្ពស់អំឡុងពេលជំងឺរាតត្បាតកូវីដ១៩

*អត្ថបទ៖ អរិយបុត្រ*

ជំងឺរាតត្បាតកូវីដ១៩ បានកំពុងតែបង្កនូវការរំខានយ៉ាងខ្លាំងដល់សេដ្ឋកិច្ចនិងទីផ្សារការងារនៅទូទាំងពិភពលោក ហើយនៅតំបន់អាស៊ានក៏កំពុងតែជួបបញ្ហាដូចគ្នានេះផងដែរ។ នេះបើតាមសេចក្តីរាយការណ៍របស់សារព័ត៌មាននៅក្នុងតំបន់។

កាលពីខែមេសាកន្លងមកនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្រមានថាជំងឺរាតត្បាតនេះនឹងគំរាមកំហែងដល់ការងាររបស់កម្មករចំនួន៦៨លាននាក់នៅទូទាំងទ្វីបអាស៊ី ប្រសិនបើការផ្ទុះឡើងបានបន្តរហូតដល់ខែកញ្ញា។ ចំពោះយុវជនដែលមានអាយុពី ១៥ ទៅ ២៤ ឆ្នាំដែលបានប្រឈមមុខនឹងបញ្ហាទីផ្សារការងារដ៏តឹងតែងស្រាប់ សូម្បីតែតាំងពីមុនពេលផ្ទុះវិបត្តិជំងឺឆ្លងនេះស្រាប់ ដល់ពេលដែលផ្ទុះការរាតត្បាត វារិតតែជះឥទ្ធិពលមិនស្មើគ្នាលើការរំពឹងទុកការងាររបស់ពួកគេ។

របាយការណ៍រួមគ្នាមួយដែលបានធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីនិងអង្គការពលកម្មអន្តរជាតិ (ILO) បានបញ្ជាក់ថា វិបត្តិការងារនេះនឹងបន្តជះឥទ្ធិពលដល់យុវជនផ្សេងៗពីគ្នា អាស្រ័យលើស្ថានភាពរបស់ពួកគេនៅក្នុងទីផ្សារការងារ។ យុវជនមួយចំនួននឹងប្រឈមនឹងការលំបាកក្នុងការរក្សាតុល្យភាពការអប់រំនិងការបណ្តុះបណ្តាលជាមួយនឹងតំរូវការដើម្បីផ្គត់ផ្គង់ប្រាក់ចំណូលគ្រួសារ។ អ្នកផ្សេងទៀតនឹងប្រឈមនឹងបញ្ហានៃការស្វែងរកការងារដំបូងរបស់ពួកគេនៅក្នុងទីផ្សារការងារដែលមានតម្រូវការរារាំងខ្លាំង ហើយយុវជនជាច្រើនទៀតនឹងប្រឈមមុខនឹងការលំបាកក្នុងការផ្លាស់ប្តូរពីការងារមិនទៀងទាត់និងក្រៅផ្លូវការទៅរកការងារសមរម្យ។ ហើយចំនួនយុវជនកាន់តែច្រើនដែលមិនមានការងារធ្វើឬក្នុងការអប់រំឬបណ្តុះបណ្តាល (NEET) អាចនឹងត្រូវផ្តាច់ចេញពីទីផ្សារការងារតែម្តង។

តាមការស្ទង់មតិថ្មីៗរបស់ក្រុមការងារយុវជន នៅក្នុងការិយាល័យទីផ្សារការងារនៃអង្គការពលកម្មអន្តរជាតិបានប្រកាសថា យុវជនក្មេងខ្ចីទំនងជាជួបប្រទះនូវបញ្ហាលំបាកនៅក្នុងការស្វែងរកការងារធ្វើនៅក្នុងកម្រិត៣ដងលើសក្រុមយុវជនដែលមានអាយុ ២៥ ឆ្នាំ ឬ លើសពីនេះ ហើយភាគច្រើននៃការបាត់បង់ការងារក្នុងចំណោមយុវជន ទាំងនេះគឺដោយសារតែអាជីវកម្មឈប់ដំណើរការ ឬត្រូវបានបញ្ឈប់។ ក្រៅពីនេះយុវវ័យក្មេងៗដែលបម្រើការងារផ្នែកកត់ត្រាបញ្ជី សេវាកម្ម ការលក់ សិប្បកម្ម និងសកម្មភាពជំនួញផ្សេងៗ ក៏កំពុងតែប្រឈមមុខនឹងការបាត់បង់ការងារធ្វើជាបន្តបន្ទាប់ផងដែរ។

អង្គការពលកម្មអន្តរជាតិ បានអះអាងថា ការបិទទ្វារសង្គមនិងវិធានការណ៍គន្លាតសង្គមដើម្បីការពារការរីករាលដាលមេរោគ គឺជាបុព្វហេតុនៃការបាត់បង់ការងារធ្វើ កាន់តែខ្ពស់ក្នុងចំណោម មុខតំណែងការងារដែលមានការងារ ទាមទារការទាក់ទងអតិថិជនញឹកញាប់។ ជាអកុសល របាយការណ៍នេះមិនបានធ្វើឱ្យមានការភ្ញាក់ផ្អើលនោះទេ ខណៈដែលជំងឺរាតត្បាតបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅទូទាំងពិភពលោក។

របាយការណ៍ដដែលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការពលកម្មអន្តរជាតិ ក៏បានផ្តល់យោបល់ផងដែរថា វិធានការណ៍នៃការបិទទ្វាសង្គមឆ្លើយតបនឹងការរីករាលដាលមេរោគ បានធ្វើឱ្យមានការថយចុះដែលមិនធ្លាប់មានពីមុនមកនូវម៉ោងធ្វើការដែលប៉ះពាល់ដល់កម្មករគ្រប់វ័យ។ យោងតាមរបាយការណ៍រួមគ្នារបស់ស្ថាប័នទាំងពីរនេះ បានអះអាងថា យុវជនទំនងជាប្រឈមនឹងការបាត់បង់ការងារទាំងស្រុងជាងការបញ្ឈប់ការងារបណ្តោះអាសន្ន។ ស្ថាប័នទាំងពីរ បានបន្តថា ឱកាសទទួលបានការងាររបស់យុវជន ទំនងជាពិបាក។ បញ្ហានេះត្រូវបានគេមើលឃើញនៅក្នុងប្រទេសថៃដែលការខាតបង់ម៉ោងធ្វើការគឺស្ថិតនៅលើកំរិត ៨ ភាគរយសំរាប់យុវជននិង ៥ ភាគរយសំរាប់មនុស្សពេញវ័យ។

នៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀតដូចជាករណី ប្រទេសម៉ាឡេស៊ី ត្រូវបានគេរាយការណ៍ថា ការបាត់បង់ការងារនៅក្នុងប្រទេសបានកើនឡើងលើសពី៤ ភាគរយ។ ស្ថានភាពនៃអាជីវកម្មនៅក្នុងប្រទេសនេះ មានការធ្លាក់ចុះប្រមាណជា ៣៧ ភាគរយ ដែលនាំឱ្យអត្រាគ្មានការងារធ្វើនៅក្នុងប្រទេសត្រូវបានគេព្យាករណ៍ថា នឹងអាក្រក់ជាងកាលពីវិបត្តិហិរញ្ញវត្ថុកាលពីឆ្នាំ ១៩៩៧ ហើយអត្រាគ្មានការងារធ្វើរបស់យុវជនភាគច្រើននៅថេរដដែលពី ៨ ទៅ ១១ ភាគរយ តែទោះយ៉ាងណា ពួកគេជាប្រជាជនដែលងាយរងគ្រោះបំផុត។ ចំណែកឯប្រទេសជិតខាងឥណ្ឌូនេស៊ីវិញបានរាយការណ៍ថាអត្រាគ្មានការងារធ្វើរបស់ប្រទេសនេះអាចឈានដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍ ពោលគឺប្រមាណជា ជាង ៩ ភាគរយ ដែលមានប្រជាពលរដ្ឋប្រមាណជា ១៣ លាននាក់៕



*កម្មករសំណង់កំពុងធ្វើដំណើរចាកចេញពីការដ្ឋានមួយ។ **បរទេស***

## ភោជនីយដ្ឋាននិងតូបលក់ដូរជាង១០០នៅមុខប្រាសាទអង្គរវត្តត្រូវបានរុះរើ



*អត្ថបទ៖ អមរិន្ទ ដានុត*

មន្ត្រីនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថាសំណង់ភោជនីយដ្ឋាន តូបលក់ដូរ អាគាររដ្ឋសរុបប្រមាណ ១៥០ខ្នងត្រូវបានរុះរើរួចរាល់ទាំងស្រុងនៅមុខបរិវេណខាងលិចប្រាសាទអង្គរវត្ត ហើយអាជ្ញាធរគ្រោងនឹងកែលំអរទីតាំងនេះទៅជាផ្លូវថ្មើរជើង។

សំណង់នៃ ភោជនីយដ្ឋាន អាគាររដ្ឋ តូបលក់ដូរវត្ថុអនុស្សាវរីយ៍ លក់ម្ហូបអាហារ សម្លៀកបំពាក់ និងគ្រឿងភេសជ្ជៈផ្សេងៗទាំងនេះ ត្រូវបានរុះរើរួចរាល់ទាំងស្រុងនាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ពីបរិវេណខាងលិចប្រាសាទអង្គរវត្តទាំងផ្នែកខាងត្បូងផ្លូវចូល និងមាត់ត្រពាំងសេះ។

កិច្ចការនេះ បានដំណើរការកាលពីដើមឆ្នាំ២០២០ ដោយមានការស្ម័គ្រចិត្តនិងឆន្ទៈរួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍របស់ម្ចាស់សំណង់អាជីវកម្ម ក្រោមកិច្ចសម្របសម្រួលរបស់អាជ្ញាធរជាតិអប្សរា ដើម្បីរួមគ្នាលើកតម្លៃរមណីយដ្ឋានអង្គរឱ្យសមជាបេតិកភណ្ឌពិភពលោក។

យោងតាមអាជ្ញាធរជាតិអប្សរា បានលើកឡើងថា ចំពោះអាជីវករដែលបានរុះរើតូបខ្លួនរួចរាល់ហើយ ចាប់ផ្តើមដំណើរការលក់ដូរឡើងវិញចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងបរិវេណនៃបណ្តុំអាគារទីលានបដិសណ្ឋារកិច្ច ដែលជាសំណង់ថ្មី ស្អាត ងាយស្រួល ហើយមានអនាម័យជាងមុន។

តាមគម្រោងរបស់អាជ្ញាធរជាតិអប្សរា នឹងកែប្រែតំបន់អតីតសំណង់ដែលរុះរើនេះហើយ រៀបចំឱ្យក្លាយជាផ្លូវថ្មើរជើង សួនឈើប្រណីត ឈើផ្កាព្រៃ និងរុក្ខជាតិលម្អដែលមានក្លិនពិដោរក្រអូបៗផង ជាការកែប្រែទីនេះឱ្យមានភាពស្រស់បំព្រង មានពណ៌បៃតង បរិយាកាសល្អ និងសណ្តាប់ធ្នាប់កាន់តែប្រសើរឡើង៕

# កម្ពុជាប្រកាសគាំទ្រសំណើរបស់ចិនក្នុងវិស័យអាទិភាព ចំនួន៤ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់មេគង្គ–ឡានឆាង

*អត្ថបទ៖ អរិយបុត្រ*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានាកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី៣ ដែលត្រូវបានរៀបចំឡើងកាលពីខែសីហាតាមរយៈប្រព័ន្ធវីដេអូដោយមានប្រទេសឡាវនិងប្រទេសចិនជាសហប្រធាន បានប្រកាសគាំទ្រនូវចក្ខុវិស័យការងាររបស់លោកនាយករដ្ឋមន្ត្រីចិន លី កឺឈាង (Li Keqiang) ក្នុងវិស័យអាទិភាពចំនួន ៤ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចមេគង្គ-ឡានឆាង។






*សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានាកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាងលើកទី៣។ **រូបភាព៖ ហ្វេសប៊ុក***

នៅគ្រាដែលប្រទេសនីមួយៗកំពុងជួបវិបត្តិសេដ្ឋកិច្ចដោយសារតែកូវីដ១៩នោះ ប្រមុខរដ្ឋាភិបាលកម្ពុជាបានប្រកាសគាំទ្រសំណើរបស់ចិនដែលអះអាងថាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចមេគង្គ ឡានឆាង ដែលរួមមានទី១ ការតភ្ជាប់តាមរយៈខ្សែក្រវ៉ាត់អភិវឌ្ឍន៍សេដ្ឋកិច្ច មេគង្គ -ឡានឆាងនិងការជំរុញច្រករបៀងពាណិជ្ជកម្មតាមផ្លូវគោក និង តាមសមុទ្រ, ទី២ កិច្ចសហការធនធានទឹក, ទី៣ការអភិវឌ្ឍដោយចេរភាពក្នុងវិស័យកសិកម្មនិងបរិស្ថាន និងទី៤ ការលើកកម្ពស់សុខភាពសាធារណៈតាមរយៈការបង្កើតសហគមន៍សុខភាពសាធារណៈមេគង្គ-ឡានឆាង។

លោក កៅ គឹមហួន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ឱ្យដឹងថា កិច្ចប្រជុំកំពូលសហប្រតិបត្តិការមេគង្គឡានឆាងលើកទី៣នេះ បានអនុម័តនូវឯកសារសំខាន់ចំនួនពីរ។ ទីមួយ. សេចក្តីថ្លែងការណ៍ទីក្រុងវៀងចន្ទន៍ និង ទីពីរសេចក្តីថ្លែងការណ៍របស់សហប្រធាននៃកិច្ចប្រជុំមេគង្គឡានឆាងលើកទី៣។

បើតាមលោក កៅ គឹមហួន សេចក្តីថ្លែងការណ៍នេះបានផ្តោតជាសំខាន់ទៅលើការធ្វើយ៉ាងណាជំរុញឱ្យកិច្ចធ្វើសហកម្មរវាងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាងនិង ការជំរុញការតភ្ជាប់ច្រករបៀងពាណិជ្ជកម្មអន្តរជាតិថ្មីតាមផ្លូវគោកនិងសមុទ្រ។

នៅក្នុងកិច្ចប្រជុំនោះមេដឹកនាំប្រទេសទាំង៦ បានជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅទៅលើការប្រើប្រាស់ធនធានទឹកហើយនាយករដ្ឋមន្ត្រីចិនបានប្រកាស ថាចិននឹងចែករំលែកនូវការប្រើប្រាស់ទិន្នន័យជុំវិញកម្រិតទឹកនិងការប្រើប្រាស់ទឹកពេញមួយឆ្នាំតែម្តងថាតើធនធានទឹកនោះយើងត្រូវធ្វើបែបណាទាំងពេលមានទឹកជំនន់និងពេលរាំងស្ងួតផង។ ចំណុចមួយទៀតដែលសំខាន់ហើយត្រូវបានលើកមកពិភាក្សាផងដែរនោះគឺការឆ្លើយតបទៅនឹងជំងឺរាតត្បាតជាសកលកូវីដ១៩ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការនេះនាយករដ្ឋមន្ត្រីចិន លោក លី កឺឈាង បានប្រកាសថានឹងត្រៀមរ៉ាក់សាំងផ្តល់ជូនដល់ប្រទេសក្នុងក្របខណ្ឌតំបន់មេគង្គឡានឆាងជាអាទិភាពដែលមានប្រទេស ៥ ដែលរួមមានទាំងកម្ពុជាផងដែរ។

> គម្រោងទាំង៥៥បានអនុវត្តន៍ទៅលើវិស័យមួយចំនួនដូចជាកសិកម្ម ទេសចរណ៍ បច្ចេកវិទ្យាព័ត៌មាន អប់រំ ធនធានទឹក អភិវឌ្ឍន៍ជនបទ ការតភ្ជាប់អាកាសចរណ៍ស៊ីវិលនិងការផ្លាស់ប្តូរទៅលើវប្បធម៌ និងសាសនា រវាងកម្ពុជានិងបណ្តាប្រទេសនៅក្នុងក្របខ័ណ្ឌមេគង្គឡានឆាង

លោកនាយករដ្ឋមន្ត្រីចិនក៏បញ្ជាក់ផងដែរគឺការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ដែលនៅក្នុងន័យនេះនាយករដ្ឋមន្ត្រីចិនបានប្រកាសថានឹងជំរុញការនាំចូលផលិតផលកសិកម្មពីប្រទេសនៅក្នុងក្របខណ្ឌមេគង្គឡានឆាង។ កិច្ចប្រជុំក៏បានពិភាក្សាផងដែរទៅលើការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀត។ លោកនាយករដ្ឋមន្ត្រីចិនក៏បានប្រកាសថានឹងបង្កើតមូលនិធិសុខភាពសាធារណៈមួយ ដើម្បីជួយគាំទ្រដល់វិស័យសុខភាពសាធារណៈដល់ប្រទេសទាំង៥ នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង។

ក្នុងឆ្នាំ២០១៩ កន្លងទៅនេះបើពិនិត្យមើល ទៅលើទំហំពាណិជ្ជកម្មរវាងប្រទេស ៥ ជាមួយនឹងប្រទេសចិន គឺកើនឡើងចំនួន ២៨ ភាគរយដែលមានទឹកប្រាក់ស្មើនឹង២៨៥,៨ ពាន់លានដុល្លារអាមេរិក។

គួររំលឹកជូនថា កាលពីកិច្ចប្រជុំកំពូលលើកទី១ នៅឆ្នាំ២០១៦ ក្រោមមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ប្រទេសចិនបានផ្តល់ជំនួយហិរញ្ញវត្ថុចំនួន៣០០ លានដុល្លារដើម្បីគាំទ្រដល់គម្រោងខ្នាតតូចនិងមធ្យមនានា នៅប្រទេសតាមដងទន្លេមេគង្គទាំង៦ សម្រាប់រយៈពេល៥ឆ្នាំចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ ចំពោះកម្ពុជាក្នុងរយៈពេល៣ឆ្នាំជាប់គ្នាមូលនិធិមេគង្គ-ឡានឆាងបានផ្តល់ជំនួយលើគម្រោងចំនួន ៥៥ គម្រោង ដែលគិតជាទឹកប្រាក់ជាង ២១លានដុល្លារ។

លោក កៅ គឹមហួន បានឱ្យដឹងថា គម្រោងទាំង៥៥បានអនុវត្តន៍ទៅលើវិស័យមួយចំនួនដូចជាកសិកម្ម ទេសចរណ៍ បច្ចេកវិទ្យាព័ត៌មាន អប់រំ ធនធានទឹក អភិវឌ្ឍន៍ជនបទ ការតភ្ជាប់អាកាសចរណ៍ស៊ីវិលនិងការផ្លាស់ប្តូរទៅលើវប្បធម៌ និងសាសនារវាងកម្ពុជា និងបណ្តាប្រទេសនៅក្នុងក្របខ័ណ្ឌមេគង្គឡានឆាង៕

# ភ្ញៀវទេសចរចូលទស្សនារមណីយដ្ឋានអង្គរ ទទួលចំណូលជាង១៨លានដុល្លារ ក្នុងរយៈពេល០៨ខែឆ្នាំនេះ

*អត្ថបទ៖ ផល សុផានិត*

នៅរយៈពេល០៨ខែ ឆ្នាំ២០២០នេះ មានភ្ញៀវទេសចរបរទេស៣៩៣,២៩៣នាក់ បានទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដោយទទួលបានចំណូលសរុបប្រមាណ ១៨,៣៣២,០១១ដុល្លារអាមេរិក។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់គ្រឹះស្ថានអង្គរ ដែលទទួលបាននៅព្រឹកនេះ។

សេចក្តីប្រកាសព័ត៌មានបានឱ្យដឹងថា ចំនួនអ្នកទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរនេះ មានការថយជាង ៧៣ភាគរយ បើធៀបនឹងឆ្នាំ២០១៩ កន្លងទៅ។

សេចក្តីប្រកាសព័ត៌មាននេះបានបង្ហាញដែរថា នៅក្នុងខែសីហា ឆ្នាំ២០២០នេះ មានអ្នកទិញបណ្ណចូលទស្សនាប្រមាណ ៣,៦៦៣នាក់ រកចំណូលបាន ១៦១,០២១ដុល្លារអាមេរិក។

គ្រឹះស្ថានអង្គរក៏បានឱ្យដឹងផងដែរថា រយៈពេល ០៨ខែឆ្នាំនេះ ចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គ បានឧបត្ថម្ភចូលមូលនិធិមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា បានចំនួនសរុប ៧៨៦,៥៨៦ ដុល្លារអាមេរិក។

ដោយឡែកភ្ញៀវទេសចរណ៍ទិញប័ណ្ណចូលទស្សនា ប្រាសាទកោះកែរ ស្ថិតក្នុងខេត្តព្រះវិហារ មានចំនួន ៨,៨១៧នាក់ និងទទួលបានចំណូលសរុប ៨៨,១៧០ ដុល្លារអាមេរិក។

ចំណែកក្នុងខែសីហាកន្លងទៅ ភ្ញៀវទេសចរអន្តរជាតិ បានទិញប័ណ្ណចូលទស្សនា ប្រាសាទកោះកែរ មានចំនួនសរុប ១៦១នាក់ និងទទួលបានចំណូលសរុប ១, ៦១០ ដុល្លារអាមេរិក៕



*ភ្ញៀវទេសចរមកទស្សនាប្រាសាទអង្គរវត្ត។ **រូបភាព៖ ស៊ីអេសស៊ី***








# មេដឹកនាំកម្ពុជាផ្តល់ទស្សនទានសំខាន់ៗទៅកាន់កិច្ចប្រជុំកំពូលឆ្នាំ២០២០នៃវេទិកាសេដ្ឋកិច្ចពិភពលោក

*អត្ថបទ៖ អរិយបុត្រ*

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងនូវទស្សនទានមួយចំនួនទៅកាន់កិច្ចប្រជុំកំពូល ឆ្នាំ ២០២០ នៃវេទិកាសេដ្ឋកិច្ចពិភពលោក ស្តីពីផលប៉ះពាល់លើការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមប្រធានបទ«ការកសាងឆ្ពោះទៅមុខប្រកបដោយចីរភាពនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន»។

ការលើកឡើងនូវប្រធានបទនេះ គឺដើម្បីឱ្យប្រទេសកំពុងអភិវឌ្ឍន៍អាចបន្តកសាងអនាគត ប្រកបដោយចីរភាព ដោយកិច្ចប្រជុំនេះធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូដែលបានធ្វើឡើងនៅវិមានសន្តិភាពនារសៀលថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២០។

ថ្លែងទៅកាន់កិច្ចប្រជុំកំពូលនេះសម្តេចនាយករដ្ឋមន្ត្រីបានលើកឡើងថា សម្តេចពិតជារីករាយដែលវេទិកាសេដ្ឋកិច្ច ពិភពលោករៀបចំឡើងដើម្បីចែករំលែកបទពិសោធន៍ និង វិធានការសំខាន់ៗក្នុងគោលបំណងសម្រេចឱ្យបាននូវរបៀបវារៈ ឆ្នាំ២០៣០៖ ការអភិវឌ្ឍ ប្រកបដោយចីរភាពនៅក្នុងបរិការណ៍មួយដែលប្រទេសទាំងអស់កំពុងខិតខំ ប្រឹងប្រែងស្តារសេដ្ឋកិច្ចរបស់ខ្លួន ឡើងវិញ ក្រោយពីវិបត្តិនៃជំងឺកូវីដ១៩។

សម្តេចបានបន្តថា ពិតណាស់ថា ការរីករាលដាលនៃជំងឺកូវីដ១៩បាននិងកំពុងបង្កើនការព្រួយបារម្ភនិងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើងក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍសង្គមសេដ្ឋកិច្ចក្នុងតំបន់និងសកលលោក។

សម្តេចហ៊ុន សែន បានមានប្រសាសន៍ថា៖ «សភាពការណ៍នេះបានធ្វើឱ្យការប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្លាយជាបញ្ហារួមរបស់យើងទាំងអស់គ្នា ទោះបីជា ប្រទេសយើងនីមួយៗកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលផ្សេងៗគ្នាក៏ដោយ នៅក្នុងបរិការណ៍នេះ ខ្ញុំសូមលើកឡើងនូវគំនិតមួយចំនួន ដើម្បីឱ្យប្រទេសកំពុងអភិវឌ្ឍន៍អាចបន្តកសាងអនាគតប្រកបដោយចីរភាព»។

សម្តេចបានលើកឡើងទៅកាន់កិច្ចប្រជុំកំពូលឆ្នាំ ២០២០ នៃវេទិកាសេដ្ឋកិច្ចពិភពលោកថា ការកាត់បន្ថយនូវផលប៉ះពាល់និងធានាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជា ជួយរក្សាលំនឹងផលិតកម្ម កិច្ចដំណើរការនៃធុរកិច្ចនិងការវិនិយោគនានាគឺជាការងារដ៏សំខាន់ដែលរដ្ឋាភិបាលនីមួយៗត្រូវតែប្រឹងប្រែងអនុវត្តឱ្យបានជាអតិបរមា។

ដើម្បីគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការមុតស្រួចនិងបន្ទាន់ចំនួន៥ជុំ រួចមកហើយ ហើយយើងកំពុងតែបន្តតាមដានសភាពការណ៍ប្រកបដោយការយកចិត្តទុកដាក់ ខ្ពស់ដោយត្រៀមដាក់ចេញនូវវិធានការដាក់ស្តែងថែមទៀតតាមការចាំបាច់។

ទស្សនវិជ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា ប្រែក្លាយការគំរាមកំហែងពីជំងឺកូវីដ១៩ ទៅជាឱកាស សម្រាប់ការកែទម្រង់នៅក្នុងប្រទេសនីមួយៗ។ ជំងឺកូវីដ១៩ បាននាំមកនូវផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុសាធារណៈ ជាពិសេសចំណូលរដ្ឋ។ ការបាត់បង់ចំណូលបានទាមទារឱ្យរដ្ឋាភិបាលដាក់ចេញយន្តការថ្មីៗ ដើម្បីកៀរគរធនធាន ហិរញ្ញវត្ថុដែលអាចយកមកប្រើប្រាស់ក្នុងការអភិវឌ្ឍនាពេលអនាគត។

សម្តេចហ៊ុន សែន បានបញ្ជាក់ថា៖ «ដើម្បីសម្រេចបានគោលដៅនេះ ខ្ញុំយល់ឃើញថា ការចាប់ដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ជាយន្តការស្នូលមួយមិនអាចខ្វះបាន ដែលនឹងជួយសម្រួលដោះស្រាយការលំបាក ផ្នែកហិរញ្ញវត្ថុរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនៅក្នុងអំឡុង និងក្រោយវិបត្តិនេះ»។

នៅក្នុងបរិការណ៍ដ៏លំបាកនេះ ដើម្បីធានាជំរុញការកែទម្រង់របស់ខ្លួនទៅមុខ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវការចាំបាច់នូវកិច្ចសហការជាសកល ពោលគឺ ការរក្សានូវភាពជាដៃគូទាំងទ្វេភាគី និង ពហុភាគីសំដៅធានាបាននូវបរិស្ថាននៃការអភិវឌ្ឍសន្តិភាពនិងស្ថិរភាពក្នុងតំបន់និងពិភពលោក។ សម្តេចបានថ្លែងថា៖ «យើងត្រូវតែធានាឱ្យបានថា យន្តការកិច្ចសហប្រតិបត្តិការរបស់យើងនៅតែរក្សាបាននូវស្មារតីបើកចំហរនិងការគាំទ្រប្រព័ន្ធពាណិជ្ជកម្ម ពហុភាគី ជាពិសេស ការពន្លឿនការតភ្ជាប់រវាងសង្គមនិងសេដ្ឋកិច្ចរបស់យើងសម្រាប់ជំរុញរបៀបវារៈនៃការអភិវឌ្ឍរបស់ប្រទេស នីមួយៗប្រកបដោយចីរភាពនិងបរិយាប័ន»។




*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ **ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

សម្តេចបញ្ជាក់ថា ត្រូវនាំគ្នាគិតគូរជាយុទ្ធសាស្ត្រអំពីកិច្ចការស្តារនិងជំរុញការងើបឡើងវិញនូវ កំណើនសេដ្ឋកិច្ចបន្ទាប់ពីវិបត្តិកូវីដ១៩ ត្រូវបានបញ្ចប់តាមរយៈការពន្លឿននូវការអនុវត្តផែនការនិងយន្តការនានាដែលមានស្រាប់និងដែលត្រូវបានរៀបចំបន្ថែមឱ្យបានលឿននិងឱ្យមានប្រសិទ្ធភាពខ្ពស់។

សម្តេចថា ត្រូវតែបន្តធានាឱ្យបាននូវនិរន្តភាពនៃការផ្តល់ជំនួយអន្តរជាតិ ជាពិសេស ជំនួយផ្នែកហិរញ្ញវត្ថុចំពោះប្រទេសកំពុងអភិវឌ្ឍដើម្បីបន្តជំរុញចលនការនៃការងារកែទម្រង់ ប្រកបដោយចីរភាពដែលជារបៀបវារៈឆ្នាំ២០៣០ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងបរិការណ៍នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សម្តេចបានវាយតម្លៃខ្ពស់និងថ្លែងអំណរគុណ ដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ចំពោះការផ្តល់កិច្ចសហការប្រកបដោយបុរេសកម្មនិងការផ្តល់នូវជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសដែលបានជួយឱ្យកម្ពុជាអាចគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩បានយ៉ាងល្អប្រសើរ៕

# ករណីឃាតកម្ម–មនុស្សឃាតបានកើតមានឡើង ធ្វើឱ្យសីលធម៌សង្គមមានការធ្លាក់ចុះគួរឱ្យបារម្ភ និងការចាប់ខ្លួនយុវជនដែលតវ៉ាទាមទាររកយុត្តិធម៌សង្គម

*អត្ថបទ៖ អមរិន្ទ ដានុត*

អំពើឃាតកម្មដ៏សាហាវៗបានកើតឡើងផ្ទួនៗគ្នាមួយរយៈពេលចុងក្រោយនេះនៅតាមបណ្តាខេត្តមួយចំនួននិងរាជធានីភ្នំពេញ ដែលជាបេះដូងនិងជាមជ្ឈមណ្ឌលនយោបាយ សង្គម វប្បធម៌ ពាណិជ្ជកម្ម និងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។

ករណីឃាតកម្មធំៗមួយចំនួនដែលបានកើតឡើង និងគួរឱ្យបារម្ភមានដូចជា ករណីប្តីយកពូថៅកាប់សម្លាប់ប្រពន្ធខ្លួនឯងចំបំពង់ក រួចជនសង្ស័យបានចងកសម្លាប់ខ្លួននៅចម្រឹងបង្អួចផ្ទះ។ ករណីនេះកើតឡើងនៅដើមខែកញ្ញា ឆ្នាំ២០២០ នៅក្នុងភូមិត្រពាំងរំពាក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ជនរងគ្រោះជាប្រពន្ធបានរងរបួសធ្ងន់ ចំណែកប្តីបានស្លាប់។

ករណីមួយផ្សេងទៀត បានកើតឡើងកាលពីដើមខែកញ្ញាដែរ ដោយស្ត្រីម្នាក់ត្រូវបានជនសង្ស័យចាក់បណ្តាលឱ្យស្លាប់ភ្លាមៗនៅកន្លែងកើតហេតុរួច ហើយជនសង្ស័យបានចាក់ខ្លួនឯងបណ្តាលឱ្យរបួសធ្ងន់ ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ចំណែកឯមួយករណីទៀតដែលបានកើតឡើងនៅថ្ងៃដូចគ្នានោះ ដែលហេតុការណ៍បានកើតឡើងក្នុងភូមិព្រៃរកា ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល ដោយជនសង្ស័យម្នាក់បានយកកាំបិតចុងស្រួចចាក់ទៅលើប្រពន្ធជាច្រើនកាំបិតរហូតស្លាប់ភ្លាមៗ នៅកន្លែងកើតហេតុ រួចអាករខ្លួនឯងតាមក្រោយ តែមិនស្លាប់ដោយរងរបួសធ្ងន់។ ករណីនេះកើតឡើងដោយសារជនរងគ្រោះខឹងប្រពន្ធសុំជានាគ្នាវិញ តែប្រពន្ធមិនព្រម ក្រោយពីលែងលះគ្នាបានមួយសប្តាហ៍។

ករណីឃាតកម្មដែលសាហាវព្រៃផ្សៃជាងគេមួយទៀតនោះគឺ ករណីឪពុកសម្លាប់កូនស្រីបីនាក់ក្នុងផ្ទះ ហើយបានចងកសម្លាប់ខ្លួនតាមក្រោយ ដោយគ្រាន់តែមានទំនាស់នៅក្នុងគ្រួសារប៉ុណ្ណោះ។

បន្ទាប់ពីករណីឃាតកម្មកើតមានឡើងផ្ទួនៗគ្នាមក នៅលើបណ្តាញសង្គមរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គបានសម្តែងនូវព្រះរាជហរទ័យបារម្ភពីការធ្លាក់ចុះនូវសីលធម៌ គុណធម៌ និងសេចក្តីថ្លៃថ្នូរ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរ និងនិរន្តរភាព នៃវប្បធម៌ និងចីរភាពរបស់សង្គម។

ព្រះបរមរាជឱង្ការដ៏ខ្ពង់ខ្ពស់បំផុត មានអត្ថន័យទាំងស្រុងដូចតទៅ៖ «បច្ចុប្បន្ននេះ សាកលលោកយើង កំពុងស្ថិតនៅក្នុងដំណាក់កាល នៃការរីកចម្រើន និងជឿនលឿន ដោយមានជំនាញខាងវិទ្យាសាស្ត្រ និងសម្ភារៈ ដែលមិនធ្លាប់មានពីមុនមក។ ប៉ុន្តែ ទន្ទឹមនឹងការរីកចម្រើនខាងលើនេះ សីលធម៌ និងអភិសមាចារ (មារយាទដ៏ល្អព្រៃលែង ឬជ្រះថ្លា) ក្នុងជីវភាពសង្គម ក៏មានការស្រុតចុះ គួរឱ្យព្រួយបារម្ភណាស់ដែរ។ ភាពអន់ថយ នៃសីលធម៌ និងគុណធម៌សង្គម នាំឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរ និងនិរន្តរភាព នៃវប្បធម៌ និងចីរភាពរបស់សង្គមនិយម ទៅអនាគត»។



*ជនសង្ស័យដែលបានរំលោភសម្លាប់ ខណៈជនរងគ្រោះស្ថិតក្នុងបន្ទប់ម្នាក់ឯង។* ***រូបភាព៖ នគរបាលជាតិ***





*(ឆ្វេង) សពឪពុកដែលបានសម្លាប់កូនស្រីខ្លួនឯងទាំង៣នាក់ដោយសារមានជំលោះក្នុងគ្រួសារ, (ស្តាំ) សពស្ត្រីជាប្រពន្ធដែលត្រូវបានប្តីចាក់ស្លាប់នៅស្រុកអង្គស្នួល។* ***នគរបាលជាតិ***

> ភាពអន់ថយ នៃសីលធម៌ និងគុណធម៌សង្គម នាំឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរ និងនិរន្តរភាព នៃវប្បធម៌ និងចីរភាពរបស់សង្គមនិយម ទៅអនាគត

ជាការកត់សម្គាល់ ការសម្តែងនូវក្តីបារម្ភ ក្នុងព្រះរាជហរទ័យរបស់ព្រះមហាក្សត្រ បានធ្វើឡើងបន្ទាប់ពីប៉ុន្មានថ្ងៃដែលគេសង្កេតឃើញការកាប់ចាក់ សម្លាប់មនុស្ស និងអំពើឃាតកម្មផ្សេងៗ បានកើតឡើងជាបន្តបន្ទាប់ជាប់ៗគ្នា ដែលភាគច្រើននៃអំពើល្មើសទាំងនេះ ផ្តើមចេញពីការប្រើប្រាស់គ្រឿងញៀន និងភាពមិនចុះសម្រុង ដោយសារករណីផ្សេងៗទៀត ជាច្រើន។

ជាមួយគ្នានេះដែរ អ្នកជំនាញផ្នែកទស្សនវិជ្ជា និងជាប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជាលោក ប៉ា ចន្ទរឿន បានលើកឡើងថា អំពើឃាតកម្មដែលបានកើតមានឡើងនេះបានឆ្លុះបញ្ចាំងពីទិដ្ឋភាពរួមមួយទាក់ទងទៅនឹងសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋខ្មែរមួយចំនួន ជាពិសេសឃាតករនោះបានបាត់បង់នូវការគិតពិចារណាលើជីវិតរបស់ជនរងគ្រោះ។

លោកបានបន្តថា ឃាតករមើលឃើញថាការសម្លាប់នេះជាជម្រើសនៃជីវិតរបស់គាត់ និងរួមផ្សំជាមួយនឹងកត្តាជាច្រើនដូចជា ស្ថានភាពសេដ្ឋកិច្ចក្នុងសម័យកូវីដ១៩នេះ ឥទ្ធិពលនៃគ្រឿងញៀន គ្រឿងស្រវឹង និងការមិនចេះដោះស្រាយបញ្ហាបែបវិជ្ជមាន សន្តិភាពនិយមជាដើម។

លោក ប៉ា ចន្ទរឿនបានថ្លែងថា៖ «ប្រជាពលរដ្ឋរបស់យើងត្រូវទទួលស្គាល់ថា ក្នុងស្ថានភាពបែបនេះ សុខភាពផ្លូវចិត្តយើងអាចងាយនឹងរងប៉ះទង្គិច ហើយនៅពេលដែលវាប៉ះហើយគឺត្រូវទទួលស្គាល់ កុំឱ្យមានការប៉ះទង្គិចទៀត ដែលនាំឱ្យកើតជាជម្លោះ ឬអាចឈានទៅដល់ការបង្ករបួសស្នាមឬសម្លាប់មនុស្សជាដើម»។

លោកថា ស្ថាប័នដែលពាក់ព័ន្ធរួមមាន ស្ថាប័នអប់រំ ខាងសាសនា សាលារៀន រួមទាំងប្រព័ន្ធផ្សព្វផ្សាយផងដែរ គួរតែនាំគ្នាលើកកំពស់ការចាប់អារម្មណ៍ ការយល់ដឹងពីភាពផុយស្រួយនិងការងាយប៉ះពាល់អារម្មណ៍និងសុខភាពផ្លូវចិត្តក្នុងដំណាក់កាលលំបាកលំបិននេះ។






*(ឆ្វេង) លោក រ៉ុង ឈុន ប្រធានសហភាពសជីពកម្ពុជា (កណ្តាល) អ្នកនាង ឈឿន ដារ៉ាវី និងយុវជន ហ៊ុន វណ្ណៈ សមាជិកយុវជនខ្មែរថាវរៈ (ស្តាំ) លោក សួង សុភ័ណ្ឌ ប្រធានគណបក្សខ្មែរឈ្នះ ដែលអាជ្ញាធរចាប់ខ្លួន។* ***រូបភាព៖ ហ្វេសប៊ុក***

## ករណីចាប់និងឃុំខ្លួនយុវជននិងអ្នកតវ៉ា

កាលពីខែសីហា ឆ្នាំ២០២០កន្លងមក មនុស្សចំនួន៦នាក់ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពីបទញុះញង់ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ពាក់ព័ន្ធនឹងការអំពាវនាវសុំឱ្យមានការដោះលែង លោក រ៉ុង ឈុន តំណាងក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា និងជាប្រធានសហភាពសហជីពកម្ពុជាដែលត្រូវបានចាប់ខ្លួនកាលពីចុងខែកក្កដា ដែលរួមមាន លោក ជុំ ពុទ្ធី លោក ឈូ ផេង កញ្ញា ស កន្និកា អ្នកនាង ឈឿន ដារ៉ាវី និងលោក ហ៊ុន វណ្ណៈ និងប្រធានគណបក្សខ្មែរឈ្នះ លោក សួង សុភ័ណ្ឌ។

យុវជនជាច្រើនរូបទៀតត្រូវបានចាប់និងទទួលរងនូវការគំរាមកំហែងជាបន្តបន្ទាប់ ដោយសារពួកគេមានគម្រោងនិងបានប្រមូលផ្តុំគ្នាដើម្បីទាមទាររកយុត្តិធម៌សង្គម។ ការចាប់ខ្លួនជាបន្តនោះរួមមាននាដើមខែកញ្ញា សកម្មជនបរិស្ថានជាយុវជនចំនួន៣នាក់ ត្រូវបាននគរបាលចាប់ខ្លួន នៅពេលដែលអ្នកទាំងបី គ្រោងនឹងរៀបចំយុទ្ធនាការមួយ ដែលយុវនារីម្នាក់ក្នុងចំណោមអ្នកទាំងបី នឹងដើរចេញពីវត្តភ្នំឆ្ពោះទៅកាន់គេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រីក្បែរវិមានឯករាជ្យ ដើម្បីផ្សព្វផ្សាយអំពីបញ្ហានៃការចាក់ដីលុបបឹងតាមោក ដែលនៅភាគខាងជើងរាជធានី។ យុវជន/នារីទាំងបីរួមមាន កញ្ញា ឡុង គន្ធា កញ្ញា ភួង កែវរស្មី និងលោក ថុន រដ្ឋា។ កាលពីថ្ងៃអាទិត្យ ទី៦ ខែកញ្ញា អ្នកទាំងបី ត្រូវបានតុលាការចោទប្រកាន់ពីបទ ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬញុះញង់ឱ្យមានភាពវឹកវរដល់សង្គម យោងតាមមាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ អ្នកទាំងបី ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការចាប់ពីពេលនោះមក។ ប្រសិនបើតុលាការផ្តន្ទាទោសដោយយោងតាមបទល្មើសខាងលើនេះ អ្នកទាំងបី អាចប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់ ២ឆ្នាំ។ ក្នុងចំណោមអ្នកទាំងបី កញ្ញា ភួង កែវរស្មី ទើបតែមានអាយុ ១៩ឆ្នាំ ប៉ុណ្ណោះ។

បន្តមកទៀតមាន សមាជិកក្រុមយុវជនខ្មែរថាវរៈ លោក ថា ឡាវី ត្រូវបានអាជ្ញាធរចាប់ខ្លួន នៅពេលដែលលោកបំរុងចេញពីរ៉ឺម៉កកង់បីដើរទៅកាន់ទីលានប្រជាធិបតេយ្យ ដើម្បីចូលរួមតវ៉ាដោយអហិង្សាអំពាវនាវសូមឱ្យមានការដោះលែងមេដឹកនាំសហជីព លោក រ៉ុង ឈុន។ សមាជិកក្រុមយុវជន ខ្មែរថាវៈ ម្នាក់ទៀត កញ្ញា អេង ម៉ាឡៃ ត្រូវបាននគរបាលតាមដានក្រោយពីចូលរួមតវ៉ាអហិង្សា ហើយត្រូវបានចាប់ខ្លួនក្រោយពេលដែលកញ្ញាចាកចេញពីការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស (UNOHCHR)។

លើសពីនេះ ព្រះសង្ឃជាសកម្មជនយុវជន ព្រះនាម កើត សារាយ និងអនុប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញាវន្តខ្មែរ លោក មាន ព្រហ្មមុនី ត្រូវបាននគរបាលចាប់ខ្លួន/ព្រះកាយ ពាក់ព័ន្ធនឹងគម្រោងប្រមូលផ្តុំគ្នាតវ៉ាអហិង្សានៅទីលានប្រជាធិបតេយ្យ ដើម្បីអំពាវនាវសុំឱ្យមានការដោះលែងប្រធានសហជីព លោក រ៉ុង ឈុន ប្រធានគណបក្សខ្មែរឈ្នះ លោក សួង សុភ័ណ្ឌ និងសមាជិកក្រុមយុវជនខ្មែរថាវរៈ លោក ហ៊ុន វណ្ណៈ និងអ្នកនាង ឈឿន ដារ៉ាវី។ ព្រះតេជគុណ កើត សារាយ ត្រូវបានចាប់ផ្សឹកកាលពីរសៀលថ្ងៃចន្ទ ហើយអ្នកទាំងពីរត្រូវបានតុលាការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ រួចត្រូវបានបញ្ជូនខ្លួនទៅកាន់ពន្ធនាគារ ម១ ដើម្បីឃុំខ្លួនបណ្តោះអាសន្ន។

មន្ត្រីនគរបាលក៏បានចាប់ខ្លួនយុវជន គា សុគន្ធ អាយុ២២ឆ្នាំ ដែលជាអ្នកនិពន្ធនិងច្រៀងបទចម្រៀងរ៉េប នៅខេត្តសៀមរាប។ លោក ត្រូវបានតុលាការចោទប្រកាន់ពីបទញុះញង់ពាក់ព័ន្ធនឹងបទចម្រៀងរ៉េបមួយបទ ដែលលោកបាននិពន្ធ ហើយផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័របណ្តាញសង្គម យូធូប កាលពី៤ខែមុន ដែលមានចំណងជើងថា៖ "ដីខ្មែរ"។ បទចម្រៀងនេះ មានការលើកឡើងអំពីបញ្ហាព្រំដែន ហើយទទួលបានការចូលទស្សនាជាង ១លាន៣សែនដង នៅលើគេហទំព័របណ្តាញសង្គម យូធូប។ លោក សុគន្ធ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅខេត្តសៀមរាប។

ក្រុមសង្គមស៊ីវិលជាច្រើនស្ថាប័នបានបង្ហាញពីការសោកស្តាយយ៉ាងខ្លាំងចំពោះសកម្មភាពចាប់ខ្លួនយុវជនជាច្រើនរូបនេះ ដោយក្រុមសង្គមស៊ីវិលទាំងអស់នេះបានអំពាវនាវឱ្យទំលាក់ចោលបទចោទទាំងនេះ។

យោងតាមសេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិលជិត៤០ស្ថាប័ន បានស្នើឱ្យអាជ្ញាធរបញ្ឈប់ការបំភិតបំភ័យនិងបង្ក្រាបមកលើក្រុមអ្នកការពារសិទ្ធិមនុស្សនិងបរិស្ថានវ័យក្មេង និងការតវ៉ាដោយអហិង្សារបស់អ្នកទាំងនោះ ហើយនឹងស្នើសុំឱ្យអាជ្ញាធរធានានូវការគោរពសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងការតស៊ូមតិដោយអហិង្សា ដើម្បីសិទ្ធិរបស់អ្នកទាំងនោះ ក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ដែលអ្នកទាំងនោះរស់នៅ។

ទន្ទឹមនឹងនេះដែរ អ្នកនាំពាក្យនៃក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ បានអះអាងថា ក្រុមយុវជនខ្មែរថាវរៈ និងក្រុមយុវជនចលនាមាតាធម្មជាតិបាន និងកំពុងធ្វើសកម្មភាពក្រោមរូបភាព ដែលមានអង្គការចាត់តាំងច្បាស់លាស់។ ក្រុមនេះមិនបានចុះឈ្មោះក្នុងបញ្ជី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឡើយ។

លោកបានលើកឡើងថា៖ «ក្រុមយុវជនខ្មែរថាវរៈ និងក្រុមយុវជនចលនាមាតាធម្មជាតិបានកំពុងធ្វើសកម្មភាពដែលមានចរិតបំផុស ញុះញង់ធ្វើឱ្យប៉ះពាល់ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបង្កភាពចលាចលវឹកវរក្នុងសង្គម តាមរយៈការប្រើប្រាស់បណ្តាញសង្គម និងបណ្តាញព័ត៌មានមួយចំនួនទៀត ដើម្បីផ្សព្វផ្សាយអត្ថបទ ខិត្តប័ណ្ណរូបភាពនានា ខ្សែវីដេអូ ព្រមទាំងបានធ្វើបាតុកម្មដោយគ្មានច្បាប់អនុញ្ញាតថែមទៀតផង»។

ក្រសួងមហាផ្ទៃក៏បានអំពាវនាវដល់ប្រជាពលរដ្ឋកុំចូលរួមក្នុងសកម្មភាពខុសច្បាប់របស់ក្រុមនេះ។ ជាមួយគ្នានេះក្រសួងមហាផ្ទៃស្នើឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវចាត់វិធានការតាមផ្លូវច្បាប់ដើម្បីធានារក្សាសណ្តាប់ធ្នាប់ សាធារណៈ និងសន្តិសុខជាតិ។ ជាពិសេសទប់ស្កាត់នូវរាល់ការបង្កភាពអនាធិបតេយ្យ និងបង្កចលាចលវឹកវរនៅក្នុងសង្គម៕




*រូបភាពយុវជន និងព្រះសង្ឃដែលត្រូវបានចាប់ និងឃុំខ្លួនជាបន្តបន្ទាប់។* ***រូបភាព៖ ហ្វេសប៊ុក***

# ផ្សារណាត់បាត់ដំបងឆេះខាតជាង៨០ម៉ឺនដុល្លារ អាជ្ញាធរបានចេញវិធានការរៀបចំ–កែលម្អតាមផ្សារធំៗ

*អត្ថបទ៖ អមរិន្ទ ដានុត*

ទំហំនៃការខូចខាតពីការឆេះផ្សារធំបាត់ដំបងឬផ្សារណាត់ គិតជាទឹកប្រាក់អស់ប្រមាណជា៨៣១០០០ដុល្លារអាមេរិក ដែលក្នុងនោះតូបខូចខាតទាំងស្រុងចំនួន ៣២ ប៉ាន់ប្រមាណជាទឹកប្រាក់ចំនួន ៧៥០ ០០០ដុល្លារអាមេរិក។

លោក សៀម ប៊ុនរិទ្ធ អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង បានឱ្យដឹងនៅថ្ងៃពុធ ទី២ ខែកញ្ញា ឆ្នាំ២០២០នេះនៅពេលដែលលោកចុះទៅជាមួយនឹងអាជីវករថា តូបដែលរងការខូចខាតខ្លះ មានតូបលក់គ្រឿងទេសចំនួន១៥, តូបលក់ចានឆ្នាំងចំនួន៤, និងតូបលក់ខោអាវ ចំនួន ១៣ ចំណែកតូបរងការខូចខាតប្រមាណ ៥០ភាគរយ មានចំនួន៦តូប ក្នុងនោះតូបគ្រឿងទេសចំនួន៥ និងតូបខោអាវ១ គិតជាទឹកប្រាក់ប្រមាណ៨ម៉ឺនដុល្លារ។


*ផ្សារណាត់ខេត្តបាត់ដំបងនៅមុនពេលឆេះបណ្តាលឱ្យខូចខាត។ រូបភាព៖ សហការី*

លោក សៀម ប៊ុនរិទ្ធ បានលើកឡើងទៀតថា អាជ្ញាធរខេត្តអនុញ្ញាតឱ្យលក់ដូរនៅផ្នែកខ្លះធម្មតាឡើងវិញ ព្រោះមិនមានការប៉ះពាល់ដោយភ្លើងឆេះពីពេលកន្លងទៅ ប៉ុន្តែផ្នែកខាងលិចផ្សារដែលរងការឆេះ មិនទាន់ឱ្យចូលលក់ដូរទេ ដោយសារតែអគារផ្សារនៅកន្លែងឆេះនេះ បានរងនូវការខូចខាតសំណង់ដំបូលផ្សារ តម្រូវឱ្យមានការរៀបចំជួសជុល និងធ្វើការកែលម្អឱ្យប្រសើរឡើងវិញចាប់តាំងពីខែកញ្ញាកន្លងមក បន្ទាប់ពីមានការផ្អាករយៈពេលប៉ុន្មានថ្ងៃ ដោយសារបញ្ហាគ្រោះអគ្គីភ័យកាលពីពេលថ្មីៗកន្លងទៅនេះ។

លោក សៀម ប៊ុនរិទ្ធិ បានបន្ថែមថា៖ «តាមការចុះពិនិត្យនិងវាយតម្លៃ អគ្គីភ័យនៅផ្សារណាត់នេះ បណ្តាលមកពីការទុស្សេខ្សែភ្លើង ធ្វើឱ្យប៉ះពាល់ដល់ផ្នែកខ្លះនៃដំបូលផ្សារ បង្កឱ្យមានស្នាមប្រេះធ្នឹមលើ បែកកញ្ចក់ បាក់បែកដំបូលបេតុងបន្ទះ តម្រូវឱ្យមានការសិក្សាលម្អិតពីការរៀបចំកែលម្អ និងជួសជុលឡើងវិញ តាមរយៈការប្រគល់ឱ្យខាងមន្ទីររៀបចំដែនដី និងមន្ទីរវប្បធម៌ខេត្ត សហការគ្នាធ្វើការពិនិត្យវាយតម្លៃ ធ្វើការជួសជុលឡើងវិញទៅតាមរចនាបថដើម ដែលជាអគារអភិរក្ស»។

រដ្ឋបាលខេត្តបាត់ដំបង បានកំណត់ និងដាក់ចេញនូវវិធានការក្នុងការចុះរៀបចំ និងធ្វើការកែលម្អនៅតាមទីតាំងផ្សារធំៗនៅក្នុងទីប្រជុំជននៃក្រុងបាត់ដំបង ដោយកំណត់ឱ្យគ្រប់បណ្តាស្ថាប័នមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងកងកម្លាំងចុះធ្វើការសិក្សាលម្អិតបន្ថែមទៀត ពីផលប៉ះពាល់ពីគំរោងពាក់ព័ន្ធគ្រប់ស្ថាប័នជំនាញ ធ្វើការសិក្សាលម្អិត និងអំពីការរៀបចំប្លង់មេ ដើម្បីធ្វើការវាយតម្លៃនូវក្នុងការស្តារ និងរៀបចំផ្សារណាត់បាត់ដំបងឡើងវិញ ដើម្បីអភិវឌ្ឍន៍ផ្សារនេះ ឱ្យមានទាំងសោភ័ណភាពទាំងអនាម័យបរិស្ថានល្អ ក្នុងការរក្សាទាំងបរិយាកាសខ្យល់ចេញចូលឱ្យបានល្អប្រសើរ និងពីអត្តសញ្ញាណរបស់ផ្សារដែលជាសម្បត្តិបេតិកភ័ណ្ឌបន្សល់ទុកពីសម័យបារាំងកន្លងមក។

ពិសេសជាងនេះទៅទៀតនោះ ការរៀបចំឱ្យមានសណ្តាប់ធ្នាប់នៃការលក់ដូរ ដោយរៀបចំរចនាតូបពីគម្លាតតូបលក់ដូរឱ្យបានល្អប្រសើរឡើងវិញនិងទុកចន្លោះផ្លូវដើរក្នុងផ្សារ និងការរៀបចំឱ្យមាននូវប្រព័ន្ធសុវត្ថិភាពទឹក-ភ្លើងក្នុងផ្សារនៅតាមតូបនីមួយៗ និងនៅក្បែរៗជិតផ្សារ ដើម្បីបំរុងទុកជាមុន នៅពេលមានហេតុការអាក្រក់កើតឡើងជាយថាហេតុ ដើម្បីបានដោះស្រាយជាបឋមនៅពេលកើតឡើង។

លោក សៀម ប៊ុនរិទ្ធិ ក៏បានសង្កត់ធ្ងន់បន្ថែមទៀតដោយស្នើដល់រដ្ឋបាលក្រុង គណៈកម្មការផ្សារ អ្នកវិនិយោគភាស៊ីផ្សារ និងសមត្ថកិច្ចជំនាញពាក់ព័ន្ធទាំងអស់ត្រូវខិតខំពន្លឿនការរៀបចំសម្អាតផ្សារឡើងវិញឱ្យបានឆាប់ដើម្បីជួយសម្រួលដល់ការលក់ដូររបស់អាជីវករក្នុងផ្សារឱ្យមានដំណើរការលក់ដូរធម្មតាឡើងវិញ។ ដោយឡែក គ្រប់អាជីវករដែលលក់ដូរទាំងក្នុងនិងនៅខាងក្រៅផ្សារត្រូវចូលរួមសហការជាមួយគណៈកម្មការនិងអ្នកវិនិយោគផ្សារទាំងសណ្តាប់ធ្នាប់ពីការកំណត់ការលក់ដូរទៅតាមការណែនាំរបស់ផ្សារនិងអាជ្ញាធរក្រុង ដើម្បីដំណើរការឱ្យផ្សារឆាប់បានលក់ដូរនៅក្នុងពេលវេលាសមស្របណាមួយចៀសវាងការឃឹតយ៉ាវ។

រដ្ឋបាលខេត្តបាត់ដំបង ក៏បានជំរុញដល់គណៈកម្មការផ្សារណាត់និងម្ចាស់ភាស៊ីផ្សារ ត្រូវពិនិត្យកែលម្អឡើងវិញ និងត្រូវបញ្ឈប់បន្ទាន់ពីភាពអសកម្មកើតឡើងនៅក្នុងបរិវេណផ្សារនិងជុំវិញផ្សារជាពិសេស និងពីបញ្ហាការឃឹតយ៉ាវពីការប្រមូលសម្រាមរបស់ក្រុមហ៊ុន ស៊ីនទ្រីកន្លងមក៕

# ចម្លាក់ប្រអប់ព្រះហស្តឆ្វេងព្រះពុទ្ធបដិមាដ៏ធំមួយ បានប្រទះឃើញនៅខាងត្បូងនៃប្រាសាទបាយ័ន





*អត្ថបទ៖ អមរិន្ទ ដានុត*

ចម្លាក់ប្រអប់ព្រះហស្តព្រះពុទ្ធរូបខាងឆ្វេងមួយធ្វើអំពីថ្មភក់ត្រូវបានប្រទះឃើញនៅក្នុងព្រៃខាងត្បូងចម្ងាយប្រហែល៣០០ម៉ែត្រពីប្រាសាទបាយ័នកាលពីដើមខែកញ្ញាកន្លងមកនេះ។

ចម្លាក់នេះមានទំហំបណ្តោយ ០.៩៥ ម៉ែត្រ ទទឹង ០.៤២ម៉ែត្រ និងកម្រាស់ ០.២៤ ម៉ែត្រ ក្នុងសភាពហាក់មិនទាន់ឆ្លាក់រួចរាល់ត្រឹមត្រូវនៅឡើយទេ ដោយឃើញមានស្នាមមុខពន្លាក និងមិនទាន់ខាត់រំលីងនៅឡើយ។

លោក ឈួក សុម៉ាឡា មន្ត្រីចុះបញ្ជីបេតិកភ័ណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការបានឱ្យដឹងថា ចម្លាក់ដែលមានត្រឹមកដៃនិងម្រាមទាំង៥ ដែលលាផ្ការបាតដៃទៅលើនេះ គឺស្ថិតនៅក្នុងសម័យកណ្តាលទំនងជាព្រហស្តព្រះពុទ្ធបដិមាក្នុងកាយវិការភូមិស្បសីមុទ្រា ឬហៅថាកាយវិការមារវិជ័យ ឬផ្ចាញ់មារ។

លោកបានបញ្ជាក់ថា៖ «ទម្រង់កាយវិការនោះ ព្រះពុទ្ធទ្រង់គង់ភ្នែន ដោយយកព្រះហស្តខាងស្តាំដាក់ផ្កាប់លើភ្លៅសំយ៉ុងម្រាមដៃចង្អុលទៅធរណី។ រីឯព្រះហស្តឆ្វេងដាក់នៅលើចន្លោះភ្លៅ ហើយលាផ្ការបាតព្រះហស្តទៅលើ»។

តាមការសន្និដ្ឋាន ជាកាយវិការភូមិស្បសីមុទ្រាបែបដូចនេះ គឺយោងទៅលើហេតុផល ដែលមានព្រះពុទ្ធបដិមាធំៗ ចំនួន២អង្គដែលស្ថិតនៅជុំវិញប្រាសាទបាយ័នរួមមាន ព្រះអង្គឥន្ទ្រទេព និងព្រះអង្គងោក គឺសុទ្ធសឹងតែសង់ឡើងក្នុងទំហំធំ និងពីថ្មភក់ច្រើនដុំ ហើយស្ថិតនៅក្នុងកាយវិការភូមិស្បសីមុទ្រាដូចគ្នា។

យោងតាមអាជ្ញាធរជាតិអប្សរាបាន លើកឡើងថា នៅបរិវេណដែលរកឃើញចម្លាក់នោះ គឺទំនងជាសំណង់ខឿនព្រះពុទ្ធសាសនា ត្បិតយើងឃើញមានថ្មសីមាមួយចំនួនផងដែរ។ យ៉ាងណាមិញ តាមការស្រាវជ្រាវ និងរូបថតពីលើអាកាសដែលថតដោយបច្ចេកវិទ្យា LiDAR ក៏បានរកឃើញស្លាកស្នាមទីតាំងមនុស្សរស់នៅជាច្រើននៅក្នុងបរិវេណក្រុងអង្គរធំ ហើយសំណង់ទាំងនោះក៏រួមមាន ខឿនពុទ្ធសាសនាជាច្រើនកន្លែង ដែលសង់ពីថ្មភក់ និងថ្មបាយក្រៀមនៅបរិវេណនោះ។

លោក ឈួក សុម៉ាឡា បានឱ្យដឹងថា បច្ចុប្បន្នចម្លាក់ប្រអប់ព្រះហស្តនេះ ក្រុមការងារចុះបញ្ជីបេតិកភ័ណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានសហការណ៍ជាមួយស្ថាប័នមានសមត្ថកិច្ចនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អង្គរ ព្រមទាំងមន្ត្រីអភិរក្សប្រាសាទ បានធ្វើកំណត់ហេតុប្រគល់ទទួល និងដឹកយកទៅរក្សាទុកនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាដើម្បីចុះបញ្ជី និងរក្សាទុករង់ចាំការជួសជុលនៅថ្ងៃអនាគត៕

# អគ្គិភ័យឆេះផ្សារសំរោងយ៉ោង អស់តូបជាង២០០ គិតជាទឹកប្រាក់ប្រមាណ៨លានដុល្លារ

*អត្ថបទ៖ អមរិន្ទ ដានុត*

តូបលក់ដូរជាង២០០តូបត្រូវបានខូចខាតទាំងស្រុងដែលគិតជាទឹកប្រាក់ប្រមាណជា៨លានដុល្លារអាមេរិក ដោយសារអគ្គិភ័យបានបំផ្លាញក្នុងផ្សារសំរោងយ៉ោង កាលពីយប់ថ្ងៃព្រហស្បតិ៍ទី១៧ ខែកញ្ញា ឆ្នាំ២០២០ ក្នុងស្រុកបាទី ខេត្តតាកែវ។

យោងតាមរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកបាទីបានឱ្យដឹងថា តូបលក់ដូរចំនួន២៣០ តូបក្នុងចំណោម២៨៣តូប នៅផ្សារសំរោងយ៉ោង ត្រូវអគ្គីភ័យឆាបឆេះទាំងស្រុងបណ្តាលមកពីឆ្លងចរន្តអគ្គិសនី។

មន្ត្រីនគរបាលខេត្តបានឱ្យដឹងថា ករណីនេះ សមត្ថកិច្ចមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងសហគមន៍ បានសហការគ្នាជួយពន្លត់ដែរ តែមិនអាចជួយសង្គ្រោះបាន ដោយសារកម្លាំងភ្លើងឆេះខ្លាំងនិងលឿនពេក។ ជាមួយគ្នានេះ អគ្គីភ័យបានរលត់ទៅវិញទាំងស្រុង នៅវេលាម៉ោង១៖៣០នាទី រំលងអាធ្រាត្រឈានចូលថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០។

របាយការណ៍របស់នាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គីភ័យនិងសង្គ្រោះនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានឱ្យដឹងថា អគ្គីភ័យនេះបានបំផ្លាញតូបដែលគិតជាទឹកប្រាក់អស់ចំនួនប្រហែល ៨លានដុល្លារសហរដ្ឋអាមេរិក។

ក្នុងប្រតិបត្តិការពន្លត់នេះ កម្លាំងពន្លត់អគ្គីភ័យបានប្រើប្រាស់រថយន្តពន្លត់អគ្គីភ័យចំនួន២៧គ្រឿង ប្រើប្រាស់ទឹកអស់ចំនួន៩២ រថយន្ត ក្នុងនោះមាន រថយន្តពន្លត់អគ្គិភ័យរបស់ក្រសួងមហាផ្ទៃចំនួន ០៤គ្រឿង, រថយន្ត ង៧០ ចំនួន ០៣ គ្រឿង, រថយន្តស្នងការដ្ឋាននគរបាលខេត្តកណ្តាល ចំនួន ០២ គ្រឿង, រថយន្តព្រលានយន្តហោះ ចំនួន ០២ គ្រឿង, រថយន្តស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ចំនួន ០៣ គ្រឿង, រថយន្តរបស់ចំការស៊ូម៉ា ចំនួន ០១ គ្រឿង, រថយន្តរបស់ក្រុមហ៊ុនស្រាបៀកម្ពុជា ចំនួន ០១ គ្រឿង និងរថយន្តរបស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ ចំនួន១១គ្រឿង៕





# ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អនុម័តហិរញ្ញប្បទាន ជាង២៩លានដុល្លារអាមេរិក គាំទ្ររាជរដ្ឋាភិបាលកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តហិរញ្ញប្បទានជាង ២៩លានដុល្លារអាមេរិក ដើម្បីគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ធ្វើឱ្យប្រសើរឡើង នូវការផ្តល់សេវាតាមរយៈកំណែទម្រង់សំខាន់ៗ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការ ជាពិសេស នៅតាមតំបន់ជនបទ ដែលភាគច្រើនពលរដ្ឋក្រីក្ររស់នៅ។


*លោក ហេង សុខគង់ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ រូបភាព៖ ធនាគារអភិវឌ្ឍន៍អាស៊ី*

សេចក្តីប្រកាសព័ត៌មានរបស់ADB បានឱ្យដឹងថា ការផ្តល់កម្ចីនេះ គឺជាកម្មវិធីទី២ នៃការអភិវឌ្ឍផ្នែកសេវា និងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ ដែលបានធ្វើវិមជ្ឈការ រួមមានប្រាក់កម្ចី ផ្តោតលើគោលនយោបាយចំនួន២០លានដុល្លារ ដែលនឹងគាំទ្រដល់វិធីសាស្ត្រដើម្បីពង្រឹងផែនការនិងការគ្រប់គ្រងសារពើពន្ធនៃរដ្ឋបាលមូលដ្ឋាន ក៏ដូចជារដ្ឋបាលសាធារណៈ។ វាក៏រួមបញ្ចូលប្រាក់កម្ចីអនុវត្តន៍គម្រោងចំនួន៩,៣៥លានដុល្លារ ដើម្បីជួយកសាងសាលារដ្ឋបាលមូលដ្ឋានជាតិ ដែលជាមជ្ឈមណ្ឌលបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជរដ្ឋាភិបាលក្នុងតំបន់។ លើសពីនេះ រាជរដ្ឋាភិបាលនឹងផ្តល់ហិរញ្ញប្បទានដល់គម្រោងនេះចំនួន១,៧ លានដុល្លារផងដែរ។

លោកស្រី Jhelum Thomas អ្នកជំនាញជាន់ខ្ពស់ផ្នែកគ្រប់គ្រងវិស័យសាធារណៈរបស់ADBបានឱ្យដឹងថា គម្រោងនេះមានគោលបំណងជួយដល់រដ្ឋបាលមូលដ្ឋាន នៅទូទាំងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាសាធារណៈមូលដ្ឋានប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ហើយនឹងបង្រួមគម្លាតតំបន់ជនបទ និងទីប្រជុំជនផងដែរ។

លោកស្រីថា៖ «គម្រោងនេះ ចាំបាច់ណាស់ ខណៈដែលជំងឺរាតត្បាតកូវីដ១៩ ធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានផ្លាស់ទីពីទីក្រុងទៅជនបទ។ ប្រការនេះនឹងនាំដល់សម្ពាធបន្ថែមដល់រដ្ឋបាលមូលដ្ឋានក្នុងការផ្តល់ជំនួយសង្គមនិងសេវាកម្មចំបាច់ដូចជាផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹកនិងអនាម័យ ដើម្បីគាំទ្រដល់ការរីកចម្រើនប្រកបដោយបរិយាប័ន្ននិងសមធម៌»។

ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជាបានកើនឡើង៨% ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០១៩ កាត់បន្ថយភាពក្រីក្រមកនៅត្រឹម១៣.៥% ក្នុងឆ្នាំ ២០១៤ ពី ៤៧,៨% ក្នុងឆ្នាំ២០០៧។ ប៉ុន្តែពលរដ្ឋកម្ពុជាជាង៧០% រស់នៅជាមួយចំណូលតិចជាង៣ ដុល្លារក្នុងមួយថ្ងៃ ហើយការទទួលបានសេវាមូលដ្ឋានក៏មិនទាន់ស្មើគ្នា។ គ្រួសារក្រីក្រនិងងាយរងគ្រោះ ប្រឈមហានិភ័យធ្ងន់ធ្ងរ ខណៈដែលមានជំងឺរាតត្បាតកូវីដ១៩ ដែលបាននាំឱ្យមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ នៃវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចកម្ពុជា និងការលំបាកនៃជីវភាពរស់នៅ។

កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនេះ នឹងបំពេញបន្ថែមលើកម្មវិធីទី១ នៃការអភិវឌ្ឍផ្នែកសេវា និងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ បានធ្វើវិមជ្ឈការ ដែលកំពុងតែមានដំណើរការ។ វានឹងជួយពង្រឹងការសម្របសម្រួលការងារទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីទទួលបានការផ្តល់សេវាកម្ម ដែលឆ្លើយតបនឹងតម្រូវការប្រកបដោយការទទួលខុសត្រូវ ដែលរួមបញ្ចូលនូវការពង្រឹងផែនការថវិកាសវនកម្មនិងមុខងារអ្នកស៊ើបអង្កេត ជាយុទ្ធសាស្ត្រ។

រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់វិមជ្ឈការក្នុងឆ្នាំ ២០០១។ រដ្ឋបាលថ្នាក់ក្រោមជាតិបន្តប្រឈមមុខនឹងបញ្ហានៃភាពខ្សោយក្នុងការធ្វើផែនការថ្នាក់ក្រោមជាតិ ការគ្រប់គ្រងចំណូល និងចំណាយមិនសូវមានប្រសិទ្ធភាព និងការអភិវឌ្ឍជំនាញមន្ត្រីសាធារណៈ។

ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ការគាំទ្រយ៉ាងទូលំទូលាយដល់កំណែទម្រង់វិមជ្ឈការរបស់ ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០២ ដូចជាការគាំទ្រដល់កំណែទម្រង់ច្បាប់ គោលនយោបាយ និង ស្ថាប័ន។

នៅចន្លោះឆ្នាំ២០០២និងឆ្នាំ២០១២ ការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តោតលើ ការពង្រឹងក្រុមប្រឹក្សាឃុំសង្កាត់ និងការពង្រីកសេវាកម្មនៅតាមតំបន់ជនបទ។ ចាប់តាំងពីឆ្នាំ ២០១២មក ការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តោតលើការពង្រឹង ការសម្របសម្រួលការងារ របស់រាជរដ្ឋាភិបាល ក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងការកំណត់តួនាទីនិងភារកិច្ចក្នុងការផ្តល់សេវា។ គម្រោងថ្មីនេះ គឺស្របទៅនឹងអាទិភាព ដែលបានដាក់ក្នុងយុទ្ធសាស្ត្រភាពជាដៃគូ របស់ ADB សម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣។

ធនាគារអភិវឌ្ឍន៍អាស៊ី ប្តេជ្ញាថានឹងសម្រេចបាននូវ វិបុលភាព បរិយាប័ន្ន ភាពធន់នឹងនិរន្តរភាពក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ស្របជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់ភាពក្រីក្រខ្លាំង។

បង្កើតឡើងនៅឆ្នាំ១៩៦៦ ធនាគារនេះគ្រប់គ្រងដោយសមាជិកចំនួន៦៨ប្រទេស ដែលក្នុងនោះមាន ៤៩ប្រទេសមកពីតំបន់នេះ៕

# ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់បើកកិច្ចប្រជុំអំពីកូវីដ១៩

*អត្ថបទ៖ អរិយបុត្រ*

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់បានបើកកិច្ចប្រជុំ បូកសរុបការងារឆមាសទី៤របស់ខ្លួន ដោយផ្តោតជាសំខាន់នៅលើបញ្ហាកូវីដ១៩។ កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សាដែលផ្តួចផ្តើមបង្កើតឡើងដោយសម្តេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្រោយការបោះឆ្នោតកាលពីឆ្នាំ២០១៨ កន្លងមកនេះ បានបើកឡើងក្រោមអធិបតី របស់ប្រមុខរាជរដ្ឋាភិបាលផ្ទាល់។




*ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់បានបើកកិច្ចប្រជុំ បូកសរុបការងារឆមាសទី៤ ក្រោមអធិបតីរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី។ រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី*

នៅក្នុងសុន្ទរកថាបើកកិច្ចប្រជុំសម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា បញ្ហាកូវីដ១៩ មិនមែនជាបញ្ហាដាច់ដោយឡែករបស់កម្ពុជានោះទេ វាជាបញ្ហារួមរបស់ពិភពលោក។ សម្តេចតេជោបានបន្តថា បើពិនិត្យទិដ្ឋភាពប្រវត្តិសាស្ត្រដែលបន្សល់ទុកឱ្យយើង ទំហំនៃការរាតត្បាតនៃកូវីដ ១៩ វាធំលើសពីសង្គ្រាមលោកលើកទី ២ ទៅទៀត ព្រោះថា សង្គ្រាមនៅពេលនោះវាប៉ះពាល់ទៅលើតែប្រទេសខ្លះតែប៉ុណ្ណោះ ក៏ប៉ុន្តែកូវីដ១៩តើវានៅសេសសល់ប្រទេសណាខ្លះសូម្បីកូនកោះតូចមួយនៅកណ្តាល មហាសាគរក៏កូវីដ១៩ បានទៅដល់ទីនោះ។

«អញ្ចឹងទេ ខ្ញុំចង់ឱ្យអស់លោកផ្តល់នូវមតិទៅលើបញ្ហាទាំងឡាយទាក់ទិនកូវីដ១៩ នេះនោះគឺទាក់ទងជាមួយការតាមដាន របស់អស់លោក អំពីវិធានការរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញកន្លងទៅទាំងវិធានការឆ្លើយតបផ្ទាល់ទៅលើករណីកូវីដ១៩ និង ករណីទាក់ទងនឹងបរិបទនៃ សង្គមនិងសេដ្ឋកិច្ចតើចំណុចទាំងអស់នេះវាសមស្របហើយឬនៅ? តើនៅមានអ្វីទៀតជាចន្លោះប្រហោង នេះជាការចង់បានរបស់ខ្ញុំជាមួយការប្រជុំនៅថ្ងៃនេះ» នេះជាការថ្លែងបញ្ជាក់របស់សម្តេចតេជោ ហ៊ុន សែន។

ក្នុងកិច្ចប្រជុំនេះ ប្រធានគណៈប្រតិភូនៃគណបក្សនយោបាយជាសមាជិក នឹងត្រូវអនុញ្ញាតឱ្យផ្តល់នូវទស្សនទាន ដើម្បីផ្តល់ធាតុចូលក្នុងន័យស្ថាបនាអំពីបរិបទបច្ចុប្បន្នភាពសង្គម ដោយផ្អែកលើការរកឃើញតម្រុយ និងភស្តុតាងនានា តាមរយៈបេសកកម្មការងារបន្ថែមជាមួយនឹងការប្រឈមនឹងជំងឺកូវីដ១៩ផងដែរ។

សូមបញ្ជាក់ថា ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ដោយមានការស្នើសុំរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ក្រោយពេលបោះឆ្នោតជាតិអាណត្តិទី៦។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានសមាសភាពមកពីគណបក្សនយោបាយចំនួន១៦ ក្នុងចំណោមគណបក្សនយោបាយចំនួន២០ ដែលបានចូលរួមការបោះឆ្នោតជាតិឆ្នាំ ២០១៨។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានតួនាទីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលក្រៅក្របខណ្ឌសភា ក្នុងគោលដៅលើកស្ទួយប្រសិទ្ធភាពការងារ ដើម្បីជាប្រយោជន៍ដល់ការបម្រើសេវាប្រជាជន និងការអភិវឌ្ឍសង្គមប្រកបដោយសក្តានុពល៕

# កាតូលិកកំពត អធិដ្ឋានសម្រាប់មរណៈបុគ្គល និងចែកទានដល់អ្នកខ្វះខាត

*អត្ថបទ៖ លី សុវណ្ណា*





ព្រះវិហារសន្តអូគូស្តាំង ព្រះសហគមន៍កាតូលិកទីរួមខេត្តកំពត បានប្រារព្ធពិធីអធិដ្ឋាន សម្រាប់មរណៈបុគ្គលទាំងឡាយ និងការចែកទានជាគ្រឿងបរិភោគជូនដល់បងប្អូនខ្វះខាតចំនួន១៨គ្រួសារ។

ខណៈពេលដែលប្រជាពលរដ្ឋខ្មែរដែលកាន់ព្រះពុទ្ធសាសនាកំពុងប្រារព្ធពិធីកាន់បិណ្ឌនិងបុណ្យភ្ជុំបិណ្ឌ ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា មានជំនឿយ៉ាងមាំលើព្រះយេស៊ូគ្រីស្ត ក៏បានប្រារព្ធពិធីនឹករលឹកដល់មរណៈបុគ្គលក្នុងរដូវដាក់បិណ្ឌនិងភ្ជុំបិណ្ឌនេះផងដែរ ដើម្បីនឹករលឹកដល់វិញ្ញាណក្ខន្ធជីដូនជីតា បុព្វការីជនដែលបានចែកស្ថានទៅហើយ។

បងប្អូនគ្រីស្តបរិស័ទកាតូលិកអធិដ្ឋានថ្វាយទៅព្រះជាម្ចាស់ សូមសេចក្តីប្រោសប្រណីពីព្រះជាម្ចាស់ ជាព្រះបិតា ចំពោះវិញ្ញាណក្ខន្ធញាតិមិត្តទាំងឡាយដែលចែកស្ថានទៅសូមព្រះអង្គទទួលអ្នកទាំងនោះនៅស្ថានបរមសុខរួមជាមួយព្រះអង្គ។ ក្នុងពិធីនោះគ្រីស្តបរិស័ទប្រកាសជំនឿ និងសេចក្តីសង្ឃឹមរបស់ខ្លួនលើព្រះគ្រីស្ត។

ក្នុងធម្មទេសនា លោកបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកតំបន់កំពត យ៉ាំងលូកា តាវូឡា បានលើកឡើងថា ក្នុងឱកាសនេះយើងសប្បាយចិត្តដោយដឹងថា ព្រះជាម្ចាស់ស្តាប់ពាក្យទូលអង្វររបស់យើង។ ព្រះអង្គមានព្រះហឫទ័យ



*លោក យ៉ាំងលូកា តាវូឡា ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកតំបន់កំពត ក្នុងពិធីអធិដ្ឋានសម្រាប់មរណៈបុគ្គល និងចែកទានដល់អ្នកខ្វះខាត។* ***រូបភាព៖ ស៊ីអេសស៊ី***

មេត្តាករុណា យើងជឿសង្ឃឹមថា ព្រះអង្គនឹងប្រទានសេចក្តីសុខសាន្ត ព្រមទាំងទទួលវិញ្ញាណក្ខន្ធ ជីដូនជីតា ឪពុកម្តាយ អ្នកមានគុណទាំងឡាយរបស់យើងនៅស្ថានបរមសុខដែរ។

លោកបូជាចារ្យបានបន្តថា៖ «យើងក៏អរគុណព្រះជាម្ចាស់ចំពោះអ្វីៗដែលល្អដែលអ្នកទាំងនោះបានប្រព្រឹត្តរួមជាមួយយើង សុទ្ធតែប្រកបដោយសេចក្តីស្រឡាញ់ ដែលមានក្នុងជំរៅដួងចិត្តរបស់យើង និងមិនអាចបំភ្លេចបានផងដែរ។ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគាត់»។

លោកបូជាចារ្យក៏បានបញ្ជាក់ប្រាប់បងប្អូននិងរំលឹកបងប្អូនគ្រីស្តបរិស័ទថា ទោះបីយើងបានឃើញសេចក្តីល្អជាច្រើនដោយសេចក្តីស្រឡាញ់ យើងគិតថាគាត់ទៅនៅស្ថានបរមសុខហើយ។ តែមនុស្សយើងមានភាពទន់ខ្សោយ យើងត្រូវការពឹងផ្អែកលើព្រះហឫទ័យមេត្តាករុណាស្រឡាញ់របស់ព្រះយេស៊ូ ចំពោះយើងម្នាក់ៗ។

លោកថា ព្យាយាមលះបង់អ្វីដែលនាំឱ្យយើងប្រព្រឹត្តអំពើបាបនិងរស់នៅប្រកបដោយសេចក្តីស្រឡាញ់។ រស់នៅដោយចេះលើកលែងទោស។ រស់នៅដោយមានគំនិតល្អចំពោះបងប្អូនឯទៀតៗ។ រស់នៅដោយចិត្តសប្បុរស ព្រោះចុងក្រោយព្រះបន្ទូលជួយបំភ្លឺយើងថា «ព្រះជាម្ចាស់នឹងវិនិច្ឆ័យយើងតាមអ្វីដែលយើងប្រព្រឹត្តចំពោះបងប្អូនឯទៀត»។

ក្នុងអភិបូជានេះគ្រួសារ គ្រីស្តបរិស័ទនីមួយៗបានសរសេរឈ្មោះញាតិមិត្តទាំងអស់ ថ្វាយទៅព្រះតាមរយៈផ្សែងធូបដែលបានអុជរួមនឹងពាក្យសម្រាប់បុព្វការីជនទាំងអស់។

ជាមួយគ្នានោះដែរ គណៈកម្មការព្រះសហគមន៍និងលោកបូជាចារបានចែកគ្រឿងបរិភោគជូនបងប្អូនខ្វះខាត ស្ត្រីមេម៉ាយ អ្នកជំងឺ ចាស់ជរា និងអ្នកទីទាល់ក្រចំនួន១៨គ្រួសារ។

កិច្ចការសប្បុរសធម៌ ជាសកម្មភាពដែលមិនអាចខ្វះបានរបស់គ្រីស្តបរិស័ទកាតូលិក ដែលបានរួមដំណើរជាមួយព្រះយេស៊ូ។ ចំពោះបុណ្យនឹករលឹកដល់មរណៈបុគ្គលនិងសន្តបុគ្គលទាំងឡាយ ព្រះសហគមន៍កាតូលិកសកលប្រារព្ធនៅថ្ងៃទី១-២ ដើមខែវិច្ឆការៀងរាល់ឆ្នាំ។ នៅប្រទេសកម្ពុជាបានទទួលការអនុញ្ញាតឱ្យធ្វើបុណ្យនឹករលឹកដល់មរណៈបុគ្គលទាំងឡាយ ក្នុងថ្ងៃដែលពលរដ្ឋកម្ពុជាប្រារព្ធបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ៕

# លោកអភិបាលអូលីវីយេ៖ «យើងរួមគ្នាកសាងជីវិតនៅថ្ងៃអនាគត ដោយស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់បានស្រឡាញ់យើងដែរ»

*អត្ថបទ៖ សុធីរិទ្ធ*

ព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច បានរៀបចំកម្មវិធីថ្វាយអភិបូជារំលឹកដល់មរណបុគ្គលដែលបានចែកឋានទាំងអស់ ក្នុងឱកាសបុណ្យភ្ជុំ ក្រោមអធិបតីភាពលោកអភិបាល អូលីវីយេ ជ្មិតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រមទាំងមានការចូលរួមដោយលោកបូជាចារ្យនិងគ្រីស្តបរិស័ទមួយចំនួនទៀត កាលពីព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២០។

ក្នុងឱកាស គោរពមរណបុគ្គល លោកអភិបាលអូលីវីយេ បានណែនាំឱ្យគ្រីស្តបរិស័ទរិះគិតសំណួរមួយគឺ «សម្រាប់ជីវិតរបស់យើងដែលរស់នៅលើផែនដីនេះ តើអនាគតជីវិតរបស់យើងទៅណា?»។ លោកអភិបាលបានបន្តថា ប្រសិនបើយើងយកបទពិសោធក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩ តាមពិតវិធានការអនាម័យគឺជាធម្មជាតិរបស់មនុស្សតាំងពីយូរមកហើយ វាមិនមែនជាវិន័យថ្មីដែលយើងបង្កើតដោយសារមានជំងឺកូវីដ១៩ទេ។ ប៉ុន្តែ នៅប៉ុន្មានប្រទេសដោយសារប្រជាជនបានយកចិត្តទុកដាក់លាងដៃនិងអនុវត្តវិធានការអនាម័យច្រើនជាងមុន បានណែនាំឱ្យកាត់បន្ថយជំងឺផ្សេងៗជាច្រើន។

លោកមានប្រសាសន៍ក្នុងឱកាសនោះថា «ដូចគ្នាដែរ សម្រាប់គ្រីស្តបរិស័ទយកវិន័យរបស់ព្រះយេស៊ូដែលថា ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ឱ្យទៅជាធម្មជាតិរបស់យើង»។

លោកអភិបាល អូលីវីយេ ក៏បាននិយាយទៀតថា ក្នុងពេលកូវីដ១៩ យើងតែងលឺសំលេងទូរសព្ទរបស់យើងថា «យើងរួមគ្នាប្រឆាំងមេរោគកូវីដ១៩តាមការណែនាំរបស់ក្រសួងសុខាភិបាល»។ លោកបន្ថែមថា ពេលផុតការរាតត្បាតនេះ សូមឱ្យគ្រីស្តបរិស័ទប្រើទូរសព្ទនិយាយថា «យើងរួមគ្នាកសាងជីវិតនៅថ្ងៃអនាគត ដោយស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើង» វិញ ដើម្បីឱ្យមនុស្សយើងនឹកឃើញនិងត្រៀមខ្លួនពិតៗ។

លោកអភិបាល បានបន្ថែមទៀតថា យើងត្រូវប្រុងប្រយ័ត្ន ព្រោះថារបៀបដែលយើងកំពុងបង្កើតសង្គមថ្មី ជាសង្គមដែលបិទព្រំដែន ជាសង្គមដែលណែនាំឱ្យយើងនៅឆ្ងាយពីគ្នា។ យើងបានបង្កើតរបៀបថ្មីដែលប្រហែលណែនាំឱ្យយើងអាត្មានិយមមែនទែន ប៉ុន្តែអ្នកជំងឺនិងអ្នកក្រីក្រ មិនចង់ឱ្យយើងមើលគេពីចម្ងាយឡើយ។ លោកបានមានប្រសាសន៍ថា៖ «ប្រសិនបើ បងប្អូនបានស្តាប់ យើងរួមគ្នាកសាងជីវិតនៅថ្ងៃអនាគត ដោយស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់ស្រឡាញ់យើង រួចហើយ យើងដឹងថា យើងមានអនាគតពិសេស ដែលព្រះជាម្ចាស់ថែរក្សាយើង ដែលព្រះជាម្ចាស់ស្រឡាញ់យើង ដែលព្រះជាម្ចាស់យកចិត្តទុកដាក់ដល់យើង ដើម្បីយើងរកឃើញសុភមង្គលអស់កល្បជានិច្ច»។



*លោកអភិបាល អូលីវីយេ ជ្មិតហាស្លេ ព្រមទាំងនិងគ្រីស្តបរិស័ទមួយចំនួននៅកម្មវិធីថ្វាយអភិបូជារំលឹកដល់មរណបុគ្គលដែលបានចែកឋានទាំងអស់ ក្នុងឱកាសបុណ្យភ្ជុំ* ***រូបភាព៖ ស៊ីអេសស៊ី***

បន្ទាប់ពីថ្វាយអភិបូជារួចហើយ លោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័ទទាំងអស់ ក៏បានដង្ហែទៅមុខចេតីយ៍ដើម្បីអធិដ្ឋាននិងគោរពដល់មរណបុគ្គលទាំងប៉ុន្មាន និងអធិដ្ឋានដើម្បីឱ្យវិញ្ញាណក្ខន្ធរបស់ពួកគាត់បានទៅឯព្រះបិតាដែលគង់នៅស្ថានបរមសុខ៕

ទស្សនាវីដេអូទីនេះ





# ប្រាក់ ប៊ុនហុងទទួលមុខងារជាអ្នកបម្រើលើតុសក្ការៈ

*អត្ថបទ៖ កែវ កញ្ញា*

អបអរសាទរបងប្រុសប្រាក់ ប៊ុនហុង ទទួលពិធីអាកូឡៃ (Acolyte) ជាជំហានមួយសម្រាប់និស្សិតទេវវិទ្យាល័យ ដែលត្រៀមខ្លួនជាឧបដ្ឋាក និងទទួលតែងតាំងជាបូជាចារ្យកាតូលិកនាពេលខាងមុខ។

ពិធីនេះធ្វើនៅព្រះសហគមន៍ប៊ូស្រា ខេត្តមណ្ឌលគិរី ដែលមានលោកអភិបាលប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ជាអធិបតីរួមនិងបូជាចារ្យនិងគ្រីស្តបរិស័ទជាច្រើននាក់ចូលរួម។

បងប្រុសប្រាក់ ប៊ុនហុង ជាកូនទី៤ ក្នុងគ្រួសារគ្រីស្តបរិស័ទដែលមានកូនៗចំនួន៧នាក់ជាជនជាតិដើមភាគតិចពូណង(ព្នង) រស់នៅក្នុងស្រុកពេជ្រដា ខេត្តមណ្ឌលគិរី។

បងប្រុសប៊ុនហុងបានឱ្យដឹងថា មុខងារអាកូឡៃនេះគឺមានន័យថាជាអ្នកបម្រើលើតុសក្ការៈ (តុអាសនៈ)។ និស្សិតទេវ ប្រាក់ ប៊ុនហុង៖ «ឱ្យយើងស្គាល់ពីរបៀបធ្វើពិធីនៅលើអាសនៈឱ្យយើងស៊ាំជាមួយរបៀបធ្វើរបស់លោកបូជាចារ្យ (ពេលថ្វាយអភិបូជា)»។

បន្ទាប់ពីទទួលមុខងារនេះរួចបងប្រុសត្រូវសិក្សាបន្ថែមទៀតពីរបៀបនៃការបម្រើព្រះសហគមន៍ យ៉ាងហោចណាស់មួយឆ្នាំ ទើបអាចទទួលតែងតាំងជាឧបដ្ឋាកដែលជាជំហានបញ្ចប់នៃការសិក្សាជាបូជាចារ្យកាតូលិក។

គួរបញ្ជាក់ថា និស្សិតទេវវិទ្យាល័យម្នាក់ត្រូវសិក្សានៅទេវវិទ្យាល័យយ៉ាងតិចណាស់៧ឆ្នាំ។ ក្នុងរយៈពេលសិក្សានៅទេវវិទ្យាល័យនេះ និស្សិតម្នាក់ត្រូវទទួលពិធីផ្សេងៗមុនទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ គឺដូចជា៖ Admission: លោកអភិបាលទទួលស្គាល់និសិត្សទេវិទ្យាល័យជាបេក្ខជនសម្រាប់ជាបូជាចារ្យនាពេលអនាគត(ទទួលសំបុត្រមួយពីលោកអភិបាលរបស់ខ្លួន)។ Lector: មានន័យថា និស្សិតទេវិទ្យាល័យមានសិទ្ធិអានព្រះបន្ទូលព្រះជាម្ចាស់(ទទួលព្រះគម្ពីរ)។ Acolyte: មានន័យថា និសិត្សទេវវិទ្យល័យ(ទទួលពែងពីលោកអភិបាល) គឺជាអ្នកបម្រើលើតុសក្ការៈ (អាសនៈ)។ Deacon: ទទួលពិធីតែងតាំងជាឧបដ្ឋាក និងPriest Ordination: ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។



*បងប្រុសប្រាក់ ប៊ុនហុង ទទួលពិធីអាកូឡៃ (Acolyte) ជាជំហានមួយសម្រាប់និស្សិតទេវវិទ្យាល័យ ក្រោមអធិបតីលោកអភិបាលប្រ៊ុយណូ កូសម៍ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។* ***រូបភាព៖ សហការី***

បងប្រុស ប្រាក់ ប៊ុនហុង បានមានប្រសាសន៍ថា៖ «ការសម្រេចចិត្តដើរតាមផ្លូវជីវិតជាអ្នកបួសនេះ គាត់ត្រូវសម្រេចចិត្តរៀងរាល់ថ្ងៃ។ ដោយសារយើងមានភាពខ្សោយច្រើនដែរ បើចង់បម្រើព្រះជាម្ចាស់ និងព្រះសហគមន៍ បើនិយាយពីចំណេះដឹងនៅខ្វះ ដូច្នេះខ្ញុំត្រូវអធិដ្ឋាននិងត្រូវជ្រើសរើសព្រះជាម្ចាស់រៀងរាល់ថ្ងៃ»។

ក្នុងពេលខាងមុខនេះ បងប្រុសមានតែការអធិដ្ឋាន សូមព្រះជាម្ចាស់បំភ្លឺ និងផ្តល់កំលាំងកាយចិត្ត ដើម្បីសម្រេចចិត្តច្បាស់ជាងក្នុងការបម្រើព្រះជាម្ចាស់និងព្រះសហគមន៍៕

# យុវជន៨រូបទទួលអគ្គសញ្ញាជ្រមុជទឹកនៅព្រះវិហារសន្តសិលានិងសន្តប៉ូល

*អត្ថបទ៖ ដាលីស*

យុវជន៨រូបបានទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីកែប្រែជីវិតថ្មីដោយមានជំនឿលើព្រះជាម្ចាស់ និងរួមរស់ជាមួយព្រះគ្រីស្ត។

កម្មវិធីនេះធ្វើនៅព្រះវិហារសន្តសិលានិងសន្តប៉ូល នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី នាព្រឹកថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២០កន្លងមកនេះ ដែលដឹកនាំដោយលោកបូជាចារ្យ សិលា សួន ហង្សលី និងមានគ្រីស្តបរិស័ទជាច្រើនចូលរួមអបអរសាទរផងដែរ។

នៅក្នុងពិធីបុណ្យអភិបូជា នៃអគ្គសញ្ញាជ្រមុជទឹកនេះ លោកបូជាចារ្យ លី បានណែនាំគ្រីស្តបរិស័ទទាំងអស់ ជាពិសេសយុវជនដែលទទួលអគ្គសញ្ញានេះឱ្យយកចិត្តទុកដាក់ចំពោះមុខងាររបស់ខ្លួនជាគ្រីស្តបរិស័ទ ជាពិសេសលោកបានសង្កត់ធ្ងន់ទៅលើបីចំណុចគឺ៖ ព្យាការី៖ នៅពេលដែលមាននរណាម្នាក់ធ្វើអំពើបាប សូមយកពេលវេលាទៅដាស់តឿនគាត់ដោយសេចក្តីស្រឡាញ់។

លោកបន្តថា៖ «ចំនុចទី២ សូមឱ្យយើងមានសេចក្តីស្រឡាញ់ពិតប្រាកដ ដោយនឹកដល់គ្រប់វិន័យរបស់ព្រះយេស៊ូ និងគ្រប់អំពើដែលយើងធ្វើចំពោះអ្នកដទៃ ព្រោះថាបើធ្វើដោយសេចក្តីស្រឡាញ់យើងនឹងទទួលផលផ្លែដ៏ប្រសើរសម្រាប់ខ្លួនយើង និងសម្រាប់អ្នកដទៃផងដែរ»។

លោកបូជាចារ្យ សិលា សួន ហង្សលី បានលើកឡើងទៀតថា ចំនុចទី៣ គឺលោកសូមឱ្យយកចិត្តទុកដាក់ចំពោះរបៀបនៃការអធិដ្ឋាន៖ ប្រសិនបើអធិដ្ឋានក្នុងព្រះនាមព្រះយេស៊ូ នោះព្រះជាម្ចាស់នឹងស្តាប់[យើង]ច្រើនជាងអធិដ្ឋានក្នុងនាមខ្លួនឯង។



*លោកបូជាចារ្យ សិលា សួន ហង្សលី ក្នុងអគ្គសញ្ញាជ្រមុជទឹកយុវជនទាំង៨រូប។* ***រូបភាព៖ ស៊ីអេសស៊ី***

បន្ទាប់ពីធម្មទេសនា លោកបូជាចារ្យ ហង្សលី ដឹកនាំគ្រីស្តបរិស័ទទាំងអស់លុតជង្គង់ទូលអង្វរព្រះជាម្ចាស់តាមរយៈសន្តបុគ្គលទាំងឡាយ រួចសួរបញ្ជាក់បេក្ខជនអំពីការប្តេជ្ញាចិត្តក្នុងការលះបង់ចោលមារសាតាំង និងប្រកាសជំនឿរបស់ខ្លួននៅមុខអាសនៈ។

យុវជនទាំង៨រូប បានទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ បន្ទាប់មកលោកបូជាចារ្យលាបប្រេងគ្រីស្មា

> សូមឱ្យយើងមានសេចក្តីស្រឡាញ់ពិតប្រាកដ ដោយនឹកដល់គ្រប់វិន័យរបស់ព្រះយេស៊ូ និងគ្រប់អំពើដែលយើងធ្វើចំពោះអ្នកដទៃ ព្រោះថាបើធ្វើដោយសេចក្តីស្រឡាញ់យើងនឹងទទួលផលផ្លែដ៏ប្រសើរសម្រាប់ខ្លួនយើង និងសម្រាប់អ្នកដទៃផងដែរ

ដើម្បីផ្តល់កម្លាំងនៃជំនឿ ហើយស្នើដល់បងធម៌បំពាក់អាវស ដែលជានិមិត្តសញ្ញានៃការពាក់ព្រះយេស៊ូដល់អស់អ្នកដែលទើបតែទទួលពិធីជ្រមុជទឹកថ្មីៗ រួចប្រគល់ទានដែលបានចម្លងពន្លឺពីទានជ័យ ដើម្បីបង្ហាញថាគ្រីស្តបរិស័ទថ្មីទទួលពន្លឺព្រះគ្រីស្តនៅជាមួយពួកគេផងដែរ។

យុវជន ស៊ុន ឌី ជាគ្រីស្តបរិស័ទដែលទើបតែទទួលអគ្គសញ្ញាជ្រមុជទឹកនេះ បាននិយាយថា ក្រោយពីទទួលការអប់រំជំនឿតាមរយៈបណ្តាញសង្គមមក លោកចង់ទទួលជឿលើព្រះយេស៊ូយ៉ាងពិតប្រាកដ ហើយក៏ចង់ដឹងពីដំណើរជីវិតរបស់លោកក្នុងការដើរតាមព្រះយេស៊ូ។

លោកបានថ្លែងថា៖ «កត្តាសំខាន់មួយទៀត ដែលធ្វើឱ្យខ្ញុំពិតជាចង់ទទួលអគ្គសញ្ញាជ្រមុជទឹក អាចជួយយើងឱ្យរួចពីអំពើបាប និងក្នុងនោះមានឃ្លាមួយក្នុងធម៌ឱព្រះបិតាបានធ្វើឱ្យខ្ញុំមានការចាប់អារម្មណ៍ជាខ្លាំងគឺ សូមប្រទានអាហារឱ្យយើងខ្ញុំនៅថ្ងៃនេះ។ ខ្ញុំយល់ថាអាហារនេះចែកជាពីរ គឺផ្លូវកាយ និងវិញ្ញាណ គឺព្រះកាយនិងព្រះលោហិតដែលអាចជួយរំដោះបានស្រាល និងមិនឱ្យប្រព្រឹត្តបាបធ្ងន់»។

យុវជន ស៊ុន ឌី បញ្ជាក់ទៀតថា ព្រះបន្ទូលមានសារៈសំខាន់សម្រាប់រូបលោក ព្រោះព្រះបន្ទូលជួយដឹកនាំជីវិតដោយលើកទឹកចិត្តលោកនៅពេលលោកពិបាកចិត្ត។ ម្យ៉ាងទៀតនៅថ្ងៃអនាគតខាងមុខនេះ យុវជនរូបនេះចង់ក្លាយជាអ្នកអប់រំជំនឿមួយរូបនៅក្នុងព្រះសហគមន៍នេះ៕

# តាមគំរូ និងរួមជាមួយព្រះនាងម៉ារី យើងធ្វើតាមព្រះទ័យព្រះជាម្ចាស់

*អត្ថបទ៖ កែវ កញ្ញា*

ក្នុងឱកាសបុណ្យកំណើតព្រះនាងម៉ារី លោកអភិបាលអូលីវីយេ ផ្មិតហស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ រួមជាមួយគ្រីស្តបរិស័ទនៃព្រះសហគមន៍អរិយក្សត្រ ក្នុងព្រះវិហារព្រះនាងម៉ារីជាមាតានៃសន្តិភាព កាលពីល្ងាចថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០។



*គ្រីស្តបរិស័ទនៃព្រះសហគមន៍អរិយក្សត្រ នៅក្នុងពិធីអរព្រះគុណព្រះជាម្ចាស់។ **រូបភាព៖ ស៊ីអេសស៊ី***



*លោកអភិបាលអូលីវីយេ ផ្មិតហស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់។ **រូបភាព៖ ស៊ីអេសស៊ី***

មានប្រសាសន៍នៅក្នុងធម្មទេសនានាឱកាសបុណ្យកំណើតព្រះនាងម៉ារីនេះ លោកអភិបាលអូលីវីយេ លើកទឹកចិត្តឱ្យគ្រីស្តបរិស័ទអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានជីវិតឱ្យម្នាក់ៗ រៀងៗខ្លួន និងប្រទានឪពុកម្តាយ ឱ្យគ្រប់គ្នា ទោះពួកគាត់ស្លាប់ទៅហើយមែន តែវត្តមានរបស់យើងនៅពេលនេះ គឺបានមកពីពួកគាត់។

លោកអភិបាលមានប្រសាសន៍ទៀតថា សេចក្តីស្រឡាញ់បានបង្កើតគ្រួសារដូចព្រះនាងម៉ារីមានលោកយ៉ូហានគីម និងលោកយាយអាណា។ ក្នុងសៀវភៅមិនផ្លូវការ ព្រះសហគមន៍បានស្រាវជ្រាវរកឃើញថា ព្រះនាងម៉ារីមានម្តាយឈ្មោះអាណា និងឪពុកឈ្មោះយ៉ូហានគីម ហើយថ្ងៃទី៨ ខែកញ្ញានេះ គឺជាថ្ងៃកំណើតរបស់ព្រះនាងម៉ារី ដែលជាមាតារបស់ព្រះយេស៊ូ។

លោកអភិបាលបន្តទៀតថា យើងក៏អរព្រះគុណព្រះជាម្ចាស់ដែលបានជ្រើសរើសយើងឱ្យទៅជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ហើយព្រះអង្គបានជ្រើសរើសព្រះនាងម៉ារីជាព្យាការីម្នាក់។«តាំងពីកំណើតពិភពលោក សង្ស័យថា ព្រះជាម្ចាស់បានរើសព្រះនាងម៉ារីជាមាតាព្រះយេស៊ូហើយៗ»។

លោកអភិបាលបានណែនាំឱ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់អប់រំកូនៗរបស់ខ្លួន ឱ្យដូចគំរូរបស់ឪពុកម្តាយរបស់ព្រះនាងម៉ារី ដោយមានការអប់រំទាំងជំនឿ និងកិច្ចការសង្គម ដោយភ្ជាប់ជីវិតរស់នៅជិតស្និទ្ធជាមួយព្រះជាម្ចាស់។ លោកអភិបាល៖ «យើងដឹងថាពីមួយថ្ងៃទៅមួយថ្ងៃ ព្រះជាម្ចាស់មានគម្រោងការសម្រាប់យើង យើងអនុវត្តតាមគម្រោងការរបស់ព្រះជាម្ចាស់ ហើយយើង (ឪពុកម្តាយ) មានតួនាទីអប់រំនិងណែនាំ ដូចជាព្រះសហគមន៍ដែរ... ដើម្បីស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់»។

លោកអភិបាលលើកទឹកចិត្តឱ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់ខ្ពស់នៃការថែរក្សាពន្លកថ្មីដែលជាជំនាន់ក្រោយរបស់ខ្លួន ដើម្បីបង្កើតមនុស្សលោកថ្មី ពិភពលោកថ្មី និងសង្គមថ្មី។

លោកក៏បានរំលឹកអំពីសភាពការណ៍នៃសម័យមេរោគរាតត្បាតកូវីដ១៩ ដែលបានធ្វើឱ្យសង្គមរបស់យើង និងពិភពលោករបស់យើងមានរបួសយ៉ាងច្រើន ដោយមានមនុស្សជាច្រើនបាត់បង់ជីវិត ការងារ បាត់បង់អ្វីៗទាំងអស់ រួមទាំងសេចក្តីសង្ឃឹមនៅក្នុងជីវិត ហើយភាគច្រើនគឺអ្នកក្រីក្រ។ ក្នុងអំឡុងពេលដ៏តានតឹងនេះ ព្រះសហគមន៍បានបញ្ឈប់និងផ្អាកសកម្មភាពរបស់ខ្លួន តាមការស្នើសុំរបស់រដ្ឋាភិបាល និងក្រសួងធម្មការនិងសាសនា។ ប៉ុន្តែលោកអភិបាលនៅតែរំពឹងថា នឹងអាចដំណើរការបានឡើងវិញក្នុងពេលឆាប់ៗខាងមុខ។

លោកមានប្រសាសន៍បន្តទៀតថា ព្រះសហគមន៍ស្ងៀមស្ងាត់ ដូចព្រះនាងម៉ារីក្នុងដំណឹងល្អ«ប៉ុន្តែស្ងៀមស្ងាត់ដោយមានផលផ្លែយ៉ាងច្រើន...លុះត្រាតែយើងចូលរួមយ៉ាងជិតស្និទ្ធជាមួយព្រះនាងម៉ារីដែលជាម្តាយរបស់យើង ដែលយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់»។

ព្រះវិហារព្រះនាងម៉ារីជាមាតានៃសន្តិភាព នៃព្រះសហគមន៍កាតូលិកអរិយក្សត្រ ជាបូជនីយដ្ឋាន ព្រះនាងម៉ារីនៃទន្លេមេគង្គ សម្រាប់ព្រះសហគមន៍កាតូលិកនៅកម្ពុជា។ មានសញ្ញាជាច្រើនបង្ហាញពីវត្តមានរបស់ព្រះអម្ចាស់យេស៊ូរួមជាមួយព្រះនាងម៉ារី នៅក្នុងតំបន់នេះ៕

ព័ត៌មានជាសម្លេង

# ពិធីសំណាក់ធម៌លោកបូជាចារ្យភូមិភាគកំពង់ចាម





*ពិធីសំណាក់ធម៌រយៈពេល៥ថ្ងៃក្រោមការពន្យល់ណែនាំពីលោកបូជាចារ្យ ទម្លាប់ សុផល មកពីភូមិភាគបាត់ដំបង និងលោកអភិបាលប្រ៊ុយណូ កូសម៌ ជាបូជាចារ្យនៃព្រះសគមន៍ភូមិភាគកំពង់ចាម។ **រូបភាព៖ សហការី***

*អត្ថបទ៖ រឿន ស្រីម៉ាច*

ពិធីសំណាក់ធម៌របស់លោកបូជាចារ្យភូមិភាគកំពង់ចាមដែលមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី០៧ ដល់ទី១១ ខែកញ្ញា ឆ្នាំ២០២០ នៅខេត្តរតនគិរី ដើម្បីរិះគិតអំពីជីវិតនៃការត្រាស់ហៅនិងកិច្ចការប្រកាសដំណឹងល្អផ្សេងៗ។

ពិធីសំណាក់ធម៌នេះមានការពន្យល់ណែនាំពីលោកបូជាចារ្យ ទម្លាប់ សុផល មកពីភូមិភាគបាត់ដំបង និងលោកអភិបាលប្រ៊ុយណូ កូសម៌ ជាបូជាចារ្យនៃព្រះសហគមន៍ភូមិភាគកំពង់ចាម។

លោកអភិបាល ប្រ៊ុយណូ កូសម៌ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានលើកឡើងឱ្យដឹងថា សំណាក់ធម៌នេះមានសារៈសំខាន់សម្រាប់អ្នកបួសមិនថាបូជាចារ្យរឺបងស្រីគឺជាអាហារដែលផ្តល់ឱ្យសម្រាប់ជីវិតខាងផ្លូវវិញ្ញាណគឺមិនអាចខ្វះបាន។

លោកអភិបាលបានមានប្រសាសន៍ថា៖ «សូមលោកបូជាចារ្យទាំងអស់មានកម្លាំងកាយចិត្តដើម្បីបន្តបេសកម្មតាមសមត្ថភាពរៀងៗខ្លួន ដើម្បីប្រកាសដំណឹងល្អដល់បងប្អូនដែលមិនទាន់ឮអំពីព្រះយេស៊ូ និងសូមបងប្អូនជួយអធិដ្ឋានសម្រាប់លោកបូជាចារ្យផងដែរ»។

លោកបូជាចារ្យ ទម្លាប់ សុផល ដែលជាអ្នកណែនាំក្នុងអង្គពិធីនេះក៏បានឱ្យដឹងផងដែរថា ពីមួយថ្ងៃទៅមួយថ្ងៃ មនុស្សម្នាក់ៗត្រូវការអាហារដើម្បីអាចរស់នៅបាននិងមានកម្លាំងទៅមុខទៀតសម្រាប់រាងកាយ ហេតុនេះ ខាងផ្លូវវិញ្ញាណបូជាចារ្យឬអ្នកបួសត្រូវការរកពេលវេលាណាមួយយូរៗម្តងដើម្បីរួមគ្នាស្វែងយល់បន្ថែមអំពីជំនឿ ចែករំលែកបទពិសោធន៍នៃកិច្ចការប្រកាសដំណឹងល្អរវាងគ្នានិងគ្នា។

លោកបានបន្តថា លើសពីនេះ ក៏រកពេលវេលាស្ងៀមស្ងាត់ខ្លះៗដើម្បីរិះគិតផ្ទាល់ខ្លួន សន្ទនាជាមួយព្រះជាម្ចាស់និងរិះគិតបន្ថែមអំពីការប្រកាសដំណឹងល្អ ដើម្បីឱ្យមានកម្លាំងដើម្បីដើរទៅមុខទៀតក្នុងការមើលថែរក្សាកូនចៀមរបស់ព្រះជាម្ចាស់។

ពិធីសំណាក់ធម៌លោកបូជាចារ្យនេះបុរព្វរឹតុតទាដោយមានការពិភាក្សា ការរិះគិតតាមប្រធានបទផ្សេងៗ ការពន្យល់ណែនាំ និងរិះគិតអំពីអត្ថបទគម្ពីរផ្សេងៗ ការតាំងព្រះកាយព្រះគ្រីស្ត អភិបូជាប្រចាំថ្ងៃ និងដំណើរកម្សាន្តតាមតំបន់ផ្សេងៗរួមគ្នាផងដែរ៕





# គ្រីស្តបរិស័ទព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ប្រារព្ធពិធីបុណ្យភ្ជុំ រួមជាមួយប្រពៃណីខ្មែរតាមបែបកាតូលិក

*អត្ថបទ៖ ដាលីស*

នៅថ្ងៃទី១៧ កញ្ញា ឆ្នាំ ២០២០ ដែលជាថ្ងៃប្រារព្ធពិធីបុណ្យភ្ជុំ និងជាប្រពៃណីជាតិខ្មែរ ព្រះសហគមន៍កាតូលិក ព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន ដែលមានគ្រីស្តបរិស័ទប្រមាណជិត៦០នាក់ បានចូលរួមប្រារព្ធពិធីនេះជាមួយប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសកម្ពុជា ដោយមានពិធីថ្វាយអភិបូជា និងអធិដ្ឋាន នឹករឭកដល់មរណៈបុគ្គលទាំងអស់ ដែលដឹកនាំដោយលោកដាមីញ៉ាំង ហ្វានី ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង។





*លោក ដាមីញ៉ាំង ហ្វានី ប្រារព្ធពិធីបុណ្យភ្ជុំ និងជាប្រពៃណីជាតិខ្មែរ ព្រះសហគមន៍កាតូលិក ព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន។ **រូបភាព៖ ស៊ីអេសស៊ី***

តាមការណែនាំរបស់លោកដាមីញ៉ាំង នៅក្នុងធម្មទេសនានាឱកាសនេះលោកបានមានប្រសាសន៍លើកយកអត្ថន័យនៃអត្ថបទព្រះគម្ពីរថា ទោះបីបងប្អូនរស់ក្តី ស្លាប់ក្តី សូមលើកទឹកចិត្តគ្នាទៅវិញទៅមក។ លោកថា បុណ្យភ្ជុំ ជាដំណឹងល្អសម្រាប់យើងជាគ្រីស្តសាសនា ដោយសារសេចក្តីក្នុងអង្គព្រះគ្រីស្តដែលជាប្រភពនៃជីវិត។

លោកដាមីញ៉ាំងបញ្ជាក់ថា សម្រាប់យើងជាគ្រីស្តបរិស័ទកាតូលិក ការបុណ្យភ្ជុំមិនមែនមានតែប៉ុន្មានថ្ងៃនេះទេ គឺយើងធ្វើជារៀងរាល់ថ្ងៃ ដោយការនឹករឭកដល់អស់បងប្អូនដែលបានលាចាកលោកនេះនៅក្នុងពិធីបុណ្យអភិបូជា ជារៀងរាល់ថ្ងៃ ដោយបងប្អូនគ្រាន់តែសរសេរឈ្មោះមរណៈបុគ្គលទាំងនោះរួចដាក់នៅក្នុងស្រោមសំបុត្រដែលដាក់នៅខាងមុខព្រះវិហារ រួចប្រគល់ជូនលោកបូជាចារ្យដើម្បីអធិដ្ឋាននៅក្នុងពិធីថ្វាយអភិបូជា។

លោកបូជាចារ្យប្រកាសស្នើដល់គ្រីស្តបរិស័ទទាំងអស់ថា សូមបងប្អូនមកអធិដ្ឋាននឹករឭកដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានចែកឋានទៅ ដោយមិនមែនត្រឹមតែថ្ងៃបុណ្យភ្ជុំនេះទេ ប៉ុន្តែបងប្អូនអាចមកអធិដ្ឋាននៅទីនេះនៅថ្ងៃណាក៏បានប្រសិនបើបងប្អូនចង់ ដោយគ្រាន់តែបងប្អូនប្រាប់មកលោកបូជាចារ្យ ឬគណៈកម្មការព្រះសហគមន៍ នឹងបើកសោរជូនបងប្អូនជានិច្ច។



*គ្រីស្តបរិស័ទប្រមាណជិត៦០នាក់ បានចូលរួមប្រារព្ធពិធីនេះ។ **រូបភាព៖ ស៊ីអេសស៊ី***

លោកសិលា កាន់ប៊ុយ បានផ្តល់នូវសាក្សីភាពក្នុងនាមជាគណៈកម្មការព្រះគម្ពីរកម្ពុជាថា ទោះបីខ្ញុំជាគ្រីស្តបរិស័ទកម្ពុជា តែពិធីបុណ្យភ្ជុំជាបុណ្យប្រពៃណី ខ្ញុំអាចធ្វើដើម្បីចូលរួមជាមួយប្រពៃណីដោយតាមជំនឿរបស់ខ្ញុំជាគ្រីស្តសាសនា។ លោកបន្តថា នៅថ្ងៃនេះយើងបានប្រារព្ធពិធីបុណ្យដើម្បីនឹករឭកដល់វិញ្ញាណក្ខន្ធរបស់មរណៈបុគ្គលទាំងឡាយ និងសាច់ញាតិជាទីស្រឡាញ់ និងឪពុកម្តាយរបស់យើង ជាឱកាសមួយដើម្បីអធិដ្ឋានអង្វរព្រះជាម្ចាស់សម្រាប់វិញ្ញាណក្ខន្ធរបស់បុគ្គលទាំងនោះ ដោយសារតែពួកគាត់ផ្ទាល់ក៏ជាបុព្វបុរសរបស់យើង ហើយក៏ជាការត្រាស់ហៅរបស់ព្រះជាម្ចាស់ដោយសារពួកគាត់ទើបមានយើង។

ដូចនេះនាំឱ្យអរព្រះគុណព្រះជាម្ចាស់ និងនឹករឭកដល់ពួកគាត់។ ដូច្នេះក្នុងនាមជាគ្រីស្តបរិស័ទ ខ្ញុំមានអំណរសប្បាយដើម្បីចូលរួមនឹងបុណ្យប្រពៃណីនេះ ដើម្បីសម្តែងនិងលើកតម្កើងព្រះជាម្ចាស់នៅក្នុងជំនឿរបស់ខ្ញុំ ហើយសូមជូនពរ និងរីករាយបុណ្យភ្ជុំតាមប្រពៃណីជាតិខ្មែរ។ បន្ទាប់ពីបញ្ចប់កម្មវិធី គ្រីស្តបរិស័ទទាំងអស់រួមជាមួយគណៈកម្មការព្រះសហគមន៍ ពិសារអាហារសាមគ្គីរួមជាមួយគ្នា ស្របទៅនឹងអត្ថន័យបុណ្យភ្ជុំ ដែលជាពិធីបុណ្យជួបជុំគ្រួសារ ហើយព្រះសហគមន៍ក៏ជាមហាគ្រួសារតែមួយផងដែរ៕

# អប់រំចិត្ត ជាមុខវិជ្ជាសំខាន់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូនារី

*អត្ថបទ៖ គង់ ដាវី និង ថា សុផាលីន*

បងស្រីដែលជាបព្វជិតានៃព្រះសហគមន៍កាតូលិកប្រចាំនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារីភាគច្រើនសុទ្ធតែមានសមត្ថភាពបង្រៀនមុខវិជ្ជាផ្សេងៗបាន ប៉ុន្តែបងស្រីម្នាក់នៅក្នុងចំណោមបងស្រីទាំងអស់៦នាក់នៅមជ្ឈមណ្ឌលនោះ ឈ្មោះ តាំង សុវណ្ណៈ ដែលយុវនិស្សិតតែងតែ ហៅគាត់ថា បងស្រីនេត្រ បានចាប់យកជំនាញនៃការបង្រៀនលើមុខវិជ្ជាអប់រំចិត្ត។

បងស្រី នេត្រ បានប្រាប់ឱ្យដឹងថា បងស្រីបានចាប់ផ្តើមបង្រៀនមុខវិជ្ជាអប់រំចិត្តនេះមានរយៈពេលជាង១០ឆ្នាំមកហើយ។ ការបង្រៀនការអប់រំចិត្តនេះ បងស្រីចាប់ផ្តើមតាំងពីបងស្រីបួសមកម្ល៉េះ ពោលគឺចាប់ពីក្នុងឆ្នាំ២០០៩មកដល់សព្វថ្ងៃនេះ។

បងស្រីបានថ្លែងថា៖ «មុខជំនាញនេះ ខ្ញុំបានបង្រៀនតាំងតែពីពេល ដែលខ្ញុំមិនទាន់មកបង្រៀននិស្សិតនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារីនៅទួលគោកមកម្ល៉េះ។ កាលនៅសាលាដុនបូស្កូទឹកថ្លាខ្ញុំបង្រៀនមុខវិជ្ជាអប់រំចិត្តផងសីលធម៌ពលរដ្ឋផង និងអក្សរសាស្ត្រខ្មែរផងដែរ»។

បងស្រីនេត្របង្រៀនមុខវិជ្ជានេះជារៀងរាល់ថ្ងៃចន្ទដល់ថ្ងៃសុក្រ បង្រៀនពីរម៉ោងក្នុង១ថ្ងៃ។ ការបង្រៀននេះមានការផ្លាស់ប្តូរពេលវេលា ពេលខ្លះគាត់បង្រៀនឆ្នាំទី១ ពេលខ្លះបង្រៀនឆ្នាំទី២ទៅតាមតម្រូវការរបស់សាលា។

បងស្រីបន្តទៀតថា ជំនាញពិតប្រាកដរបស់គាត់គឺ អក្សរសាស្ត្រខ្មែរ ប៉ុន្តែគាត់មិនមានបញ្ហាអ្វីទេ ក្នុងការបង្រៀនអប់រំចិត្តព្រោះគាត់គិតថាវាមានការទាក់ទងគ្នាដែរ។ ក្រៅពីការបង្រៀនមុខវិជ្ជាមួយនេះ បងស្រីមានសមត្ថភាពបង្រៀនអក្សរសាស្ត្រខ្មែរ កុំព្យូទ័រ និងអង់គ្លេសបានដោយគ្មានបញ្ហាផងដែរ។

រយៈពេល១០ឆ្នាំជាងនេះ គឺបងស្រីចំណាយពេលនៅជាមួយយុវនិស្សិត ដុនបូស្កូទាំងអស់។

មុខវិជ្ជាអប់រំចិត្តនេះ ជាមុខវិជ្ជាមួយដ៏សំខាន់បំផុត ដោយសារបងស្រីទាំងអស់និងសាលានេះមានគោលបំណងចង់ឱ្យយុវនិស្សិតនៅដុនបូស្កូទាំងអស់មិនត្រឹមតែទទួលបាននូវជំនាញតែមួយទេ គឺចង់ឱ្យយុវនិស្សិត ទទួលបានទាំងអាកប្បកិរិយា អត្តចរិតរស់នៅសមរម្យ សំខាន់បំផុតនោះ គឺគុណធម៌និងសីលធម៌នៃការរស់នៅដើម្បីឱ្យក្រុមនិស្សិតមានគុណធម៌ក្នុងការរស់នៅប្រចាំថ្ងៃនិងពេលដែលពួកគេទៅធ្វើការ។

បងស្រីនេត្របន្តទៀតថា៖ «ការបង្រៀនមុខវិជ្ជាអប់រំចិត្តនេះជួយដល់ក្រុមនិស្សិតពេលដែលពួកគាត់ចេញទៅធ្វើការងារដែលក្រុមនិស្សិតទាំងអស់ត្រូវភ្ជាប់ជាមួយនឹងគុណធម៌និងបំពេញការងារដោយសីលធម៌ល្អ មានទំនួលខុសត្រូវខ្ពស់»។

បងស្រីបន្តទៀតថា ការបង្រៀនមុខវិជ្ជានេះគឺចង់បណ្តុះយុវនិស្សិតឱ្យក្លាយជាប្រជាពលរដ្ឋដែលមានភាពស្មោះត្រង់ដែលសកម្មនិងមានគុណធម៌ ដែលទាំងនេះគឺជាវត្ថុនិងគោលបំណងដ៏សំខាន់របស់សាលាដុនបូស្កូ។

បងស្រីបានបន្តថា ដើម្បីងាយស្រួលបង្រៀនមុខវិជ្ជានេះ គឺបងស្រីត្រូវស្គាល់និស្សិតផ្ទាល់ម្នាក់ៗតែម្តង មានន័យថាបងស្រី បង្រៀននិស្សិតប៉ុន្មាននាក់ គឺបងស្រីត្រូវស្គាល់និងដឹងរឿងរបស់ពួកគាត់ទាំងអស់ដែរ។

បងស្រីថា៖ «មានតែការស្គាល់ពួកគេនិងជិតស្និទ្ធនឹងពួកគេតែប៉ុណ្ណោះ ទើបអាចឱ្យខ្ញុំអប់រំពួកគេបានល្អ»។

ក្រៅពីបងស្រី នេត្យ បងស្រីម្នាក់ទៀត មកពីប្រទេសអាល់សាវ៉ាឌ័រ ឈ្មោះអាម៉ាន់ដា ហ្គូដាល់ឡូបអាល់វ៉ាដូ បានមានប្រសាសន៍ថា គាត់គឺជាគ្រូបង្រៀនមុខវិជ្ជាអប់រំចិត្តដល់សិស្សឆ្នាំទី២នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ ផ្នែកនារីនេះផងដែរ។

បងស្រី អាម៉ាន់ដា បានលើកឡើងថា គាត់បានបង្រៀនមុខវិជ្ជាអប់រំចិត្តនៅប្រទេសកម្ពុជាកាលពីមួយឆ្នាំមុន ហើយក្រៅពីមុខវិជ្ជានេះគាត់ក៏អាចបង្រៀនមុខវិជ្ជាផ្សេងទៀតបានដែរគឺភាសាអង់គ្លេស ជាដើម។

បងស្រីបានមានប្រសាសន៍ថា៖ «ចំពោះមុខវិជ្ជាអប់រំចិត្តគឺសិក្សាអំពីគុណតម្លៃរបស់មនុស្សការអប់រំឱ្យមនុស្សក្លាយទៅជាមនុស្សល្អនៅក្នុងសង្គម មានការប្រាស្រ័យជាមួយមនុស្សជុំវិញខ្លួនចេះគោរពអ្នកដទៃ យល់ដឹងពីតជីវិតគ្រួសារ មុនក្លាយទៅជាម្តាយមួយរូប ហើយនឹងរបៀបរបបនៃការមើលថែចិញ្ចឹមបីបាច់កូន មុនពេលសិស្សនិស្សិតគ្រប់រូប មានគ្រួសារ និងក្លាយទៅជាម្តាយមួយរូប»។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូផ្នែកនារី នេះបានបើកដំណើរការបណ្តុះបណ្តាលជំនាញកុំព្យូទ័រនិងលេខាធិការដល់យុវតីកម្ពុជាតាំងពីឆ្នាំ១៩៩២ ស្ថិតនៅក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ។ នៅក្នុងមួយឆ្នាំមជ្ឈមណ្ឌលនេះបានបណ្តុះបណ្តាលយុវតីក្រីក្រដែលមកពីសហគមន៍នានា ទាំងនៅជនបទនិងទីក្រុងជាមធ្យមប្រមាណជាជាង៧៨នាក់។ ដោយឡែកមុខវិជ្ជាអប់រំចិត្តនេះ គឺជាមុខវិជ្ជាមួយប្លែកដែលហាក់បីដូចជាមិនដែលបានឃើញនៅក្នុងកម្មវិធីសិក្សានៅស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សានិងក្រោយឧត្តមសិក្សានៅកម្ពុជា៕

# ទំនាក់ទំនងអន្តរសាសនា ដើម្បីលើកកំពស់សន្តិភាពនិងសុខដុមសាសនាក្នុងសហគមន៍





*លោកអភិបាលអូលីវីយេ រួមជាមួយព្រះសង្ឃ គណៈកម្មការវត្ត បានរួមគ្នាដាំដើមឈើ និងស្មៅ រៀបចំសួន។ **រូបភាព៖ ស៊ីអេសស៊ី***

*អត្ថបទ៖ CSC*

សកម្មភាពនៃកិច្ចសន្ទនាអន្តរសាសនា ដើម្បីលើកកំពស់សន្តិភាព និងសុខដុមសាសនា ក្នុងសហគមន៍ រវាងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលមានលោកអភិបាលអូលីវីយេជាអភិបាល បានកសាងចំណងមេត្រីភាពយ៉ាងជិតស្និទ្ធរវាងព្រះសហគមន៍កាតូលិក ជាមួយវត្តអង្គមន្ត្រីក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ លោកអភិបាលអូលីវីយេ រួមជាមួយព្រះសង្ឃ គណៈកម្មការវត្ត បានរួមគ្នាដាំដើមឈើ និងស្មៅ រៀបចំសួននៅមុខរូបសំណាក់ដែលលោកអភិបាលបានប្រគេនដល់វត្តអង្គមន្ត្រី។

ព្រះសង្ឃលោកអាចារ្យ និងគណៈកម្មការវត្តអង្គមន្ត្រី បានថ្លែងអំណរគុណ លោកអភិបាលអូលីវីយេ ជ្មីតហស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជាប្រធានបរិស្ថានវត្តអង្គមន្ត្រី។

ព្រះគ្រូចៅអធិការវត្តមានថេរដីការថា លោកអភិបាលបានប្រគេនរូបសំណាកចំនួនបីរួមមាន រូបសំណាកសម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) រូបសំណាកព្រះបាទជ័យវរ្ម័នទី៧ និង រូបសំណាកអភិរម្យក្រម ង៉ុយ។ ជាមួយគ្នានេះលោកក៏បានប្រគេនដើមក្រញូងពីរដើម និងប្រគេនស្មៅ១០០ការ៉េ ដើម្បីធ្វើសួនច្បារមុខរូបសំណាកផងដែរ។



សូមបញ្ជាក់ថា ក្នុងរដូវកាលនៃការការពារប្រយុទ្ធនឹងជំងឺកូវីដ១៩ លោកអភិបាលអូលីវីយេ បានប្រគេនរោងកសិដ្ឋានដាំបន្លែ និងបានជួយរៀបចំតាមស្តង់ដាបច្ចេកទេសទៀតផង។ ចំពោះព្រះសង្ឃ និងគណៈកម្មការវត្តអង្គមន្ត្រីក៏បាន ជូនដល់លោកអភិបាលនូវកញ្ចុះធ្វើពីឫស្សីមួយយ៉ាងស្អាតផងដែរនាពេលកន្លងទៅ និងបានដាក់ក្បែរកុដិលោកអភិបាល នៅព្រះសហគមន៍ភូមិចំការទៀង ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ៕

# ពិធីបញ្ចុះគ្រឹះរបស់បឋមសិក្សាមាតានៃសន្តិភាព

*អត្ថបទ៖ សេង មួយ*

សាលាបឋមសិក្សាមាតានៃសន្តិភាពដែលជាសាលារបស់ព្រះវិហារសន្តីម៉ារីនៃព្រះសហគមន៍ច្រាបវាលនឹងមានអាគារសិក្សាថ្មីជាច្រើនបន្ទប់នាពេលឆាប់ៗខាងមុខនេះ។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០នេះ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោក ទេព ច័ន្ទពិសិដ្ឋ រួមនិងសហការីរបស់លោក និងអាជ្ញាធរមូលដ្ឋានបានចូលរួមជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាសម្រាប់អាគារសាលានេះ។

ព្រះសហគមន៍ច្រាបវាលបានបង្កើតសាលាមត្តេយ្យនិងសាលាបឋមសិក្សាជាច្រើនឆ្នាំមកហើយ តែដោយសារមានចំនួនសិស្សកាន់តែច្រើន ធ្វើឱ្យគ្មានកន្លែងគ្រប់គ្រាន់ដើម្បីទទួលសិស្ស។

ដោយមានជំនួយពីក្រុមគ្រួសារបងស្រីឧសុលីន ព្រះសហគមន៍បានសម្រេចចិត្តធ្វើអាគារសិក្សាថ្មីបន្ថែមទៀត ដើម្បីឱ្យកុមារមានកន្លែងរៀនសមរម្យ និងទទួលបានការអប់រំល្អ។

គម្រោងនៃការសាងសង់របស់សាលានេះរួមមាន អាគារ១ខ្នងកម្ពស់១ជាន់ (ជាន់ផ្ទាល់ដី និងជាន់ទី១) សរុបមាន១២បន្ទប់ មានថ្នាក់រៀន៩បន្ទប់ ថ្នាក់កុំព្យូទ័រ១បន្ទប់ ការិយាល័យ១បន្ទប់ បន្ទប់សិល្បៈ១បន្ទប់ និងមានអាគារសម្រាប់កម្មវិធីផ្សេងៗផងដែរ។



*អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោក ទេព ច័ន្ទពិសិដ្ឋ រួមនិងសហការីរបស់លោក និងអាជ្ញាធរមូលដ្ឋានបានចូលរួមជាអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាសម្រាប់អាគារសាលាបឋមសិក្សាមាតានៃសន្តិភាព។ **សហការី***

បច្ចុប្បន្ន សាលានេះមានគ្រូចំនួន៤នាក់ និងសិស្សចំនួន១៤០នាក់។ សាលាបឋមសិក្សាមាតានៃសន្តិភាព ស្ថិតនៅភូមិច្រាបវាល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង៕



# លោកឪពុក រ៉ូ ង្វៀន ត្រូវបានជ្រើសតាំងជាប្រធានក្រុមសហជីវិនប្រចាំអូស្ត្រាលី

*អត្ថបទ៖ CSC*

លោកឪពុក រ៉ូ ង្វៀន ត្រូវបានជ្រើសតាំងជាប្រធានក្រុមសហជីវិន ប្រចាំអូស្ត្រាលី លោកឪពុក អាទូរ៉ូ សូសា (Fr Arturo Sosa SJ) ជាប្រធានក្រុមគ្រួសារបព្វជិត សហជីវិនព្រះយេស៊ូ បានជ្រើសតាំងលោកឪពុក ដូមីនីក រ៉ូ គីម ង្វៀន ជាប្រធានក្រុមសហជីវិនព្រះយេស៊ូប្រចាំតំបន់អូស្ត្រាលី (Provincial of the Australian province)។ នេះបើតាមការចុះផ្សាយរបស់គេហទំព័រ Australian Jesuit: Jesuit.org.au។ ប្រភពដដែលបានបន្តថា លោកឪពុក រ៉ូ ង្វៀន នឹងចូលបំពេញមុខងារថ្មីនេះ នៅខែមករា ឆ្នាំ២០២១។

លោកឪពុក រ៉ូ ង្វៀន កើតនៅប្រទេសសឹង្ហបុរី បន្ទាប់មកបានទទួលសិទ្ធិជ្រកកោនជាជនភៀសខ្លួន រួមជាមួយក្រុមគ្រួសារនៅប្រទេសអូស្ត្រាលី។ លោកចូលរួមក្នុងក្រុមគ្រួសារ បព្វជិតសហជីវិន ក្នុងឆ្នាំ១៩៩៤ និងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ២០០៤ ហើយបានថ្វាយពាក្យសច្ចានិរន្តរ៍ នៅឆ្នាំ២០១៤។ លោកបានសិក្សាផ្នែកវិទ្យាសាស្ត្រ ទេវវិទ្យា និងការអប់រំ។

លោកបានមកបម្រើការងារនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០១៥ ហើយបច្ចុប្បន្នជាលេខាធិការផ្នែកអប់រំ បឋមសិក្សានិងមធ្យមសិក្សា នៃក្រុមសហជីវិនព្រះយេស៊ូនៅប្រទេសកម្ពុជា និងជានាយកសាលាសន្ត សាវីយេ នៅស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ។

លោកឪពុក ដូមីនីក រ៉ូ គីម ង្វៀន ធ្លាប់បម្រើការងារនៅប្រទេសទីម័រខាងកើតនិងបានបញ្ចប់ការសិក្សាក្រោយឧត្តមសិក្សាផ្នែកអប់រំសិក្សានៅបូស្តុនឆ្នាំ ២០០៩-២០១១៕





# គ្រីស្តបរិស័ទព្រះសហគមន៍នានាប្រារព្ធពិធីបុណ្យភ្ជុំរួមជាមួយប្រពៃណីខ្មែរតាមបែបកាតូលិក



*អភិបូជាបុណ្យភ្ជុំនៅព្រះវិហារសន្តីតេរេសា នៃព្រះសហគមន៍ចំណោម។ **រូបភាព៖ ច្រុច សាវ៉ែន***









*យុវជន យុវនារីនៃព្រះសហគមន៍តំបន់មណ្ឌលគិរី នៃភូមិភាគកំពង់ចាម រួមនឹងបងស្រីវពេនហ៊ីល បានចុះសួរសុខទុក្ខ និងជូនខោអាវ និងក្រមាដល់ចាស់ជរា ក្នុងឃុំប៊ូស្រា កាលពីពេលបុណ្យភ្ជុំ។ **រូបភាព៖ Chek Tev***

បន្តទៅទំព័រ - ២០

# ការប្រារព្ធខួប៥៥ឆ្នាំនៃព្រះវិហារសន្តមីកាអែលក្នុងខេត្តព្រះសីហនុ

*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍កំពង់សោម ព្រះវិហារសន្តមីអាអែលបានប្រារព្ធពិធីបុណ្យអភិបូជាសម្រាប់ពិធីសំខាន់ៗចំនួន៤កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ កន្លងមកនេះ ក្រោមអធិបតីភាពលោក អូលីវីយេ ជ្មីតហស្លេរ៉ េ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ពិធីទាំងនោះមាន ការអបអរសាទរខួបទី៥៥ឆ្នាំនៃការកកើតវិហារសន្តមីអាអែល ការផ្តល់អគ្គសញ្ញាជ្រមុជទឹកដល់កុមារចំនួន៥នាក់ អគ្គសញ្ញាព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទចំនួន៧នាក់ និងខួបទី១០ឆ្នាំនៃលោកអភិបាលអូលីវីយេ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញពេញសិទ្ធិ។

នៅក្នុងធម្មទេសនានៃពិធីបុណ្យអភិបូជានេះ លោកអភិបាលអូលីវីយេ បានអប់រំគ្រីស្តបរិស័ទទាំងអស់ឱ្យរិះគិត ធ្វើដូចម្តេចដើម្បីចូលក្នុងប្រវត្តិសាស្ត្រ និងដោយយល់ថា នៅក្នុងដៃរបស់យើងកំពុងសាងសង់គ្រឹះបច្ចុប្បន្នកាលដើម្បីសាងសង់អនាគត។

លោកអភិបាលបានលើកយកគំរូនៃអគ្គទេវទូតមីកាអែល ដែលជាឧបការីជននៃព្រះសហគមន៍នេះថា៖ «អគ្គទេវទូតមីកាអែល ជានិមិត្តរូបនៃអំពើសុចរិតដែលសម្លាប់អំពើបាប ហើយតាមរយៈទេវទូតមីកាអែលជាពេលវេលាមួយដើម្បីកសាងជីវិតថ្មី»។

លោកអភិបាលក៏បានដាស់តឿនគ្រីស្តបរិស័ទដោយក្រើនរំឭកបន្ថែមថា យើងនឹករឭកដល់វិហារនេះដែលបានសាងសង់ឡើង៥៥ឆ្នាំមុន និងបានឆ្លងទាំងអំណរសប្បាយ និងទុក្ខលំបាកនៅក្នុងសង្គមយើង ហើយសព្វថ្ងៃការរស់នៅក្នុងក្រុងសម័យថ្មី នាំឱ្យយើងជាគ្រីស្តបរិស័ទសួរសំណួរដែរថា តើយើងជាគ្រីស្តបរិស័ទនៅទីនេះធ្វើដូចម្តេចដើម្បីប្រកាសដំណឹងល្អ? យើងធ្វើដូចម្តេចដើម្បីឱ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅជាសញ្ញាសម្គាល់ ដែលនាំឱ្យមានសេចក្តីសង្ឃឹមសម្រាប់បងប្អូនឯទៀតៗមិនត្រឹមតែគ្រីស្តបរិស័ទ។

លោកអភិបាលបានមានប្រសាសន៍ថា៖ «ខ្ញុំជឿថាសម្រាប់យើងជាគ្រីស្តបរិស័ទនៅភូមិភាគភ្នំពេញ យើងត្រូវពិចារណាដែរថា តើយើងធ្វើដូចម្តេចដើម្បីឱ្យព្រះសហគមន៍របស់យើងទៅជាគ្រួសារកក់ក្តៅដែលណែនាំឱ្យបងប្អូនឯទៀតៗចាប់អារម្មណ៍? ធ្វើដូចម្តេចដើម្បីឱ្យយើងឆ្លើយតបទៅនឹងសំណួរ តើព្រះជាម្ចាស់ជានរណា? គឺត្រូវធ្វើសាក្សីភាពតាមរយៈព្រះសហគមន៍កាតូលិកយើងអាចឆ្លើយតបសំណួរនេះដល់បងប្អូនឯទៀតៗដែលសួរខ្លួនឯងដែរ»។

លោក អ៊ុន សុន ជាបូជាចារ្យទទួលបន្ទុកព្រះសហគមន៍នេះ បានមានប្រសាសន៍ថា ក្នុងព្រះសហគមន៍ដែលលោកបានមកនៅអស់៩ឆ្នាំដែលទទួលការខុសត្រូវនៅព្រះសហគមន៍នេះ រួមជាមួយលោកបូជាចារ្យជំនួយនិងបងស្រីដែលបានសហការគ្នានៅទីនេះ ធ្វើឱ្យព្រះសហគមន៍នៅទីនេះមានជីវិតទោះបីជាពេលខ្លះពួកលោកមានទុក្ខលំបាកក៏ដោយ



*អបអរសាទរខួបទី៥៥ឆ្នាំនៃការកកើតវិហារសន្តមីអាអែល ក្រោមអធិបតីភាពលោក អូលីវីយេ ជ្មីតហស្លេរ៉េ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ **រូបភាព៖ ស៊ីអេសស៊ី***

ក៏ប៉ុន្តែលោកបានអរគុណដល់បងប្អូនទាំងអស់ដែលធ្វើឱ្យក្រុមលោកមានជីវិតថ្មី។

លោកមានប្រសាសន៍ថា៖ «នៅក្នុងកាលៈទេសៈកូវីដ១៩នេះ យើងបានប្រជុំគ្នាជាមួយគណៈកម្មការ និងចែករំលែកនូវអ្វីដែលយើងត្រូវធ្វើរួមគ្នា ហើយក៏មានការទូន្មានពីលោកអភិបាល ដើម្បីទទួលចំណូលថ្មីដោយកក់ក្តៅជាក្រុមគ្រួសារដែលជាលក្ខណៈព្រះសហគមន៍ ជាផ្ទះរបស់ព្រះជាម្ចាស់»។

ព្រះសហគមន៍នេះបានសាងសង់ឡើងក្នុងសម័យសង្គមរាស្ត្រនិយម និងបានចេញប្លង់ដោយស្ថាបនិកដ៏ល្បីឈ្មោះប្រចាំប្រទេសកម្ពុជា ហើយព្រះសហគមន៍បានជ្រើសរើសសន្តមីកាអែល ធ្វើជាឧបការីព្រះសហគមន៍ ដោយសារព្រះវិហារនេះបានឆ្លងកាត់សម័យសង្គ្រាមជាច្រើនលើក ហើយសន្តមីកាអែលគឺជាអគ្គទេវទូតដែលទទួលជ័យជម្នះលើសង្គ្រាម៕

ទស្សនាវីដេអូទីនេះ

